00338746

E1/28.1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩**

**សវនាការលើកទី២៤**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក វីលៀម ស្មីត

*(Mr. William SMITH)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ *(Mr. Stuart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអាវ

**មេធាវីការពារជនជាប់ចោទ ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

កញ្ញា ទី ស្រ៊ុនណា

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៊ែនណឺ

*(Mr. Alain WERNER)*

លោកស្រីអេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី ៖** ជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ ឌុច

សួរដោយ លោក តាន់ សេណារ៉ុង ផ្ដើមពី ............................................ ទំព័រ ៣
សួរដោយ លោក វីលៀម ស្មីត ផ្ដើមពី............................................ ទំព័រ ២៦
សួរដោយ លោក អាឡាំង វែ៉នណឺ ផ្ដើមពី ............................................ ទំព័រ ៥៧
សួរដោយ លោកស្រី ស៊ីលយិ ស្ទូតហ្សិនស្តី ផ្ដើមពី............................................ ទំព័រ ៧៤

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ដាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន | បារាំង |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:១៣:២៨]

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលលើអង្គហេតុនៃការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅក្នុងស-២១ ។ ហើយមុននឹងចាប់ផ្តើមដំណើរការ ខ្ញុំក្នុងនាមអង្គជំនុំជម្រះសាលាដំបូង សូមជម្រាបដល់ភាគី និងសាធារណជនបានជ្រាបថា នៅថ្ងៃព្រហស្បតិ៍ ទី១១ ខែមិថុនា ឆ្នាំ២០០៩ ខាងមុខនេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនធ្វើសវនាការទេ ។ ដោយអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យឃើញថា មានបញ្ហាជាច្រើនដែលត្រូវធ្វើការបើកកិច្ចប្រជុំត្រៀមរៀបចំសវនាការ និងត្រូវចំណាយពេលវេលាពេញមួយថ្ងៃ ដើម្បីអញ្ជើញគូភាគីមកពិភាក្សាអំពីកាលវិភាគសវនាការដែលត្រូវធ្វើនាពេលខាងមុខ និងបញ្ហាផ្សេងៗមួយចំនួនទៀតដែលកំពុងជួបប្រទះ ។ ដូច្នេះ សូមភាគីនៅក្នុងរឿងក្តីនេះជ្រាប ហើយនិងត្រៀមលក្ខណៈមតិយោបល់ផ្សេងៗដើម្បីចូលរួមនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំខាងមុខ ។

ចំណែកឯរបៀបវារៈនៃកិច្ចប្រជុំ អង្គជំនុំជម្រះកំពុងតែត្រៀមរៀបចំ ហើយនឹងជូនដល់ភាគីនៅក្នុងអំឡុងពេលខាងមុខ ធ្វើយ៉ាងណាឲ្យបានមុខថ្ងៃបើកកិច្ចប្រជុំរៀបចំដំណើរការកិច្ចសវនាការ ។

ដោយសារបញ្ហានេះ ជាបញ្ហាបច្ចេកទេសនៃដំណើរការសវនាការ ដែលទាមទារឲ្យភាគីដែលមានបច្ចេកទេសក្នុងការចូលរួម គឺអាចអញ្ជើញចូលរួមនៅក្នុងនីតិវិធីនេះបានពេញលេញ ។ ដោយឡែកភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលកាលមុនមានការកត់សម្គាល់ពីមេធាវី ស្ទួតហ្សីនស្គី និងមេធាវី មួយចំនួនផ្សេងទៀត អំពីសិទ្ធិចូលរួមរបស់អ្នកដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលមានការប៉ុនប៉ងចូលរួម គឺអង្គជំនុំជម្រះមិនហាមឃាត់ទេ ។ អញ្ជើញចូលក៏បាន មិនអញ្ជើញចូលក៏បានដែរ ដោយសារបញ្ហានេះជាបញ្ហាបច្ចេកទេសនៃកិច្ចពិភាក្សាដើម្បីរៀបចំដំណើការសវនាការ ធ្វើយ៉ាងណាឲ្យបានល្អ ឲ្យបានឆាប់រហ័ស ។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបដល់សាធារណជនផងដែរថា នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំពិភាក្សាអំពីរៀបចំសវនាការនោះ គឺអង្គជំនុំជម្រះនឹងដំណើរការទៅជាទូទៅធ្វើជាសម្ងាត់ ។ ដូច្នេះ គឺ

សាធារណជនមិនចាំបាច់ចូលរួមនៅក្នុងដំណើរការអង្គប្រជុំដែលនឹងរៀបចំនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០០៩ នោះទេ ។

[០៩:១៧:២៥]

ជាកិច្ចបន្តសូមក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគីដែលត្រូវចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួនហើយ ។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាំងរង់ក្រចកសេះខាងមុខនេះ ។

*[ជនជាប់ចោទដើរទៅកាន់ឈើរាំងរង្វង់ក្រចកសេះ]*

មុននឹងដំណើរការពិភាក្សាដេញដោល អង្គជំនុំជម្រះសូមរំឭកដល់ភាគីថា ការដែលយើងធ្វើសវនាការដេញដោលនៅថ្ងៃនេះ គឺអង្គហេតុនៃការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ ដែលកាលពីធ្វើដំណើររការសវនាការពីពេលមុននោះ គឺអង្គជំនុំជម្រះបានធ្វើការដេញដោលចំពោះជនជាប់ចោទហើយ ។ ហើយនៅក្នុងអំឡុងពេលបន្ទាប់គឺយើងបានសួរដេញដោលដល់អ្នកជំនាញក្រេក អេតឆេសាន់ ដែលមានការពាក់ព័ន្ធទៅនឹងអង្គហេតុនេះរួចហើយ ។ ហើយកិច្ចការមួយចំនួន មានឯកសារមួយចំនួនដែលយើងបានសួរដេញដោលពាក់ព័ន្ធជាមួយអង្គហេតុនេះ ជាមួយនឹងជនជាប់ចោទរួចហើយដែរ ។

ដូច្នេះ អង្គជំនុំជម្រះសូមរំឭកភាគីថា ដើម្បីឲ្យដំណើរការប្រព្រឹត្តទៅបានត្រឹមត្រូវ គឺប្រឹងប្រែងរៀបចំដំណើរការក្នុងការតាំងសំណួរផ្សេងៗ គឺចៀសឲ្យផុតពីការតាំងសំណួរច្រំដែល ដែលយើងបានសួរដេញដោលរួចហើយ ។ ដោយកត់សម្គាល់នេះ វាមានបញ្ហាខ្លះ ដោយការដែលយើងធ្វើទៅមានមិនតាមលំដាប់លំដោយ ដោយសារហេតុបច្ចេកទេស និងអ្នកជំនាញដែលត្រូវចូលរួមនោះមានកាលវេលាកំណត់របស់គាត់ ដែលមានការងារមមាញឹកក្នុងវិជ្ជាជីវៈរបស់គាត់នោះ ទើបមានបញ្ហា ដែលយើងបានធ្វើសវនាការកន្លងមកនេះមានបញ្ហារៀបចំមុខក្រោយ រវាងការសួរដេញដោលជនជាប់ចោទ និងសួរភាគីដែលពាក់ព័ន្ធនៅក្នុងនោះមានអ្នកជំនាញចំនួនពីររូបដែលយើងបានធ្វើរួចហើយ ។ ហើយដោយសារ

ពេលមុនយើងបានដំណើរការរហូតដល់ ត្រូវដល់វេទិកានៃភាគីដែលត្រូវចូលសួរដល់ជនជាប់ចោទពាក់ព័ន្ធជាអង្គហេតុដែលបានជម្រាបជូននេះ ។

អ៊ីចឹងដើម្បីជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះ ទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានលទ្ធភាពក្នុងការតាំងសំណួរពាក់ព័ន្ធជាមួយនឹងជនជាប់ចោទ និងអង្គហេតុដែលបានជម្រាបជូនអម្បាញ់មិញនេះ ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាប្រសិនបើមានសំណួរ ។

[០៩:២១:០៧]

**សួរដោយលោក តាន់ សេណារ៉ុង៖**

សូមអរគុណលោកប្រធានអង្គជំនុំជម្រះ និងគោរពសវនាការ ។ នៅថ្ងៃនេះតំណាងសហព្រះរាជអាជ្ញានឹងសូមលើកយកនូវសំណួរដែលពាក់ព័ន្ធជាមួយនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដូចខាងក្រោម ។

សហព្រះរាជអាជ្ញាយល់ឃើញថា នៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍ លេខពិសេស ចុះក្នុងខែឧសភា-មិថុនា ឆ្នាំ១៩៧៨ ដែលមានលេខ *ERN Number* នោះ 00064551 ដែលជាលេខនៅក្នុងឆ្នាំ១៩៧៨ នៅត្រង់ទំព័រលេខ១៦និង១៧ ស្ដីពីចំពោះអ្នកដែលបានទទួលការចាត់តាំងពីខ្មាំង ក្នុងនោះបក្សកុម្មុយនីស្តកម្ពុជាបានលើមាគ៌ារបស់បក្សដូចខាងក្រោម៖

មួយ វាមានពីមុខឆ្នាំ១៩៦៨ មក ។

ទីពីរ មានចាប់ពីឆ្នាំ១៩៦៨ រហូតដល់ឆ្នាំ១៩៧០ ។

ទីបី វាមានពីឆ្នាំ១៩៧០ រហូតមកដល់ឆ្នាំ១៩៧៥ ។

ទីបួន ពីឆ្នាំ១៩៧៥ មកដល់ថ្ងៃរំដោះ ។

ហើយនៅក្នុងដំណាក់កាលពី៧៥ រហូតមកដល់ថ្ងៃរំដោះហ្នឹង បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកជាពីរចំណែក ។ ក្នុងនោះដែរមាននិយាយអំពីអ្នកដែលបានចូលចុះចូលខ្មាំង ដែលខ្ញុំសូមមិនអានឡើងវិញទេ ។ ទីពីរ ចំណុចទីពីរ គឺមាននិយាយអំពីការធ្វើឲ្យស្ងប់ស្ងាត់ដើម្បីកុំឲ្យខ្មាំងវាផ្អើលរត់ចូលស៊ីង ហើយឲ្យវារត់ចូលស៊ីងយើង ។ នៅក្នុងចំណុចដែលសហព្រះរាជអាជ្ញាចង់បាន សួរថាតើការលើកឡើងនូវមាគ៌ាបក្ស នូវចំណុចទាំងនេះវាមានប្រសិទ្ធភាពដែរឬទេ នៅក្នុងក្របខ័ណ្ឌគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាកន្លងមកហ្នឹង? ហើយជាពិសេស ហើយនិយាយដោយឡែកនៅក្នុងគោល

ការណ៍បក្សកុម្មុយនីស្តកម្ពុជា ដែលអនុវត្តនៅក្នុងមន្ទីរស-២១ នៅពេលដែលគេយកអ្នកទោសដែលមានប្រវត្តិតស៊ូមុនរំដោះឆ្នាំ១៩៧៥ មកហ្នឹង ។

[០៩:២៤:២៥]

តំណាងការិយាល័យសហព្រះរាជអាជ្ញានឹងសូមជូនលោកដើម្បីជាមធ្យោបាយនៅក្នុងការលោកបានពិនិត្យមើលនូវឯកសារទាំងនោះ ។ ក្រឡាបញ្ជី សូមអនុញ្ញាតពីលោកប្រធាន ដើម្បីសូមជូនឯកសារមួយច្បាប់នេះដើម្បីជូនគាត់មើល ដើម្បីងាយស្រួលកុំឱ្យគាត់ពិបាករក ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនទៅជនជាប់ចោទ ។

[០៩:២៥:៤៨]

**សួរដោយ លោក តាន់ សេណារ៉ុង៖**

**ស៖** តើលោកអាចឆ្លើយនឹងសំណួររបស់ការិយាល័យសហព្រះរាជអាជ្ញាហ្នឹងបានទេនូវចំណុចដែលខ្ញុំបានលើកឡើងនេះ?

**ឆ៖** សូមគោរពលោកប្រធាន ។ សំណួរនេះវែង ។ ខ្ញុំក្តាប់ខ្លឹមសារបានខ្លះ ដូច្នេះ ខ្ញុំសូមសាកល្បងឆ្លើយដូចតទៅ ប្រសិនបើខុសទាស់យ៉ាងម៉េចសូមលោកសហព្រះរាជអាជ្ញាលោកមេត្តាសួរបញ្ជាក់ម្តងទៀតដោយអនុគ្រោះ ។

ខ្ញុំបានឃើញឯកសារនេះពីរលើក ម្តងជាសារាចរទៅដល់ស-២១ មុននឹងឃើញទស្សនាវដ្តីនេះ ឬក៏ក្រោយពីទស្សនាវដ្តីនេះ ខ្ញុំវង្វេងអស់ហើយសាមសិបប្រាយឆ្នាំមកហើយ ខ្លឹមសារដដែល ។ ខ្លឹមសារនយោបាយនៅក្នុងសារាចរ ហើយនិងនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍លេខពិសេសនេះមិនខុសគ្នាទេដដែលទេ ។ ជាការចាប់អារម្មណ៍របស់ខ្ញុំភ្លាមក្នុងពេលឃើញសារាចរនេះអរដែរ អរដោយនឹកឃើញថា ប្រជាជនជម្លៀសដែលពីដើមមកគេទុកជាអនុប្រជាជន គេមិនឱ្យមានសិទ្ធិទោះបីខំយ៉ាងណាក៏ដោយចូលយុវ-កក ទោះបីខំយ៉ាងណាក៏ដោយចូលបក្ខជន ហើយមិនមានសិទ្ធិចូលធ្វើកងទ័ពទៅទៀត ។ នេះប្រជាជនជម្លៀស ប្រជាជនថ្មី នោះគេហៅថា ប្រជាជន១៧មេសា នោះគឺវាអត់សិទ្ធិអីចឹង ។ ឃើញឯកសារនេះខ្ញុំអរ ។ ហើយតាមពិតមនុស្សដែលគេចាប់បញ្ជូនយកមកស-២១ ហើយបក្សចាត់ទុកថា ជា "ខ្មាំង" ហើយ ឱ្យតែខ្មាំងត្រូវតែ "កម្ទេច" ។ នេះជាក់ស្តែង ។

ក្នុងមួយជីវិតមន្ទីរស-២១ តាំងពីខ្ញុំកាន់កាប់កិច្ចការជាអនុប្រធានពេញលក្ខណៈ គឺពីខែ១០ ឆ្នាំ

១៩៧៥ រហូតដល់ថ្ងៃ៧ មករា ១៩៧៩ បក្សឲ្យខ្ញុំដោះលែងមនុស្សតែបីនាក់គត់ ។ នេះបក្សបញ្ជាតែម្ដង គឺពួកហ្វូរ៉ូ ។ ហ្វូរ៉ូ នេះខ្ញុំដូចជាជម្រាបអង្គសវនាការយើងនេះម្ដងរួចមកហើយ ជាអក្សរកាត់មកពីភាសាបារាំងថា "*ហ្វ្រង់អ៊ុយនី ឌេលុត ឌេរ៉ាស់អ៊ុបពីមេ*" គឺឲ្យដោះលែងតែបីហ្នឹងឯង ក្រៅពីនោះ "កម្ទេច" ទាំងអស់ គ្មានដោះលែងទេ ។ នេះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបញ្ជាឲ្យ ស-២១ អនុវត្តគឺអ៊ីចឹង ដូច្នេះឯកសារនេះ មិនមានសារសំខាន់ដល់ស-២១ ទេ ។

[០៩:២៩:១៦]

ជាពិសេស វគ្គឆ្នាំ១៩៧៨ ជាវគ្គនយោបាយមួយដែលខ្ញុំអត់បានរៀនជាមួយនឹងមេចាស់ខ្ញុំទេ គឺលោកគ្រូ សុន សេន ។ វគ្គឆ្នាំ១៩៧៨ នេះ ខ្ញុំទៅរៀនជាមួយនឹងមន្ទីរផ្សេងទៀត វគ្គនេះបង្រៀនដោយ ប៉ុល ពត ខ្លួនគាត់ផ្ទាល់តែម្ដង ។ ពេលនោះគាត់និយាយសម្បើមណាស់ គាត់ថា "ស-២១ អត់មានសួរអីទៀតទេ" មនុស្សដែលគេបញ្ជូនទៅទុក ។ ប៉ុន្តែ គាត់ទាំងមិនមានប្រសាសន៍អ៊ីចឹងទៀតផង ។ ខ្ញុំអរ ថា អ៎ ស-២១ ធូរហើយ ។ វារួចអំពីគ្រោះ និយាយថា គ្រោះថ្នាក់ក៏មិនត្រូវដែរស និយាយថា ឧក្រិដ្ឋកម្មក្នុងរឿងវាយមនុស្ស ក្នុងរឿងសម្លាប់មនុស្សរួច ខ្ញុំអរណាស់ ។ បីថ្ងៃក្រោយមក ពូនួន គាត់ហៅខ្ញុំទៅធ្វើការ គឺ នួន ជា រាល់ថ្ងៃនេះ ។ ដល់គាត់ហៅខ្ញុំទៅធ្វើការ ខ្ញុំថាអេ អត់បានសួរផង ។ ខ្ញុំប្រកែកទៅតាមមាគ៌ាដែលខ្ញុំបានរៀនជាមួយនឹង ប៉ុល ពត ថ្ងៃនុំង ។ ពូនួន គាត់ស៊ុកឲ្យខ្ញុំមួយម៉ាត់ គាត់ថា មិត្តឌុច ឥឡូវគាត់ចេះមាគ៌ាសម្បើមណាស់ ខ្ញុំហួសចិត្ត ។ ត្រឡប់មកវិញ ខ្ញុំយកមកគិត ។ ខ្ញុំថា អូ៎! អាល្បែងអស់នេះ គឺគ្រាន់តែជាល្បែងផ្សាយចំហដែលខ្ញុំធ្លាប់រាយការណ៍ជូនលោកចៅក្រម ឡាវែន៍ ថា ជា *ហ្វាសាត* ជារបាំងមុខ ។ អារបាំងមុខដែលអាក្រក់បំផុត គឺវគ្គសិក្សា១៩៧៨ ដែលខ្ញុំទៅរៀនជាមួយ ប៉ុល ពត នេះឯង ។ ដើម្បីផ្សាយទៅឲ្យឃើញថា ប្រមូលកម្លាំងដែលលែងជឿគេ មកឲ្យជឿឲ្យស្រពេចស្រពិលចំពោះឧក្រិដ្ឋកម្មរបស់គេឡើងវិញ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុននុំង ។ អត់មានឥទ្ធិពលអីក្នុងការអនុវត្តមាគ៌ានយោបាយរបស់បក្សនៅស-២១ ទេ ចុងបញ្ចប់ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

[០៩:៣១:២៥]

**ស៖** បាទ, អរគុណជនជាប់ចោទ កាំង ហ្កេកអ៊ាវ ។ តំណាងសហព្រះរាជអាជ្ញា គឺទទួលយកបាន ហើយនៅអ្វីដែលលោកបានជម្រាបជូនអង្គសវនាការ ហើយដោយមិនបាច់លម្អិតបន្ថែមទៀតទេ ។ សំណួរបន្តទៀត ចំពោះលោកនៅក្នុងទស្សនាវដ្ដីទង់បក្សបដិវត្តន៍ ដែលខ្ញុំចង់ភ្ជាប់បន្តិច ដែលចែងនៅត្រង់ទំព័រទី១៩ នោះ ។ នៅក្នុងនោះ មាននិយាយពីបញ្ហាសីលធម៌វាមានបែងចែកជាពីរយ៉ាង ។ ទីមួយ គេ

បែងចែកថា "ជាសំណល់ដែលសល់ពីសង្គមចាស់" ។ ទីពីរ គេថា "ជាផែនការរបស់ខ្មាំង" ។ សំណួរដែលចង់សួរលោកនុ៎ង មានដូចខាងក្រោម៖ ថាតើការអនុវត្តជាក់ស្តែងនូវគោលការណ៍បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ហ្នឹង ចំពោះអ្នកទោសដែលលោកបានជួបប្រទះ តើវាមានដូចការលើកឡើងរបស់គោលការណ៍បក្សកុម្មុយនីស្តកម្ពុជានៅក្នុងចំណុចនេះទេ?

[០៩:៣៣:០២]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមឆ្លើយនឹងសំណួរលោកព្រះរាជអាជ្ញាដូចតទៅ៖

បញ្ហាសីលធម៌នេះ វាជាកម្មវត្ថុមួយដែលគេយកទៅរួមផ្សំសម្រាប់ចាប់មនុស្ស ។ នេះតាមការសង្កេត វិភាគនិងសន្និដ្ឋានរបស់ខ្ញុំ ។ ឧទាហរណ៍ កុយ ធួន វាមានរឿងជាហូរហែច្រើន ចុងបញ្ចប់គាត់ទៅសីលធម៌ជាមួយប្រពន្ធគេ ហើយគាត់ទៅសម្លាប់ប្តីគេ ។ ធ្វើឲ្យល្បីល្បាញ ។ ដូច្នេះ បក្សកុម្មុយនីស្តកម្ពុជាដក កុយ ធួន តាមក្នុងលក្ខន្តិកៈបក្ខជនណាដែលប្រព្រឹត្តល្មើសត្រូវដកសិទ្ធិបក្ស ។ កុយ ធួន គាត់ជាសមាជិកកណ្តាលបក្ស សមាជិកពេញសិទ្ធិ គាត់ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មរដ្ឋ ។ តែកាលណាគេដកសិទ្ធិបក្សតាមលក្ខន្តិកៈកំណត់ហើយ ឋានៈគាត់ជាសមាជិកពេញសិទ្ធិរបស់មជ្ឈិមបក្សវារលាយ។ តួនាទីក្នុងរដ្ឋាភិបាលរបស់គាត់ ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម វារលាយ ។ ដូច្នេះ គ្រាន់តែសិលធម៌ ហើយនិងគ្រាន់តែសម្លាប់មនុស្ស ម៉េចក៏យកសមាជិកមជ្ឈិមបក្សពេញសិទ្ធិយកទៅកម្ទេច ។

[០៩:៣៤:៥០]

សូមងាកទៅនិយាយអំពីសេចក្តីសម្រេចចិត្តថ្ងៃ៣០ មីនា ១៩៧៦ ។ ថ្ងៃ៣០ មីនា ១៩៧៦ គេកំណត់ឲ្យអ្នកដែលមានសិទ្ធិសម្រេចកម្ទេចៗទៅតាមមាគ៌ាបក្សទៅទៀត តែមនុស្សបួនក្រុមទេ ។ កុយ ធួន ពេលគាត់នៅជាលេខាភូមិភាគឧត្តរ គាត់មានសិទ្ធិជម្លៀសប្រជាជន គាត់មានសិទ្ធិជ្រើសរើសមនុស្ស គាត់មានសិទ្ធិសម្រេចកម្ទេច ។ ដល់គាត់មកជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម គាត់លែងមានសិទ្ធិជាលេខាភូមិភាគហើយ ។ គាត់លែងមានសិទ្ធិកម្ទេចមនុស្ស ហើយដល់ទៅកម្ទេចមនុស្សដោយមិនសួរអចិន្ត្រៃយ៍មជ្ឈិម កម្ទេចមនុស្សខុសមាគ៌ាទៀត គេដក ។ គេដកគាត់នៅថ្ងៃ៥ មេសា ១៩-- (សូមទោស) ថ្ងៃ៨ មេសា ១៩៧៦ គេដកគាត់ ។ ដកយកទៅទុកចោលក្នុងផ្ទះ ឃុំឲ្យនៅក្នុងផ្ទះហ្នឹង ។ នេះអំពីបញ្ហាដែលខ្ញុំសង្កេត ។ ដូច្នេះ មនុស្សឲ្យតែចូលដល់ស-២១ ហើយ ការបែងចែកជាសីលធម៌តាមរបៀបខ្មាំង ឬបែងចែងជាសីលធម៌តាមប្រពៃណី អត់មានការបែងចែកទេគឺគិតធ្វើម៉េចឲ្យតែសួរចម្លើយចេញយកសេចក្តីសារភាពទៅឲ្យគេ ។ ដូច្នេះ យើងខ្ញុំអត់មានបានគិតគូររឿងបែងចែកអ៊ីចឹងទេ ។ ជាពិសេស ក្នុង

ការអនុវត្តនៅស-២១ មិនទាន់មានចាប់អ្នកណាម្នាក់ដោយរឿងសីលធម៌ទេ ។ បើតាមខ្ញុំចាំ នេះមិនទាន់ឃើញឯកសារហ្នឹងហែ នេះបើតាមខ្ញុំចាំ ខ្ញុំមិនដែលទាន់បានសម្រេចអនុញ្ញាតបក្ស ចាប់អ្នកណាម្នាក់ដោយសាររឿងសីលធម៌នៅឡើយទេ ។ នេះនៅស-២១ ខ្ញុំសូមជម្រាបអ៊ីចឹង ។ សូមចប់ ។

[០៩:៣៦:៤៧]

**ស៖** អរគុណលោក ។ សំណួរបន្តទៅទៀតរបស់ខ្ញុំ ចំពោះបញ្ហាផ្សព្វផ្សាយទស្សនាវដ្ដីទង់បក្សបដិវត្តន៍ហ្នឹងនៅមន្ទីរស-២១ ។ តើទស្សនាវដ្ដីនោះ គេបញ្ជូនមកដោយមជ្ឈិមបក្ស ឬមួយក៏លោកទៅយកវាមកផ្ទាល់ ឬក៏អាចកម្មាភិបាលដទៃទៀត គេយកទស្សនាវដ្ដីនោះមក? ទីមួយ ហើយបើសិនជាយកមក តើញឹកញាប់ទេ? ហើយក្នុងនោះដែរ ថាតើអ្នកណា អ្នកទទួលខុសត្រូវក្នុងបញ្ហាទស្សនាវដ្ដីហ្នឹងដែលយកមកផ្សព្វផ្សាយនៅមន្ទីរស-២១របស់លោក? ហើយក្នុងការរៀនសូត្រ តើអ្នកណាអ្នកអាននៅពេលប្រជុំរៀន តើអ្នកណាអ្នកអានទស្សនាវដ្ដីទង់បដិវត្តន៍ហ្នឹងដល់កម្មាភិបាលដែលនៅទីនោះ?

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសូមឆ្លើយនឹងសំណួរលោកចៅក្រមដូចតទៅ៖

ទីមួយ ទស្សនាវដ្ដីទង់បក្សបដិវត្តន៍ ខ្ញុំបានបញ្ជាក់ឃ្លូវមកហើយថា ជាទស្សនាវដ្ដីផ្ទៃក្នុងបក្ស ។ គេចែកសម្រាប់តែបក្ខជនអាន រៀនសូត្រ ផលប្រយោជន៍នៃការរៀនសូត្រទស្សនាវដ្ដីទង់បដិវត្តន៍ គឺរៀនសូត្រផ្ទាល់ពាក់ព័ន្ធទៅនឹងការងារ ។ គេលើកទឹកចិត្តខ្ញុំ ខ្ញុំលើកកទឹកចិត្តបុគ្គលិកនៅស-២១ ជាបក្ខជនឲ្យខិតខំរៀនសូត្រផ្ទាល់ ។ នេះជាបញ្ហាសំខាន់ ។ បើតាមខ្ញុំចាំ ហើយសៀវភៅកំណត់ត្រារបស់បង ម៉មណៃ ដែលចៅក្រមស៊ើបអង្កេតប្រគល់ឲ្យខ្ញុំមានកម្រាស់ជាងបីរយទំព័រ ERN នុ៎ង ក៏វាបញ្ជាក់ដែរថាយើងខ្ញុំរៀនពីអ្វីខ្លះ?

នៅស-២១ ឲ្យខ្ញុំកាន់ក្បាលមេក្រូច្រើនតែនិយាយអំពីសភាពការណ៍ អំពីរបៀបសួរចម្លើយ អំពីឧបាយកលខ្មាំង មានកំណត់ត្រានៅក្នុងនុ៎ងស្រាប់ ។ ក៏ប៉ុន្តែ គេថាឧទ្ទេសនាមពីទង់បក្សបដិវត្តន៍យើងខ្ញុំដូចនឹកមិនឃើញថា ខ្ញុំបាទបានយកចិត្តទុកដាក់ប៉ុន្មានខ្លាំងពេកទេ ។ ក៏ប៉ុន្តែ ផ្ទាល់ខ្លួនខ្ញុំរៀនខ្លាំងណាស់ហើយ ជាពិសេស លក្ខន្តិកៈបក្ស ហើយទស្សនាវដ្ដីទង់បដិវត្តន៍នេះ ខ្ញុំមើលច្រើនដែរ មិនដែលខានទេ ។ នេះរបៀបរៀនសូត្រ ។

ឥឡូវ ខ្ញុំសូមត្រឡប់ទៅសំណួរដើមរបស់លោកព្រះរាជអាជ្ញាវិញ ។ អ្នកបញ្ជូនទស្សនាវដ្ដីមកនេះ គឺបញ្ជូនមកទាន់ពេលវេលាពីអគ្គសេនាធិការ របស់អស់ហ្នឹងយើងខ្ញុំនៅវណបអគ្គសេនាធិការទេ ។ អត់មាននីរសារខ្ញុំទៅយក គឺបញ្ជូនមកជាផ្លូវការពីអគ្គសេនាធិការមក ។ រួចមកដល់ខ្ញុំឲ្យគេចាត់ចែង

ចែកចាយចំពោះបក្ខជនទាំងអស់ ។ នេះសូមជម្រាបខ្លីប៉ុណ្ណោះ សូមជ្រាប ។

**លោក តាន់ សេណារ៉ុង៖**

អរគុណ លោក កាំង ហ្គេកអ៊ាវ ។ សំណួរបន្តទៀត ពាក់ព័ន្ធនឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដដែលហ្នឹង នៅក្នុងទស្សនាវដ្ដីលេខពិសេស ដែលការិយាល័យសហព្រះរាជអាជ្ញានេះចង់ដឹងជាចុងក្រោយហ្នឹង នៅក្នុងនោះវាមានលើកជាមតិថា នៅក្នុងត្រង់ទំព័រលេខ២០ និង២១ ។

សុំអនុញ្ញាតប្រធានអង្គជំនុំជម្រះ ដើម្បីជូនឯកសារហ្នឹងមួយ ជូនទៅជនជាប់ចោទ ដើម្បីឲ្យគាត់មានពន្លឺក្នុងការឆ្លើយតបជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទទួលយកឯកសារនោះ ជូនទៅដល់ជនជាប់ចោទពិនិត្យ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** នៅក្នុងទំព័រលេខ២០ និង២១ ហ្នឹង គោលការណ៍គេបានលើកឡើងថា ជាពិសោធន៍គេថាបើកន្លែងណាខ្វះខាតស្បៀង យើងត្រូវតែរៀបចំរដ្ឋអំណាចថ្មីឡើងវិញ ។ សំណួរសួរថា តើនៅក្នុងន័យរៀបចំរដ្ឋអំណាចថ្មីឡើងវិញដើម្បីឲ្យមានស្បៀងជាថ្មីនោះ តើរដ្ឋអំណាចចាស់នោះគេចាត់ទុកជាអ្វីហើយគេយកទៅណាដែរ?

**ឆ៖** សូមគោរពលោកប្រធាន ។ ខ្ញុំសូមឆ្លើយជាមួយហ្នឹងសំណួររបស់លោកព្រះរាជអាជ្ញាដូចតទៅ៖

ខ្ញុំមើលទៅអំណះអំណាងនៅក្នុងទស្សនាវដ្ដីនេះ ត្រង់កន្លែងនេះ វាមានលក្ខណៈជាទ្រឹស្ដីសម្រាប់សម្របឲ្យសកម្មភាពឧក្រិដ្ឋរបស់គេក្នុងការកាប់កាប់រដ្ឋអំណាចពីមុន ។ រឿងនេះ វារឿងកើតនៅមូលដ្ឋានជនបទ ស-២១ក្ដាប់រឿងមិនបានជាក់ស្ដែងទេ ក៏ប៉ុន្តែ តាមគោលការណ៍ជារួមដែលកើតមានឡើងហើយនិងរឿងដោយឡែកដែលខ្ញុំដឹងខ្លះ ខ្ញុំសូមរាយការណ៍ជូនដូចតទៅ៖

ឆ្នាំ១៩៧៧ ចាប់ពីដើមឆ្នាំទៅតែម្ដង មានការសម្រិតសម្រាំងកម្មាភិបាលចាស់ នៅភូមិភាគឧត្តរ គឺដែលក្រោយមកគេប្រែឈ្មោះថា ភូមិភាគកណ្ដាលនោះ ។ ទាំងខ្ញុំទាំងគេ ជាពិសេសអចិន្ត្រៃយ៍មជ្ឈិមដែលធ្វើជាមេខ្ញុំ គឺលោកគ្រូ សុន សេន ហ្នឹងគាត់ជឿថា ដល់កាលណាសម្រិតសម្រាំងកម្មាភិបាលចាស់ដែលក្បត់របស់អាឃ្លួនទៅ ប្រជាជនកម្ពុជានៅខាងណោះពិត ជានឹងមានបាយហូបគ្រប់គ្រាន់ ។ នេះជារឿងដែលសង្ឃឹមទូទៅ ។

[០៩:៤៣:៥៦]

ខ្ញុំសូមនិយាយពីផ្ទាល់ខ្លួនខ្ញុំដែលដឹង។ ម្ដាយខ្ញុំគាត់ឧស្សាហ៍អញ្ជើញមកភ្នំពេញ គាត់អញ្ជើញមកកូនបីនៅភ្នំពេញ កូនពីរនៅកំពង់ធំ ។ អ៊ីចឹង សំខាន់មែនទែនគាត់ព្រួយនឹងខ្ញុំ ខ្លាចខ្ញុំត្រូវគេចាប់ចង ម្ល៉ោះហើយមកញឹកណាស់ មកដល់ខ្ញុំសួរម៉េចម៉ែរឿងហូបចុក គាត់មានប្រសាសន៍ប្រាប់ខ្ញុំ ខ្ញុំរាយការណ៍ជូនមេ ខ្ញុំថា អ៊ំរបង នៅឧត្តរកម្មាភិបាលបង្អត់បាយប្រជាជន មេខ្ញុំឆ្លើយពីម្ខាងទូរស័ព្ទមក អាហ្នឹងមកពីខ្មាំងវាបង្អត់បាយប្រជាជន មិនមែនកម្មាភិបាលយើងបង្អត់បាយប្រជាជនទេ មិត្តត្រូវច្បាស់ បន្តិចទៀតវាភ្លឺស្វាងហើយបញ្ហា ។ ដល់កម្មាភិបាលតាម៉ុក ទៅ មិនមែនប្រជាជនត្រឹមតែអត់បាយទេ ឪពុកខ្ញុំត្រូវឈ្មោះ ឈុំ បង្ខំឲ្យទៅរកផ្ដៅសោមមកចងកណ្ដាប់ស្រូវ ហើយទំនៀមទម្លាប់ស្រុកស្ទោង ទៅរកផ្ដៅសោមឯណាមកចងកណ្ដាប់ស្រូវ ខ្ញុំវាហួសចិត្ត ហើយបាយកាន់តែអត់ឡើង ។ ដល់ពេលខ្ញុំជួបមេ ពេលនោះម្ដាយខ្ញុំ គាត់អញ្ជើញទៅលេងដែរ ពេលខ្ញុំជួបលោកគ្រូ សុន សេន ខ្ញុំជម្រាបគាត់ទៀតថាបង១១ពួកឧត្តរ ពួកតាម៉ុកទៅ ប្រជាជនកាន់តែអត់បាយខ្លាំងឡើង ហើយឪពុកខ្ញុំត្រូវគេបញ្ជាឲ្យរកផ្ដៅសោមឲ្យទៅចងកណ្ដាប់ស្រូវឯម៉េច មេខ្ញុំអត់ឆ្លើយរួចនៅស្ងៀម នាំខ្ញុំជជែកទៅរឿងឯណាផ្សេងទៀតទៅ ។

ដូច្នេះ រឿងចាប់ គេចាប់ រឿងរកហេតុផលស្អី ដើម្បីសម្រេបការចាប់របស់គេ ជាអធិកអធមបែបនេះគេចេះតែរកហើយ ។ ដូច្នេះ ទស្សនាវដ្ដីនេះ ដែលនិយាយបែបនេះ ខ្ញុំជឿថា វាមានលក្ខណៈទ្រឹស្ដី ជាជាងវិភាគសភាពការណ៍ ហើយរកសេចក្ដីសន្និដ្ឋានមួយដែលមានលក្ខណៈវិទ្យាសាស្ត្រ ដើម្បីដោះស្រាយជីវភាពប្រជាជនពិតប្រាកដ ។ ពួក តាម៉ុក ទៅប្រជាជនកាន់តែអត់បាយថែមទៀត នេះជាក់ស្ដែង នេះសូមជម្រាបអ៊ីចឹង នេះតាមការសង្កេតរបស់ខ្ញុំ ដោយផ្ទាល់និងដោយប្រយោល ។

**ស៖** អរគុណលោក ។ ការិយាល័យសហព្រះរាជអាជ្ញា អាចទទួលយកបាននូវចំណុច ដែលលោកបានពន្យល់ត្រួសៗនូវបញ្ហានេះ ។ សំណួរបន្តទៀត ចំពោះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះលោក ដែលអនុវត្តចំពោះអ្នកទោស ដែលបានចាប់ហើយបញ្ជូនមកមន្ទីរស-២១ហ្នឹង ថាតើជាគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង គេត្រូវរក្សាទុកអ្នកទោសយ៉ាងឆាប់ ហើយនិងយ៉ាងយូរហ្នឹងរយៈពេលប៉ុន្មានដែរ? ទីមួយ វាមានអ្នកទោស វាអាចជាយុទ្ធជនបដិវត្តន៍កម្ពុជាហ្នឹង ។ ទីពីរអ្នកទោសជាកម្មាភិបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ទីបី វាមានបញ្ញវន្តដែលមកពីបរទេស ។ និងទីបួន ប្រជាជនធម្មតា ដែលថាជាខ្មាំងស៊ីរូងផ្ទៃក្នុង ។ តើលោកយល់សំណួរបានទេ?

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោកព្រះរាជអាជ្ញាដូចតទៅ៖

មនុស្សដែលគេចាប់ មកចូលមន្ទីរស-២១ ហើយ គេចាត់ទុកជាខ្មាំងទាំងអស់ត្រូវតែកម្ទេច ។ នេះជាគោលការណ៍ដែលអ្នកណាមិនអាចអ្នកណាល្មើសបាន គេអត់គិតដល់ប្រភពដើមជាបញ្ញាជនស្លូតត្រង់ស្អីទេ ទោះបីជាបញ្ញាជននោះអត់មានបាតដៃប្រឡាក់ឈាមមនុស្សសោះក៏ដោយ ក៏គេចាត់ទុកដូចជាកម្មាភិបាលម្នាក់ដែលប្រឡាក់ឈាមប្រជាជនដែរ ។ យើងប្រៀបធៀបមើលចុះ កុយ ធួន ប្រលាក់ឈាមប្រជាជន ហើយប្រៀបធៀបទៅនឹងដុកទ័រ រ័ត្ន គត់ បងធម៌ខ្ញុំ ប្រៀបធៀបជាមួយហ្នឹង លោកសាស្ត្រាចារ្យ ភីន តុន តើអ្នកណាល្អជាងអ្នកណា? តើអ្នកណាបាតដៃប្រលាក់ឈាមប្រជាជន? គេអត់បែងចែកអញ្ចឹងទេ សូមជម្រាប ។ ឲ្យតែខ្មាំង គេចាប់ ចាប់មកស្វ័យប្រវត្តិស-២១ ត្រូវតែសួរចម្លើយមានទារុណកម្ម ឬគ្មានទារុណកម្ម តាមដាក់ស្លែងចុងបញ្ចប់អស់ហើយត្រូវបញ្ជូនយកទៅកម្ទេចនៅជើងឯក ។ ពាក្យដក ពាក្យបញ្ចេញ ពាក្យកម្ទេច ពាក្យវាយចោល ប្រើដូចគ្នាពេលនោះ ។ ប៉ុន្តែ ជាទូទៅគេប្រើពាក្យកម្ទេច ។ នេះអត់ប្រកែក ត្រូវតែអនុវត្តអ៊ីចឹង ។

[០៩:៤៩:៥១]

ដោយឡែកនៅស-២១មានប្រភេទពីរ ។ ប្រភេទទីមួយ ជាងគូរជាងឆ្លាក់ ដែលយើងខ្ញុំបានខ្នះខ្នែងសុំអនុគ្រោះ បក្សកុម្មុយនីស្តកម្ពុជាសុំអនុគ្រោះឲ្យនៅត្រឹមតែអ្នកទោសដែលមិនត្រូវសម្លាប់មានគ្នាប្រាំនាក់ ។ ក្រៅពីនោះ មានម្នាក់គឺទន្តពេទ្យ ឌី ផុន បងប៉ុល ឲ្យគេចាប់ប្រគល់មកឲ្យស-២១ បានម៉ៃពីរគាត់ឲ្យពូនួន មកប្រាប់វិញ ហៅខ្ញុំយកទៅប្រាប់ថា ឌី ផុន មិត្តកុំវ៉ៃ ទុកប្រើទៅ ឲ្យជាលក្ខណៈអ្នកទោសដែលមិនត្រូវសម្លាប់ទៅ ទាំងអស់ប្រាំមួយនាក់ ។ នេះវាបញ្ជាក់ថា ឲ្យតែខ្មាំងត្រូវតែកម្ទេច យ៉ាងច្រើនណាស់បានត្រឹមទុកឲ្យនៅជាអ្នកទោសដែលគេមិនកម្ទេចប៉ុណ្ណឹងឯង ។ នៅស-២១ ទាំងមូលយើងខ្ញុំបានឃើញប្រាំមួយនាក់នេះ ដែលរួចជីវិត ដែលត្រូវរួចជីវិត ក្រៅពីនោះទាំងអស់ ។

ដោយឡែក នៅមន្ទីរ១៣ មានម្នាក់ដែលគេទុកឲ្យជាខ្មាំងនៅរួចជីវិតអ៊ីចឹងគឺ ហាម អ៊ីន ហើយក្រៅពីនោះ យើងខ្ញុំដោះលែងបានប្រាំមួយនាក់ មែនមុនដំបូងខ្ញុំអត់ស្ងួរយល់ តាមពិតតាមការរំឭកឡើងវិញ អ្នកប្រាំបីនាក់នោះដូច ហ្វ្រង់ស្វ័រ ប៊ីហ្សូ អី យើងខ្ញុំជជែកជាមួយនឹងគេអំពីរឿងមិនមែនជាខ្មាំងគេយល់ស្របថា មិនមែនជាខ្មាំងមែន របៀបបង អ៊ុច ស៊ន ដែលមកធ្វើសាក្សីនៅទីនេះ សាក្សី KW30 នោះ ។ គេយកទៅទុកឲ្យឃើញគុកច្រវាក់ ខ្នោះឃ្នាង ឃើញរបៀបសួរចម្លើយ របៀបកម្ទេចហើយគេបញ្ជូនឲ្យទៅនៅមជ្ឈដ្ឋានផ្សេងទៅ ដែលមិនមែនជាមជ្ឈដ្ឋាននេះខ្លួនឯង ។ អាហ្នឹង មិនមែនគេទុកជា

ខ្លាំងទេ គេទុកជាប្រជាជនដែលមានកំហុសធ្ងន់ នេះខ្ញុំមានច្របូកច្របល់បន្តិចហើយ ។ ប្រជាជនដែលមានកំហុសធ្ងន់ គេធ្វើរបៀបបង អ៊ុច ស៊ីន អ៊ីចឹង គេយកមកឲ្យឃើញគុក ឲ្យខ្មោះ ឲ្យឃើញការសម្លាប់ ហើយគេនិរទេសទៅកន្លែងផ្សេង ទៅភូមិស្រុកផ្សេងក្រៅពីមជ្ឈដ្ឋានសេពគប់ចាស់ ។

[០៩:៥២:១៦]

សរុបមក អានេះរឿងនេះទុកមួយឡែកណាស់ និយាយពីរឿងឲ្យតែខ្លាំងគេចាប់បញ្ជូនមកស-២១ហើយ ត្រូវតែវ៉ៃ ត្រូវតែសួរ ត្រូវតែមានទារុណកម្ម ត្រូវតែសួរ មានទារុណកម្មភាគច្រើន ហើយត្រូវតែយកទៅកម្ទេចឲ្យគេ ស-២១ ដោះលែងអត់បានទេ ដោះលែងកំបុងក ។ នេះសូមបញ្ជាក់ប៉ុណ្ណឹងអំពីមាគ៌ា ។

**ស៖** អរគុណលោក ប៉ុន្តែ លោកហាក់ដូចជាពុំបានឆ្លើយនូវសំណួររបស់ខ្ញុំថា ពីរយៈពេលតើលោកអាចបញ្ជាក់ឡើងវិញបានទេ? យ៉ាងឆាប់ ហើយនិងយ៉ាងយូរ?

**ឆ៖** អរគុណដែលលោកបានសួរបញ្ជាក់ ខ្ញុំពិតជាបានរំលងបញ្ហានេះមែន ព្រោះក្នុងការអនុវត្តរយៈពេលនេះអត់មានកំណត់ជាក្រឹត្យក្រម ជាគោលការណ៍មកទេ អ្នកណាសំខាន់យើងទុកយូរបន្តិចទៅទាល់តែខាងលើគេថា ទៅអាហ្នុងយកទៅ បានហើយប៉ុណ្ណឹងបានហើយ ហ្នឹងក៏យើងយកទៅ ។ ឯចំណែក អ្នកណាខ្លះដែលមិនសំខាន់ ក៏យកទៅប្រូសៗ ឧទាហរណ៍ នៅក្នុងបញ្ជី 159/4.10 មនុស្សមួយរយនាក់ចូលមកដល់ថ្ងៃ២៣ ខែ១១ ខ្ញុំបញ្ជាឲ្យ មិត្តហ៊ា តាមសេចក្តីរបស់បក្សពីខាងលើឲ្យបញ្ចេញឲ្យដក គេដកផុតនៅថ្ងៃ០២ ធ្នូ ១៩៧៧ អត់ទាំងបានសួរផង ។ ដូច្នេះ កំណត់ជាគោលការណ៍ឲ្យជាក់លាក់ចំពោះបញ្ហាខ្លាំងប្រភេទណាប៉ុន្មានថ្ងៃគេអត់កំណត់ទេ វាទៅតាមការជាក់ស្តែងដែលប្រែប្រួលពីមួយលើកទៅមួយលើក ។ នេះសូមបញ្ជាក់ដោយស្មោះត្រង់អញ្ចឹង ។

**ស៖** អរគុណលោក ។ លោកហាក់ដូចជាពុំបានឆ្លើយនូវអាររយៈពេល ថាតើខែដែលលោកដែលខ្ញុំចង់បាននោះ ថាតើអាចមួយខែ ពីរខែ ប្រាំមួយខែ តើលោកបានបញ្ជាក់ចំណុចហ្នឹងបន្តិចបានទេបាទ?

[០៩:៥៥:00]

**ឆ៖** អរគុណៗ ។ ក្នុងបញ្ជី159/4.10 នេះតែ១០ថ្ងៃទេ លោកព្រះរាជអាជ្ញាមើលចុះភស្តុតាងនៅសល់១០ថ្ងៃទេ អ្នកខ្លះរាប់ខែ ដូច កុយ ធួន មិនដឹងប៉ុន្មានខែទេ ខ្ញុំភ្លេចអស់ទៅហើយ អ្នកខ្លះរាប់ខែ ។ ដូច្នេះវាប្រែប្រួលទៅតាមសភាពការណ៍ អីនៅក្នុងបញ្ជី 159/4.10 នេះ ១០ថ្ងៃទេ ។ លោកមើលចុះ ។

**ស៖** អរគុណលោក ជាគោលការណ៍តំណាងសហព្រះរាជអាជ្ញាអាចទទួលយកបាន ប៉ុន្តែនឹងពិភាក្សាលម្អិតនៅពេលក្រោយទៀត នៅពេលដែលចូលដល់ប្រតិបត្តិការនីមួយៗ ។

សំណួរបន្តទៅជូនលោក នៅក្នុងកថាខណ្ឌលេខ៥៨ នៃអង្គហេតុដែលលោកបានព្រមព្រៀងនៅក្នុងនោះវានិយាយតួនាទីចម្បងរបស់មន្ទីរស-២១ ដែលអនុវត្តគោលនយោបាយចំពោះខ្មាំង ដែលលោកៗក៏បានឯកភាពដែលថា អ្នកទោសទាំងអស់ត្រូវតែកម្ទេចដាច់ខាត ។ តើនៅក្នុងន័យនេះ ចង់ឲ្យលោកបញ្ជាក់ឡើងវិញបន្តិច ថាតើអ្នកទោសចាត់ទុកជាខ្មាំងនុ៎ង វាៗអាច--វាៗ សំណួនេះ ហាក់ដូចជាដដែលឡើងវិញដែរ ។ ប៉ុន្តែ គ្រាន់តែលោកសង្ខេបខ្លីៗបានហើយ ថាតើបក្សចាត់ទុកជាខ្មាំងនោះ មានវាសកម្មភាពអីខ្លះ នៅក្នុងអង្គហេតុព្រមព្រៀងកថាខណ្ឌលេខ៥៨ នុ៎ង? សូមខ្លីៗបានហើយ ។

**ឆ៖** កថាខណ្ឌលេខ ៥៨ --

**ស៖** ៥៨

**ឆ៖** របស់ស្អីៗ ។

**ស៖** របស់អង្គហេតុ ដែលបានព្រមព្រៀង ។

**ឆ៖** អ៊ំៗ ខ្ញុំមិននឹកឃើញដល់កថាខណ្ឌនេះទេ ។ សូមមេត្តាអាន មិនចាំបង្ហាញទេ ។

**ស៖** នៅក្នុងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសនៅមន្ទីរស-២១ ហ្នឹង ពីគោលនយោបាយកម្ទេចខ្មាំង ។ តួនាទីជាចម្បងរបស់មន្ទីរស-២១ គឺអនុវត្តគោលមាគ៌ាបក្សចំពោះខ្មាំង ដែលតាមរយៈមាគ៌ានេះ អ្នកទោសត្រូវតែកម្ទេចជាដាច់ខាត ។ កថាខណ្ឌទី៣១ របស់ដីកាដំណោះស្រាយ ក្នុងនេះលោកថា យល់ព្រម ។

**ឆ៖** ឥឡូវ សូមបញ្ជាក់សំណួរបន្តិចមក ។ សូមលោកព្រះរាជអាជ្ញាមេត្តាៗ បញ្ជាក់សំណួររបស់លោកឲ្យម្តងទៀត សូមទោស ។

**ស៖** ថាតើអ្នកទោសដែលបក្សចាត់ទុកជាខ្មាំង នៅក្នុងកថាខណ្ឌហ្នឹង តើវាបានធ្វើសកម្មភាពអ្វីខ្លះ? សូមបញ្ជាក់តែខ្លីៗបានហើយ ។

**ឆ៖** សូមគោរពលោកប្រធាន! សូមអរគុណ លោកព្រះរាជអាជ្ញា ដែលបានលោកបង្ហាញឯកសារ ហើយនឹងលើកសំណួរម្តង ឲ្យកាន់តែច្បាស់ ឲ្យខ្ញុំបានឆ្លើយស្រួល ។ សូមអរគុណ ។

សេចក្តីសម្រេចចិត្ត ថ្ងៃ៣០ មីនា ១៩៧៦ វាកំណត់ហើយ ក្របខ័ណ្ឌនៃអ្នកដែលមានសិទ្ធិសម្រេចកម្ទេច គឺពួកនុ៎ងឯង ដែលគេសម្រេចថា អ្នកណាជាខ្មាំង ។ បើអាមួយក្នុងចំណោមអាប្អូនក្រុម

ហ្នឹង វាសម្រេចហើយ នគរបាលមិនចាប់មិនបាន អង្គភាពដើមមិនចាប់មិនបានទេ ត្រូវតែចាប់ ។ អ្នកណាឲ្យរត់រួច អ្នកនោះត្រូវមានទោស មកដល់ស-២១ ហើយ ត្រូវតែសួរចម្លើយឲ្យបានឲ្យគេជាមូលដ្ឋាន ខ្ញុំមិននិយាយថាគ្រប់មនុស្សទេ ខ្ញុំនិយាយថាជាមូលដ្ឋាន ។ ដូច្នេះមកដល់ស-២១ ហើយ ត្រូវតែសួរចម្លើយឲ្យគេឲ្យបានជាមូលដ្ឋាន រួចហើយត្រូវយកទៅកម្ទេចឲ្យគេ កុំឲ្យសល់ កុំលួចដោះលែង អ្នកឯងហ៊ានតែលួចដោះលែង គឺអ្នកឯងត្រូវតែប្រឈមមុខជាមួយនឹងបក្ស បានន័យថា អ្នកឯងមានទោស ។

[០៩:៥៩:៣៣]

សរុបមក មូលហេតុស្អីបានជាគេសម្រេចចាប់ អាប្អូននាក់ហ្នឹងវាអ្នកសម្រេច អំណាចនៅលើវាគ្មានអ្នកណាសម្រេចបានទេ។ អាប្អូនក្រុម មិនមែនអាប្អូននាក់ទេ អាប្អូនក្រុមហ្នឹងអ្នកសម្រេច ដូច្នេះអត់មានអ្នកណាទៅសម្រេចបានទេ ។ ស-២១ សម្រេចមិនបាន លេខាកងពលសម្រេចមិនបាន សូម្បីតែរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដូចខ្ញុំបានរាយការណ៍ជូនអំមិញហ្នឹង សម្រេចអត្តនោម័តិទៅតាមផលប្រយោជ៍អ្នកឯងត្រូវគេចាប់ ។ ដូច្នេះ មូលហេតុស្អីៗ ស-២១ ពិបាកពន្យល់ គេៗអ្នកសម្រេច ហើយនៅក្នុងសេចក្តីសម្រេចចិត្ត ថ្ងៃ៩ តុលា ១៩៧៥ នៅពេលដែលនិយាយអំពីករណី មាន មាននេះ គឺចាន់ ចក្រី ហើយនិង សួ សុផាន ។ ប៉ុល ពត និយាយថា យើងកុំជឿចម្លើយខ្មាំងពេក យើងជឿតាមខ្សែយើង។ ដូច្នេះ គេវិភាគនៅក្នុងគ្នាគេនុ៎ងហើយ យ៉ាងម៉េចៗ ច្បាស់ ។

[១០:០០:៤៦]

សរុបមកវិញ ខ្ញុំសង្ខេបចម្លើយដែលខ្ញុំឆ្លើយជូនលោកព្រះរាជអាជ្ញាថា ស-២១ មិនយល់អំពីមូលហេតុជាចំពោះ ដោយឡែកៗ របស់បុគ្គលណាមួយ ដែលអចិន្ត្រៃយ៍ ដែលពួកក្រុមប្អូននាក់វាសម្រេចនោះ សម្រេចចាប់ទេ គឺគេសម្រេចឯករាជ្យពីយើង គេជាអ្នកមានអំណាចធំ គេសម្រេចហើយ គេបញ្ជាឲ្យយើងអនុវត្ត របបការសួរចម្លើយ ហើយនិងកម្ទេច ។ នេះសូមបញ្ជាក់ប៉ុននេះ ។

**ស៖** អរគុណលោក ។ សហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញា ចាត់ទុកថាទទួលយកបានចុះ ។ ខ្ញុំសូមបន្តសំណួរបន្តទៀត ពាក់ព័ន្ធទៅនឹងសកម្មភាព និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង ដែលវាពាក់ព័ន្ធទៅដល់ទារក ឬក្មេងៗតូចដែលយកមកតាម ដែលមានជាប់មកជាមួយម្តាយ ហើយដែលបក្សបានសម្រេចថា ចាប់ខ្លួននុ៎ង តើជាទិសដៅរបស់បក្សកុម្មុយនីស្តកម្ពុជានុ៎ង យល់ឃើញដូចម្តេចដែរ ថាពួកគេនឹងមានសកម្មភាពអីដែរ ហើយខុសអីដែរ បានជាសម្រេចយកកូន និងទារកតូចៗដែលមកតាមខ្លួននុ៎ងមកដែរ?

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសូមឆ្លើយនឹងសំណួរព្រះរាជអាជ្ញា ដូចតទៅ៖

ដើម្បីយល់បញ្ហានេះ ចាំបាច់ត្រូវមើលសភាពការណ៍ដែលយើងខ្ញុំជាអ្នកអនុវត្តបទបញ្ជាគេ កាលនៅអមលាំង នៅម-១៣ ។ នៅមន្ទីរ១៣ មុនដំបូងយើងខ្ញុំទាមទារ សុំដកក្មេងស្រីជំទង់ម្នាក់ ឈ្មោះនាងស៊ុស ណាស ។ ហ្រ្វង់ស័រ ប៊ីហ្សូ ក៏គាត់មាននិយាយនៅក្នុងសៀវភៅគាត់ អំពីនាងហ្នឹងដែរ ។ ខ្ញុំតស៊ូស្វិតស្វាយជាមួយនឹង ឆាយ គឹមហ៊ុរ ។ ឆាយ គឹមហ៊ុរ គាត់ថា ប្រយ័ត្នសងសឹកណាស់ មិត្ត ឌុច មិត្តគិតឲ្យមែនទែន ខ្ញុំមើលតស៊ូមតិជាមួយនឹងបង គឹមហ៊ុរ មិនបាន ខ្ញុំស្ទុះទៅដល់បង វន គឺ វ៉ន វេត ហ្នឹង បងវន ឲ្យខ្ញុំដោះលែង ក៏ប៉ុន្តែបញ្ហាចោទ តើត្រូវយកទៅប្រគល់ឲ្យអង្គភាពណា? នៅពេលដែលចោទ ថាត្រូវយកទៅប្រគល់អង្គភាពណានោះ? បានត្រូវនាងនុំង នៅនុំង ជាមនុស្សអត់ទោស ។ ពេលហ្នឹងហើយ ហ្រ្វង់ស័រ ប៊ីហ្សូ គាត់ទៅឃើញ ។ ដល់ក្រោយមក បានខាងឃុំអមលាំង គេសម្រេចថាយកឲ្យទៅនៅនារីឃុំ ជាមួយនឹងបង ខៀវ ស្រីម្នាក់ឈ្មោះយាយ ខៀវ ទៅ ខ្ញុំក៏យកទៅ ។ នេះលើកទីមួយ។ ដល់លើកពីរ ខ្ញុំសាកល្បងចិញ្ចឹមកូន ឲ្យគេថែរក្សាកុមារតូចៗរបស់មនុស្សម្នាក់ ឈ្មោះ សាំង អ៊ុន ។ មនុស្សហ្នឹង មិនដឹងជាស្អី ល្អើកសឹក ឬស្អីម៉េចទេ? ហើយតាមចាំនេះដូចជា-- នេះទេ ខ្ញុំឲ្យគេអ៊ីចឹង បីនាក់ កូនរបស់ សាំង អ៊ុន ចិញ្ចឹមមិនរស់ ។ ពេលនុំងមេខ្ញុំ លោកគ្រូសុន សេន គាត់ជ្រាបដែរ ដល់ចិញ្ចឹមមិនរស់ ខ្ញុំប្រាប់ថា អូ្ហ! ចិញ្ចឹមក្មេងពិបាកណាស់បង មិនមែនគ្រាន់តែអាហារហើយនិងអនាម័យទេ វាទាមទារមនោសញ្ចេតនាថែមទៀត ពេលហ្នឹងហើយ ដែល សុន សេន គាត់ថាហ្នឹងហើយ ឌុច មានពិសោធន៍ទៅ មិត្តទុកក៏អត់ចំណេញដែរ ។ ថ្ងៃក្រោយវាសងសឹក នេះចាំណាំ ជំហរវណ្ណៈមិត្តត្រូវពង្រឹងឡើង ពីពេលហ្នឹងហើយដែលខ្ញុំសុខចិត្តចាញ់លោកទស្សនៈរបស់បក្សកុម្មុយនីស្តកម្ពុជា ឲ្យតែក្មេងចូលទៅដល់ ខ្ញុំក៏កម្ទេចដោយបញ្ហាគោលការណ៍របស់បក្សខ្លាចសងសឹក ។ នៅស-២១ អត់មានរឿងហ្នឹងតទៅទៀតទេ គឺខ្ញុំចុះចាញ់លោកទស្សនៈរបស់គេរួចទៅហើយ ខ្ញុំសុខចិត្តទទួលអនុវត្តលោកទស្សនៈរបស់បក្សកុម្មុយនីស្តកម្ពុជាទៅហើយ ។ នេះចំពោះកុមារ និងទារក ឧក្រិដ្ឋកម្មនេះ ខ្ញុំទទួលទាំងស្រុង មិនឆ្លើយទម្លាក់ថា មកពីគេទាំងស្រុង គឺក្នុងនុំងក៏វាមានខ្ញុំដែរ ខ្ញុំចុះចាញ់ទស្សនៈគេរួចទៅហើយនេះសូមបញ្ជាក់អ៊ីចឹង ។

[១០:០៥:៥២]

**ស៖** សំណួរបន្តចំពោះលោក ដូចលោកធ្លាប់បានបញ្ជាក់ហើយ ថានៅក្នុង KW01 ដែលលោកបានលើកឡើងអម្បាញ់មិញ ថាត្រូវបានទុកប្រើមួយរយៈ ក្នុងនោះវាមានការសាងសង់រូបបដិមាករ វា

នៅវត្តភ្នំជាដើម ។ នៅក្នុងនោះ វាមានសាក្សីម្នាក់ដែលមាននៅក្នុងអក្សរកាត់ គេសរសេរថា CP1/6 និងប្អូនប្រុសរបស់ខ្លួន ដែលនៅពេលនោះ ពួកទាំងនោះជាក្មេងៗ ចុះហេតុអ្វីបានជាពួកអស់ទាំងនោះ និងក្មេងនោះ មិនត្រូវបានសម្លាប់ ដូចលោកបានលើកឡើងនៅក្នុងមន្ទីររបស់លោក?

**ឆ៖** សូមគោរពលោកប្រធាន ។ ខ្ញុំរក-- (សុំទោស) ខ្ញុំសូមឆ្លើយជាមួយនឹងលោកសហព្រះរាជអាជ្ញា ដូចតទៅ៖

ខ្ញុំរកប្រភពដើមរបស់ CP1/6 នេះមិនឃើញ ។ មិនដឹងជាឪពុកគាត់ឈ្មោះអី ម្ដាយគាត់ឈ្មោះគាត់អី មកពីអង្គាល់ អត់រកឃើញទេ នឹងជម្រាបឲ្យត្រង់ ។ ដូច្នេះ ប្រភពដើមរបស់ CP1/6 នេះ ខ្ញុំរកមិនឃើញ ។ បើប្រភពដើម D25/5 -- អ៊ូ! /6 អ៊ីចេះមិនដឹង ខ្ញុំរកឃើញប្រភពដើម ។ សូមបញ្ជាប់ប៉ុនណេះ ខ្ញុំរកប្រភពដើមងរបស់ CP1/6 រកមិនឃើញទេ មិនដឹងមនុស្សហ្នឹងជាស្អី ជាពីណាមកទេ ខ្ញុំសូមជម្រាបអ៊ីចឹង អត់ច្បាស់ ។

**ស៖** អរគុណលោក ។ អ៊ីចឹងតំណាងសហព្រះរាជអាជ្ញាសូមបន្តទៀតចុះ ហើយនិងទុកលើកយកបញ្ហាហ្នឹង ហើយជូននូវប្រវត្តិនៃការចាប់ខ្លួនរបស់ឪពុករបស់CP1/6 ហ្នឹង នឹងបង្ហាញជូនលោកនៅពេលក្រោយបន្ទាប់ នៅប្រតិបត្តិការបន្ទាប់ទៀត ។ អរុគណលោក ។

សំណួរបន្តទៀតជូនលោក សួរថាក្មេងៗជាពិសេសក្មេងៗ ចង់ការិយាល័យសហព្រះរាជអាជ្ញាចង់លើកឡើងថា បើនិយាយពីក្មេងៗបានន័យថាចាប់ពីប្រាំពីរឆ្នាំចុះ បើនិយាយពីទារកថា វានៅនឹងដៃរបស់ម្ដាយចុះ ។ ថាតើក្មេងៗនិងទារក ភាគច្រើនដែលគេយកចូលមកនៅក្នុងមន្ទីររបស់លោកនុ៎ង តើគេសម្លាប់នៅជើងឯក គេយកទៅជើងឯក ឬក៏នៅកន្លែងណាមួយនៃមន្ទីររបស់លោក?

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោកព្រះរាជអាជ្ញាដូចតទៅ៖

រឿងល្អិតខ្ញុំសូមជម្រាបថា ខ្ញុំក្ដាប់មិនបានទេ ។ រឿងរួម ខ្ញុំដឹងថាខ្ញុំពិតជាមានទោសឧក្រិដ្ឋទៅលើការប្រហារជីវិត កុមារតូច កុមារធំ ហើយនិងក្មេងជំទង់ អនិតិជនទាំងអស់ ។ ខ្ញុំដឹង ។ ឆ្លងតាមការដែលទៅ កុងហ្វ្រង់តេ អាតទល់គ្នាពីលើកមុននោះ ជាមួយនឹងសាក្សី ជាមួយអីហ្នឹង ខ្ញុំឃើញមានញគេទុកមួយកន្លែង នៅជុំវិញស-២១ដែរ ហើយមួយកន្លែងទៀត គេយកទៅឯខាងជើងឯក ។ រូបភាពឧក្រិដ្ឋដែលគេថាសម្លាប់ក្មេងដោយវាយក្បាលនឹងគល់ឈើ ខ្ញុំអត់ឃើញទេ ហើយជំនាន់នុ៎ង ខ្ញុំក៏អត់ដឹងដែរ ក៏ប៉ុន្តែដល់ឮពាក្យខ្ញុំជឿថា ខ្ញុំទទួលបាន គឺពិតជាកូនចៅខ្ញុំជ្រើមទៅអ៊ីចឹងមែន ។ ខ្ញុំទទួលរូបភាពបែបហ្នឹង ក៏ប៉ុន្តែរូបភាពមួយទៀត គេថាបោះក្មេងពីលើមកណា ពីលើអាជាន់ទីបី ខ្មែរយើងហៅជាន់ទី

បីហ្នឹង បាវាំងគេហៅ *ឌីហ្សៀមអេតា* ។ ខ្ញុំមិនជឿៗ ព្រោះម៉េចបានមិនជឿ? ពីព្រោះគ្មានអ្នកណាប៉ាន ទៅសម្លាប់អីអាឡារិកឲ្យអ្នកទោសផ្សេងទៀតដឹងបែបនេះទេ ។ នេះជារឿងមួយដែលខ្ញុំមិនជឿ ។

សរុបមកវិញ កន្លែងសម្លាប់នៅជើងឯកមាន កន្លែងសម្លាប់នៅស-២១ មានរូបភាពឧក្រិដ្ឋដែល មហាសាហាវបោកក្បាលក្មេងសម្លាប់នឹងគល់ឈើ ខ្ញុំជឿថាមាន កូនចៅខ្ញុំគេពិតជាធ្វើអីចឹង ។ ក៏ប៉ុន្តែ ខ្ញុំមិនឆ្លើយដាក់គេទេ ក៏ប៉ុន្តែឧក្រិដ្ឋបែបនេះ ក៏ខ្ញុំនៅតែទទួលចំពោះមុខមនុស្សជាតិ ថាជាឧក្រិដ្ឋកម្មមួយ ដែលខ្ញុំបណ្តោល នេះសូមបញ្ជាក់ ។

**ស៖** អរគុណលោក ។ សំណួរបន្តទៀតជូនលោក ដែលពាក់ព័ន្ធនឹងរឿងកុមារដែលថា មូល ហេតុអ្វីបានជាកុមារនិងក្មេងតូចៗហ្នឹង មុននឹងកម្ទេចហើយភាគច្រើនដូចជាពុំមានថតរូប? សំណួរហ្នឹង វាអាចលើកមុនដូចដែលខ្ញុំ តាមខ្ញុំចាំ ខ្ញុំប្រហែលជាបានសួរម្តងហើយ ប៉ុន្តែ ឥឡូវសូមបញ្ជាក់បន្តិចដែល ពាក់ព័ន្ធជាមួយកុមារហ្នឹង ថាភាគច្រើនពុំសូវឃើញមានរូបថត មូលហេតុអ្វីបានជាពុំសូវមានរូបថត?

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំសូមឆ្លើយនឹងសំណួរនេះដូចតទៅ៖

ខ្ញុំពិតជាទទួលខុសត្រូវនូវឧក្រិដ្ឋកម្មលើកឧក្រិដ្ឋកម្មនៅស-២១ ទាំងអស់ ក៏ប៉ុន្តែចូលកិច្ចអនុវត្ត ល្អិត ខ្ញុំនៅឆ្ងាយបន្តិចដែរ មិនអាចពន្យល់ជូនលោកបានទេ ។ ដូច្នេះ រឿងថតឬមិនថត ខ្ញុំមានឃើញមាន នូវរូបថតខ្លះ ហើយខ្ញុំជឿថា មួយចំនួនធំមិនបានថតមែន ។ ដូច្នេះ កិច្ចអនុវត្តល្អិតវាស្រេចនៅលើគេខាង ក្រោមទ ខ្ញុំដឹងថាធ្វើម៉េចកុំដោះលែងរបស់ខ្ញុំ ។ ដោះលែងអ្នកណាម្នាក់យើងងាប់ទាំងអស់គ្នាណាមិត្ត ហ៊ ណា ។ គ្មានអ្នកណាប៉ានដោះលែងទេ។ ដូច្នេះ ខ្ញុំដឹងតែប៉ុណ្ណឹង ដឹងថាម៉េចកុំឲ្យគេដោះលែង ។ ដោះលែងកំបុតកទាំងអស់គ្នា រឿងគេថត ឬមិនថត អាហ្នឹងខ្ញុំសូវជាបានយកចិត្តទុកដាក់ដេញដោល ទេ ។ នេះសុំចប់ប៉ុណ្ណឹង ។

[១០:១៣:០៣]

**ស៖** សំណួរបន្តទៀត អរគុណលោកបាទ ។ ជូនលោកថា ក្នុងនាមលោកជាប្រធានរបស់មន្ទីរ ស-២១ ហ្នឹង ហើយសំណួរនេះ ខ្ញុំបានសួរទៅដល់អ្នកជំនាញមួយលើករួចហើយ នៅពេលដែលលោក បណ្ឌិត ក្រេក អេតធេសាន់ ហ្នឹងបានចូលមកឆ្លើយចំពោះអង្គសវនាការ ពីបញ្ហាដែលមានការចាប់ខ្លួន របស់ជនជាតិខ្មែរបានបញ្ជូន ដែលបានបញ្ជូនមកដោយអាជ្ញាធរថៃតាមរយៈបោយប៉ែតហ្នឹង ថាក្នុងនាម លោកជាប្រធានរបស់មន្ទីរស-២១ តើលោកមានបានទទួលពួកអស់ទាំងនោះ ដែលគេបញ្ជូនមកពី ប្រទេសថៃតាមរយៈលោក ខែក ប៉ែន គេដាក់មានសមមិត្ត ខែក ប៉ែន ។ ហើយចូលក្រោយមកអ្នក

ទាំងនោះបានយកចូលមកមន្ទីរស-២១ តាមឡានមួយគ្រឿង ហើយខ្ញុំគ្រាន់តែចង់រំឭកលោកថា ក្នុងនោះវាមាន ក្នុងចំនួនមនុស្ស២៦នាក់ហ្នឹង វាមានស្លាប់ម្នាក់ តើលោកក្នុងនាមលោកជាប្រធាន លោកមានបានទទួលពួកហ្នឹងទេ?

**ឆ៖** សូមគោរពលោកប្រធាន! សូមគោរពលោកព្រះរាជអាជ្ញា! នេះវាចូលទៅក្នុងសកម្មភាពល្អិត ខ្ញុំក្តាប់មិនបាន បើទោះជាក្តាប់បានក៏ឥឡូវភ្លេចអស់ទៅហើយ ។ សំខាន់គឺបញ្ជី បើបញ្ជីនេះវាពិតជារបស់ស-២១ មែន ខ្ញុំអត់ប្រកែកទេ ។ វាពិតជារឿងដែលត្រូវតែឆ្លងកាត់ វាពិតជារឿងដែលស្ថិតនៅក្រោមអំណាចរបស់ខ្ញុំ ដែលបក្សប្រគល់ឲ្យ ។

ពីខែណា? បញ្ជីហ្នឹងពីខែណា?

**លោក តាន់ សេណារ៉ុង៖**

សូមគោរពលោកប្រធាន! តើខ្ញុំអាចជូនឯកសារមួយទៅដល់ជនជាប់ចោទ? ដើម្បីជាពន្លឺក្នុងការចងចាំ ។

**ប្រធានអង្គជំនុំ៖**

អង្គជម្រះអនុញ្ញាត ហើយមន្ត្រីតុលាការទទួលយកឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនទៅជនជាប់ចោទពិនិត្យ ដើម្បីអាចមានលទ្ធភាពក្នុងការឆ្លើយតបនឹងសំណួរ ។

**លោក តាន់ សេណារ៉ុង៖**

ជាភាសាខ្មែរមាន ERN ហ្នឹងលេខ 00090147 ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំចង់ឲ្យធ្វើការគោរពៗក្នុងការគោរពទៅលើ ក្នុងការពិនិត្យមើលលើឯកសារខ្ញុំមិនដឹងថា ឯកសារនេះនិយាយអំពីអ្វីទេ? គឺឯកសារដែលខាងលោកសហព្រះរាជអាជ្ញាបានលើកយកមកនោះ ហើយខ្ញុំជឿថា ឯកសារនេះគួរតែត្រូវបានអាននៅក្នុងសាលសវនាការ ឬក៏ធ្វើសេចក្តីសង្ខេបមុននឹងយើងធ្វើការវិភាគទៅលើឯកសារនេះ ។ ដូច្នេះ ថាតើលោកខាងសហព្រះរាជអាជ្ញាអាចធ្វើការបញ្ជាក់អំពីឯកសារនេះបានដែរឬទេ?

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកចៅក្រម ឡាវែន៍ ។ ឯកសារដែលខ្ញុំបានទទួលហ្នឹង ហើយដែលមានបញ្ជីរបស់អ្នកទោសដូចលេខ ERN ដែលខ្ញុំបានជម្រាបជូនហ្នឹង វាមាននៅក្នុងបញ្ជីរបស់-- មាននៅក្នុងសំណុំរឿងរបស់យើង ហើយឯកសារហ្នឹងវាមានភ្ជាប់ជាមួយនឹងលិខិតរបស់ *អេមណេសធី អីនធឺណាស្សូណាល់* ហ្នឹង ដែលមានភាសាបារាំង ERN ណាំប៊ឺហ្នឹង គឺលេខ 00271499 និង 00271501 ហើយជាភាសាខ្មែរវាមានលេខ 0000323619 ។

**អ្នកបកប្រែ៖**

សូមឲ្យលោកសហព្រះរាជអាជ្ញាអានលេខ ERN ម្តងទៀតឲ្យបានយឺតបន្តិច សូមអរគុណ ។

**លោក តាន់ សេណារ៉ុង៖**

បាទ,អរគុណលោក ។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាអានៗៗបញ្ជាក់លេខ ERN ម្តងទៀត ហើយអម្បាញ់មិញលេខ ERN ជាភាសាអង់គ្លេសទេ ។ ទីមួយបញ្ជាក់លេខ ERN ម្តងទៀត ដើម្បីឲ្យអ្នកបកប្រែបានស្តាប់បានច្បាស់ ហើយនឹងអាចបកប្រែជូនដល់ភាគីដែលប្រើប្រាស់ភាសាផ្សេងទៀត ។ ហើយនៅក្នុងនោះក៏បញ្ជាក់ផងដែរ អំពីលេខ ERN ជាភាសាអង់គ្លេស បើសិនជាមាន ឬក៏គ្មានក៏បញ្ជាក់ឲ្យបានច្បាស់លាស់អំពីបញ្ហានេះ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ ។ ជាភាសាបារាំងលេខERN លេខ 00271499 ហើយនឹងបញ្ចប់ដោយលេខ 00271501 ។ ប៉ុន្តែជាអកុសលពុំមាន ខ្ញុំពុំមានឯកសារហ្នឹង ERN នឹងឯកសារហ្នឹងជាភាសាអង់គ្លេសទេ មានតែជាភាសាខ្មែរ ដែលមានលេខ 00323619 ។

ឯកសារនេះ គឺជាការព្រួយបារម្ភរបស់អង្គការអន្តរជាតិ ដែលបានលើកឡើង ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ឲ្យខ្ញុំសូមទោស ប៉ុន្តែ ខ្ញុំបានពិនិត្យមើលឯកសារទៅតាមលេខ ERN ដែលលោកបានប្រគល់មក

ឱ្យខ្ញុំ ប៉ុន្តែខ្ញុំមិនអាចរកមើលឯកសារនេះឃើញទេ ។ តើឯកសារនេះមានលេខអ្វីផ្សេងទៀតទេ? តើថិតនៅក្នុងដីកាបញ្ជូនឱ្យស៊ើបសួរ ឬក៏ជាឧបសម្ព័ន្ធនៃឯកសារអ្វីផ្សេងទៀត? ពីព្រោះនេះជាបញ្ហាដែលខ្ញុំមិនរកមើលឯកសារនេះឃើញ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ។ តាមការទទួលបានរបស់ការិយាល័យសហព្រះរាជអាជ្ញា គឺឯកសារហ្នឹងគឺមាននៅក្នុង *ហ្វាយឡេប* ខ្ញុំក៏ភ្លេចជម្រាប សូមអភ័យទោស ភ្លេចជម្រាប D84-2.5 ។ វាអាចថាឯកសារនេះមាននៅក្នុងសំណុំរឿងលេខ០០២ ក៏ពុំដឹង ។ ប៉ុន្តែ បញ្ជីឈ្មោះដែលពាក់ ព័ន្ធជាមួយនឹងការព្រួយបារម្ភរបស់អង្គការអន្តរជាតិហ្នឹង វាមាននៅក្នុង វាពាក់ព័ន្ធនៅក្នុងបញ្ជីរបស់មន្ទីរស-២១ ដូចខ្ញុំបានជម្រាបជូនអម្បាញ់មិញ ។ ក៏ប៉ុន្តែ ឯកសារហ្នឹង គឺមាន ខាងការិយាព្រះរាជអាជ្ញា គឺបានទទួលពីក្នុង *ហ្វាយឡេប* ហ្នឹងមក ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារជនជាប់ចោទ ។

**លោកស្រី ការនីវារេស៖**

គឺថា ឯកសារនេះដែលព្រះរាជអាជ្ញាលើកឡើងនេះ តាមពិតគឺដាក់បញ្ចូលនៅក្នុងសំណុំរឿងក្តីលេខពីរទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

[១០:២២:២០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បញ្ជីអ្នកទោសនេះ ដែលបានយោងទៅរកនោះ គឺថាត្រូវវាឆ្លើយតបទៅនឹងបញ្ជីអ្នកទោសដែលត្រូវបានឃុំខ្លួននៅស-២១ ទេ ឬក៏បញ្ជីអ្នកទោសនេះគ្រាន់តែបញ្ជីអ្នកទោស ដែលជាឯកសារភ្ជាប់ទៅនឹងបញ្ហាដែលលើកឡើង ។ តើលោកអាចបញ្ជាក់បន្ថែមបានទេ? តើមានទំនាក់ទំនងរវាងបញ្ជីអ្នកទោសនេះទៅនឹងស-២១ ទេ? បើសិនជាមានទំនាក់ទំនងសូមលោកបញ្ជាក់ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកចៅក្រម ដែលសួរបញ្ជាក់នូវសំណួរនេះឡើងវិញ ។ បញ្ជីនេះវាមាននៅក្នុងបញ្ជី

របស់អ្នកទោស D លេខ 57 អឺនឌីក លេខ 2 ដែលមានលេខ ERN0090147 ។ ហើយបើសិនជាអង្គជំនុំជម្រះនិងលោកចង់បាន គឺការិយាល័យតំណាងសហព្រះរាជអាជ្ញាអាចបង្ហាញជូននៅក្នុងអេក្រង់កុំព្យូទ័រហ្នឹងបានដែរ ។ បើសិនជាលោកអនុញ្ញាត ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ លោកប្រធានបានឯកសារនេះជាភាសាខ្មែរ ប៉ុន្តែ យើងពិនិត្យឃើញថាមិនមានអត្ថបទជាភាសាបារាំង ឬអង់គ្លេសទេ ដែលថាយើងមិនអាចទាន់រកឃើញ ។ អ៊ីចឹងសេចក្តីយោងដែលយើងប្រើនោះ គឺថាយើងមិនទាន់ទទួលបានទេ គឺយើងមិនអាចបើក *ហ្វាយឡេប* បានទេ ។ ដូច្នេះ តើសហព្រះរាជអាជ្ញាអាចជួយផ្តល់ជាអត្ថបទជាភាសាបារាំង ឬក៏ជាភាសាអង់គ្លេសបានទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមិនប្រាកដថា តើឯកសារនេះចេញមកពីឯកសាររឿងក្តីលេខទីមួយនោះ?

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកស្រីប្រធាន ។ ចំពោះឯកសារនេះដែលការិយាល័យសហព្រះរាជអាជ្ញានឹងបានទទួលនឹង ព្រោះវាក្រោយពីយើងរកបាននូវបញ្ជីឈ្មោះនេះ ហើយក្នុងនោះយើងមានការបកប្រែប្រហែលជាវាអាចពាក់ព័ន្ធជាមួយនឹងសំណុំរឿងលេខ០០២ ពីព្រោះវាពាក់ព័ន្ធជាមួយនឹងគណៈប្រធានរដ្ឋ ខៀវ សំផន អាចនៅក្នុងសំណុំរឿង តាមខ្ញុំស្មានក្នុងសំណុំរឿងទីមួយ ពុំមានភ្ជាប់លិខិតនេះមកជាមួយ លិខិតដែលបានផ្ញើមកពី អេមណាសធី អ៊ីនធឺណាស្យូណាល់ ហ្នឹង ប៉ុន្តែ វាមានបកប្រែ ប្រហែលជាមាននៅក្នុងសំណុំរឿងទីពីរ ។ ប៉ុន្តែ លិខិតហ្នឹងវាភ្ជាប់គ្នាហ្នឹងជាមួយបញ្ជីឈ្មោះដែលបានបញ្ជូនហ្នឹង ។

ការិយាល័យសហព្រះរាជអាជ្ញាគ្រាន់តែចង់បញ្ជាក់ ហើយនិងជូនឯកសារហ្នឹងជាភាសាបារាំងនៅពេលក្រោយ ហើយនិងគ្រាន់តែចង់បញ្ជាក់ជាមួយនឹងជនជាប់ចោទថាតើគាត់បានទទួលចាំនៅពេលស្សួរលម្អិត យើងខ្ញុំនឹងបង្ហាញជូនបន្តបន្ទាប់ទៀត ប៉ុន្តែគ្រាន់តែចង់សួរបញ្ជាក់ទៅដល់ជនជាប់ចោទថាតើគាត់មានបានទទួលនូវជនជាប់ចោទទាំងនោះ ។ ហើយក្នុងនោះដែរ ការិយាល័យសហព្រះរាជអាជ្ញាពុំ

អាចអាននូវចំណាររបស់លោកហ្នឹងបាន ។ ថាតើលោកអាចបញ្ជាក់ពីចំណារហ្នឹងឡើងវិញបានទេ ថាតើចំណារហ្នឹងតាមខ្ញុំយល់ប្រហែលជាចំណាររបស់លោក ។ គ្រាន់តែលោកបញ្ជាក់ឡើងវិញថាចំណារហ្នឹងបានចារដូចម្ដេចខ្លះ? ហើយនិងពិភាក្សាលម្អិតនៅ--

[១០:២៨:៣៦]

**ប្រធានអង្គជំនុំ៖**

យើងគិតថា ការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញាក្នុងករណីនេះ ទាំងការបង្ហាញឯកសារ ទាំងការបង្ហាញនូវហេតុផលផ្សេងៗមិនច្បាស់លាស់ទេ។ អ៊ីចឹងគឺពាក់ព័ន្ធទៅនឹងអ្វីប៉ុនប៉ងលើកឡើងនេះយើងផ្អាកបញ្ឈប់ការដេញដោលនេះជាបណ្ដោះអាសន្នសិន ហើយឲ្យលោកបន្តទៅអង្គហេតុផ្សេងទៀត ឬរឿងហេតុផ្សេងទៀត ដែលលោកប៉ុនប៉ងសួរ ហើយទុកឱកាសក្នុងការឈប់សម្រាកក្នុងអំឡុងពេលបន្តិចទៀតនេះលោកនឹងមានឱកាសនៅក្នុងការសិក្សា និងបញ្ជាក់អំពីបញ្ហានេះឡើងវិញឲ្យបានច្បាស់ ដើម្បីយើងសម្រេចចុងក្រោយថា តើយើងត្រូវធ្វើសវនាការដេញដោលអំពីអង្គហេតុនេះ ឬក៏មិន ច្រានចោលក្នុងការប៉ុនប៉ងលើកអង្គហេតុនេះមកដេញដោលនៅពេលនេះ ។ ពីព្រោះមិនច្បាស់លាស់រវាងថា នៅក្នុងអង្គហេតុដែលបានលើកឡើងនេះ នៅក្នុងរឿងទីមួយឬក៏ទីពីរ ។ អ៊ីចឹង សូមឲ្យលោកតំណាងសហព្រះរាជអាជ្ញាអាចបន្តទៅអង្គហេតុផ្សេង ។ ចំពោះអង្គហេតុនេះគឺទុកឱកាសនៅក្នុងលោកហ្នឹងមានការពិចារណានៅក្នុងអំឡុងពេលបន្តិចទៀតនៃដំណើរការសម្រាកនៃរយៈសម្រាកនេះចុះ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ និងសូមអរគុណលោក កាំង ហ្គេកអ៊ាវ ដោយសំណួរនេះនឹងទុកដើម្បីនឹងលើកយកមកពិនិត្យឡើងវិញម្ដងទៀតតាមការឲ្យយោបល់របស់លោកប្រធានអង្គជំនុំជម្រះ ។ ហើយខ្ញុំជាតំណាងសហព្រះរាជអាជ្ញាជាតិអស់សំណួរ ហើយនិងសូមជូននាទីបន្ទាប់ទៀតជូនទៅតំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។ អរគុណចំពោះលោកដែលបានឆ្លើយនូវសំណួររបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយខ្ទះដប់នាទី សូមអញ្ជើញចូលមកវិញដើម្បីបន្តដំណើរការនីតិវិធីសវនាការដេញដោល។

*[សវនាការសម្រាកពីម៉ោង ១០:៣០ ដល់ម៉ោង ១១:០០ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។ ហើយជាកិច្ចបន្តនេះសូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាជាតិឡើងបញ្ជាក់អំពីឯកសារដែលសហព្រះរាជអាជ្ញាបានលើកឡើងដើម្បីយកមកពិភាក្សាដេញដោលនាពេលនេះអំពីភាពពាក់ព័ន្ធនៃឯកសារទាំងអស់នេះទៅនឹងអង្គហេតុនឹងដែលត្រូវធ្វើសវនាការដេញដោលនាពេលនេះ ។ ហើយទីពីរ គឺបញ្ជាក់ផងដែរអំពីអត្ត-សញ្ញាណនៃឯកសារដែលបានលើកឡើងមកដេញដោល ប៉ុនប៉ងក្នុងការលើកឡើងមកដេញដោលនៅពេលនេះអំពីលេខ ERN និងលេខផ្សេងទៀតដែលជាភាសានីមួយៗដើម្បីឲ្យភាគីដែលពាក់ព័ន្ធនឹងអាចមានការកត់សម្គាល់មតិយោបល់ ឬក៏អាចមើលឃើញនូវ រកឃើញនូវឯកសារទាំងអស់នេះចេញពីសំណុំរឿងជាក់លាក់ ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាជាតិ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ ។ តំណាងសហព្រះរាជអាជ្ញាជាតិដែលចង់លើកនូវបញ្ហាដែលបានជម្រាបជូនពីមុនមកនេះ គឺមានការព្រួយបារម្ភតែទៅលើបញ្ជីរបស់អ្នកទោសដែលបាន បញ្ជូនមកពី ម-១៦ ចុះថ្ងៃទី២៥ ខែ១១ ឆ្នាំ១៩៧៦ ដែលមាន ERN ខ្ញុំសូមអានឡើងវិញ លេខ00090147 និង ERN ជាភាសាអង់គ្លេសមានដូចខាងក្រោមគឺលេខ 00181611 ។ ចំពោះអត្ថបទដែលពាក់ព័ន្ធជាមួយនឹងបញ្ជីនេះ ខ្ញុំសូមមិនលើកយកមកពិភាក្សាទេ គឺសុំលើកយកតែបញ្ជីដែលមាន ដូចបានជម្រាបជូននូវ ERN ទាំងពីរភាសានេះជូន ។ ខ្ញុំសូមអស់យោបល់ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** លោកបាននិយាយថា បញ្ជីឈ្មោះមនុស្សទាំង២៦នាក់នេះគឺជាបញ្ជីដែលគេផ្ញើពីម-១៣ មកឬ?

**លោក តាន់ សេណារ៉ុង៖**

បាទសូមអរគុណលោកស្រីចៅក្រម ។ ខ្ញុំសូមគ្រាន់តែអាននូវបញ្ជីរបស់លិខិតហ្នឹងដែលបាន ផ្ញើមកពីព្រំដែលកម្ពុជា ថៃហ្នុងដាក់ថា គណៈកម្មាធិកា--

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ្វីដែលខ្ញុំចង់ដឹងនោះគឺថា ពីមុនលោកទើបបាននិយាយថា តើមនុស្សអស់ទាំងហ្នឹងត្រូវបាន គេបញ្ជូនមកពីម-១៣ ឬពីព្រើនៅក្នុងការបកប្រែជាភាសាអង់គ្លេស គឺអស់មាននិយាយពីម-១៣ ទេ តែមាននិយាយអំពី ម-១៦ តើលោកអាចបញ្ជាក់បានទេ?

[១១:០៤:៤៩]

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកស្រីចៅក្រម ។ នៅក្នុងបញ្ជីនេះ គឺមកពី ម-១៦។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ៊ីចឹងក្នុងករណីហ្នឹង តើបញ្ជីហ្នឹងវាមានភាពពាក់ព័ន្ធអ្វីដែលទៅនឹងស-២១ ហ្នឹងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានោះ?

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកស្រីចៅក្រម ។ តំណាងការិយាល័យសហព្រះរាជអាជ្ញា ដែលបានលើកនូវបញ្ជីឈ្មោះហ្នឹង អ្នកទោសដែលបានបញ្ជូនមកពីប្រទេសថៃហ្នឹង ពីព្រោះនៅក្នុងបញ្ជីរបស់អ្នកទោសនោះវាមាននៅក្នុងសំណុំរឿងលេខ០០១ ទីមួយ ។ ទីពីរ គ្រាន់តែចង់បញ្ជាក់ទៅលើជនជាប់ចោទថាតើ នៅក្នុងអំឡុងកាលដែលគាត់ធ្វើជាប្រធានមន្ទីរស-២១ ហ្នឹង គាត់ធ្លាប់បានទទួលមនុស្សដែលចាប់បញ្ជូន មកពីព្រំដែលថៃតាមរយៈ ម-១៦ ដែរឬទេ? ហើយនៅក្នុងនោះដែរ ការិយាល័យសហព្រះរាជអាជ្ញានោះវាមានចម្ងល់ វាឃើញមានចំណាររមួយនៅចុងបញ្ជីដែលបញ្ជូនមកពី ម-១៦ ហ្នុងវាហាក់ដូចជាចំណាររបស់ជនជាប់ចោទ ។ អ៊ីចឹងបានជាការិយាល័យសហព្រះរាជអាជ្ញាចង់បញ្ជាក់ឡើងវិញទៅលើជនជាប់ចោទហ្នឹងនូវបញ្ជីនេះថាតើគាត់ អំឡុងពេលនោះគាត់ពិតជាបានទទួលឬយ៉ាងណា? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

យើងមានឯកសារមួយជាភាសាខ្មែរ ហើយនិងដែលជាបញ្ជីឈ្មោះមនុស្ស ។ ហើយនៅខាងចុងឯកសារនេះគឺមានចំណាររមួយនៅខាងឆ្វេងដៃ ។ តើលោកនិយាយចំណារនៅខាងឆ្វេងដៃនេះឬ? ពីព្រោះ

អីតាមខ្ញុំមើលទៅគឺថា ចំណារខាងឆ្វេងដៃហ្នឹងមើលទៅដូចជាអានមិនដាច់ទេ ឬមួយក៏លោកនិយាយអំពីចំណារអ្វីផ្សេងក្រៅពីចំណារមួយនេះ?

[១១:០៧:៣៧]

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកចៅក្រមឡាវ៉ែន៍ ។ ខ្ញុំលើកនៅពេលនេះគឺចំណារដែលនៅខាងឆ្វេងដៃហ្នឹង ដែលចង់បញ្ជាក់ទៅជនជាប់ចោទដើម្បីឲ្យគាត់ ក្រែងលោគាត់មានការចងចាំឡើងវិញ ថាតើជាចំណារហ្នឹងជាចំណារខាងឆ្វេងដៃជាចំណាររបស់គាត់ឬ? ហើយមានន័យដូចម្ដេចដែរ? ពីព្រោះវាមានការព្រិលប្រទាក ប្រឡាក់ៗមើល ដែលពុំអាចអានបាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាតាំងសំណួរម្ដងទៀតឲ្យបានជាក់ចំពោះជនជាប់ចោទ។ ហើយជនជាប់ចោទត្រូវត្រាប់ស្ដាប់ ហើយនិងអាចឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាជាតិដែលនឹងសួរសំណួរលោកពាក់ព័ន្ធជាមួយនឹងចំណារនៅលើឯកសារដែលបានបង្ហាញដោយតំណាងសហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** អរគុណលោកប្រធាន ។ សំណួរជូនលោក កាំង ហ្គេកអ៊ាវ ចង់សួរថាតើចំណារនេះ គឺពិតជាចំណាររបស់លោកទេ? ហើយចំណារហ្នឹងវាមានន័យដូចម្ដេចដែរ?

**ឆ៖** លោកប្រធានជាទីគោរព! ចំណារនេះថ្វីត្បិតតែពាក់កណ្ដាលមើលមិនដាច់ ក៏ប៉ុន្តែខ្ញុំទទួលស្គាល់ ថាជាចំណាររបស់ខ្ញុំ អក្សររបស់ខ្ញុំ ។ បាត់ស៊ីញ៉េ ហើយតិច វាជាអក្សរខ្ញុំ។ ឯចំណែក រឿងរ៉ាវផ្សេងទៀតទាក់ទងជាមួយនឹងជនជាតិខ្មែរទាំង២៦, ២៥ រូបនេះខ្ញុំនឹកមិនឃើញទេ ។

**លោក តាន់ សេណារ៉ុង៖**

ខ្ញុំសូមកាត់ប្រសាសន៍សុំយោបល់លោកប្រធានថាតើអាចឲ្យខាងការិយាល័យសោតទស្សន៍អាចបង្ហាញឯកសារនេះនៅតាមអេក្រង់កុំព្យូទ័រហ្នឹងបានទេ? ដោយភ្ជាប់មកខាងការិយាល័យសហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

ខាងបច្ចេកទេសសោតទស្សន៍សូមភ្ជាប់នូវប្រព័ន្ធកុំព្យូទ័រមកប្រព័ន្ធកុំព្យូទ័ររបស់សហព្រះរាជ

អាជ្ញាដើម្បីបញ្ចាំងនូវឯកសារដែលបានលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះ ។

[១១:១០:៣៥]

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** សូមលោកបង្ហាញពីចំណារខាងក្រោម ដែលជនជាប់ចោទគាត់បានទទួលស្គាល់ថា ជាចំណារ របស់គាត់ហ្នឹង ថាតើលោកអាចនឹកឃើញនូវចំណារនេះមានអត្ថន័យដូចម្តេច?

**ឆ៖** អរគុណ សូមគោរពលោកប្រធាន! ចំណារនេះខ្ញុំមើលដាច់បានតែប៉ុន្មានម៉ាត់ទេ ។ ចំណងជើងធម្មតាទេ ខ្ញុំសរសេរថា "បងជាទីគោរព!" ។ នេះជាសេចក្តីចម្លងលិខិតបញ្ជូនពួកខ្មែរ២៥ នាក់ ។ តទៅទៀតខ្ញុំមើលអត់ដាច់ទេ ។ ហើយមានពាក្យសៀម មួយម៉ាត់បញ្ជូនស្អីទៀតមើលមិនដាច់ទេ។ ដូច្នេះ ខ្ញុំមើលដាច់បានតែប៉ុណ្ណឹង ។ នេះសូមបញ្ជាក់ជូនថា ដោយឡែកនិយាយត្រឹម នេះខ្ញុំមើលដាច់បានតែប៉ុណ្ណឹងឯង ។

**ស៖** អ៊ីចឹងលោក កាំង ហ្កេកអ៊ាវ លោកពិតជាទទួលស្គាល់ថា លោកហ្នឹងបានទទួលចំនួនមនុស្ស ចំនួន២៦នាក់ហ្នឹង វាមានស្លាប់ម្នាក់ ដូច្នេះមែនទេ?

**ឆ៖** បញ្ហានេះ តែមានចំណារខ្ញុំហើយវាច្បាស់ជាមនុស្សមកដល់ហើយៗ ។ ហើយប្រហែលជាលិខិតនេះវាមកជាមួយមនុស្ស ។ ក៏ប៉ុន្តែ ខ្ញុំត្រូវចារទៅជូនមេខាងលើរបស់ខ្ញុំថា គេបញ្ជូនមកដល់ខ្ញុំហើយ ព្រោះសេចក្តីខាងដើមដែលខ្ញុំសរសេរថានេះជាសេចក្តីចម្លងលិខិតបញ្ជូនខ្មែរ២៥នាក់ ។ ដូច្នេះ មុននឹងមនុស្សនេះមកដល់ពិតជាមេប្រាប់ខ្ញុំ ។ ដល់មនុស្សនេះមកដល់ខ្ញុំបានទទួលមនុស្សហើយ ខ្ញុំបញ្ជូនអាលិខិតនេះទៅលើថាខ្ញុំបានទទួលហើយ ។ នេះតាមការវិភាគលើចំណារ លើឯកសារទាំងអស់នេះខ្ញុំសូមសន្និដ្ឋានប៉ុណ្ណឹង ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក កាំង ហ្កេកអ៊ាវ ។ លោកប្រធានសូមឲ្យលោកឲ្យខាងបន្ទប់សោតទស្សន៍ហ្នឹងត្រឡប់រូបភាពហ្នឹងចូលរូបភាពដើមវិញចុះ ហើយខ្ញុំជាតំណាងសហព្រះរាជអាជ្ញាជាតិសូមអស់សំណួរហើយនិងបញ្ជូនតួនាទីបន្ទាប់នេះទៅលោក វីលៀម ស្មីត ដែលជាសហព្រះរាជអាជ្ញារងអន្តរជាតិធ្វើការសាកសួរជនជាប់ចោទបន្ត ។

[១១:១៣:៤៦]

**ប្រធានអង្គជំនុំ៖**

សូមផ្នែកបច្ចេកទេសនៃសោតទស្សន៍សូមផ្តាច់ប្រព័ន្ធជាមួយនឹងកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ហើយមកភ្ជាប់នូវរូបភាពប្រក្រតីឡើងវិញ ។ ហើយសូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រម ។ លោកប្រធាន បើសិនជាខ្ញុំសុំឲ្យមានការអនុញ្ញាតគឺខ្ញុំចង់ឲ្យធ្វើការបង្ហាញឯកសារ D69/18 ដែលមានលេខ 0005248 សូមឲ្យដាក់តាំងបង្ហាញលើអេក្រង់ដោយភ្ជាប់មកលើកុំព្យូទ័ររបស់ខាងសហព្រះរាជអាជ្ញា ។ រូបថតនេះគឺជារូបថតរបស់ជនជាប់ចោទនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលគាត់ជាប្រធាននៅស-២១ ។

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេសសោតទស្សន៍សូមភ្ជាប់ប្រព័ន្ធមកកុំព្យូទ័រសហព្រះរាជអាជ្ញាសាជាថ្មីម្តងទៀត។

[១១:១៥:១២]

**សួរដោយ លោក វីលៀម ស្មីត៖**

អ៊ឹចឹង ខ្ញុំសូមពន្យល់បន្តិចលោកប្រធានទៅលើសំណួរដែលខ្ញុំនឹងសួរទៅលោក កាំង។

លោក កាំង ហ្គេកអ៊ាវ ទាក់ទងទៅនឹងថា តើគោលនយោបាយនៃការសម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានធ្វើឡើងបង្កើតឡើងនៅស-២១ ។ គឺថា លោកបានពិភាក្សាអំពីការទទួលខុសត្រូវទៅលើការបណ្តុះបណ្តាលនៅស-២១ ហើយជាពិសេសទាក់ទងទៅនឹងគោលនយោបាយនៃការសម្លាប់នេះ ។ ដូច្នេះ អង្គសវនាការទាំងមូលនឹងអាចយល់ដឹងបានកាន់តែច្រើនថា តើលោកធ្វើកិច្ចការហ្នឹងដោយរបៀបណា? ហើយទៅតាមភាពជាក់ស្តែងនៃប្រតិបត្តិការប្រចាំថ្ងៃរបស់លោកនោះ ។

ដូច្នេះ នេះគឺជាជំនួយការដ៏ច្រើនដល់ខាងសហព្រះរាជអាជ្ញា បើសិនជាលោកអាចធ្វើបានដូច្នេះ។ ប៉ុន្តែ មុននឹងខ្ញុំសួរសំណួរមួយចំនួនទៅលោកនោះ ខ្ញុំចង់ធ្វើសេចក្តីសង្ខេបបន្តិចអំពីអ្វីដែលបានទទួលស្គាល់ហើយនៅក្នុងសវនាការ ។

លោក កាំង ហ្គេកអ៊ាវ លោកបានផ្តល់សក្ខីកម្មថា “ការសម្លាប់តាមទំនើងចិត្តក្រៅច្បាប់ហ្នឹង គឺត្រូវបានផ្សព្វផ្សាយឡើងនៅស-២១ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ គឺសម្រាប់អង្គភាពទាំងមូល ព្រមទាំង

ការផ្សព្វផ្សាយផងដែរនៅតាមកិច្ចប្រជុំផ្សេងៗនៅតាមអង្គភាពតូចៗ" ។ លោកក៏បានឯកភាពផងដែរថា លោកបានធ្វើការផ្សព្វផ្សាយគោលនយោបាយសម្លាប់ទាំងនេះ នៅពេលដែលធ្វើការឆ្លើយសំណួររបស់ ខាតវ៉ាយថ៍ ដោយបាននិយាយថា "ទាក់ទងតាមជំហរនយោបាយ និងមនោមគមវិជ្ជាទៅលើខ្មាំងនោះ គឺមានតែខ្ញុំម្នាក់ឯងទេ ដែលមានសិទ្ធិយកក្បាលមេក្រុមកកាន់ ដើម្បីអប់រំកម្មាភិបាលអស់ទាំងនុ៎ង តើជាការពិតដែរឬទេ?"

**ស៖** សំណួរទីមួយដែលខ្ញុំមាន បើសិនជាលោកអាចឆ្លើយឲ្យបានខ្លីបំផុតនោះ គឺថា នៅពេលដែលលោកនិយាយថា មានតែលោកម្នាក់ទេ ដែលជាអ្នកទទួលខុសត្រូវក្នុងការអប់រំបុគ្គលិកនៅក្នុងអង្គភាពរបស់លោកទាក់ទងទៅនឹងគោលនយោបាយនេះ ហើយគឺមានតែលោកទេដែលមានសិទ្ធិកាន់ក្បាលមេក្រុមនោះ អ៊ីចឹងតើលោកនិយាយហ្នឹង គឺជាភាពជាក់ស្តែង ឬក៏វាមានអត្ថន័យអ្វីផ្សេងពីហ្នឹងទៀត? មានន័យថា គឺមានតែលោកតែឯងទេឬ ដែលអាចធ្វើការបង្ហាញមាគ៌ាបក្ស ឬក៏របស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់ខ្មាំងនៅស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មុននឹងចូលដល់ចម្លើយនេះ ខ្ញុំសូមបញ្ជាក់បញ្ហាពីរ ។ បញ្ហាទីមួយ មាគ៌ាវណ្ណៈនិងការតស៊ូវណ្ណៈ ជាមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលស្តីថា ខ្មាំងត្រូវតែកម្ទេច នេះជាមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជាជាទូទៅ ដែលគ្មានអ្នកណាប៉ានល្មើស នេះទីមួយ ។ ទីពីរ អ្នកដែលគេចាប់បញ្ជូនមកស-២១ មិនមែន ស-២១ សុំចាប់ទេ គឺពួកក្រុមបួននាក់ ដែលមានចែងនៅក្នុងសេចក្តីសម្រេចថ្ងៃ៣០ មីនា ហ្នឹង គេអ្នកចាប់បញ្ជូនមក នេះពីរ ។ ទីបី គឺចូលចំសំណួរដែលលោកព្រះរាជអជ្ញា លោកសួរខ្ញុំហើយ ។ នៅស-២១ ខ្ញុំកាន់កាប់ខាងកិច្ចការនយោបាយ ហើយនិងកាន់កាប់ទទួលខុសត្រូវរួម ។ នៅស-២១ អប់រំមាគ៌ានយោបាយចំពោះខ្មាំង និងកិច្ចដំណើរការនៃការសួរ គឺមានតែខ្ញុំទេ នេះក្បាលមេក្រុនេះជាឧទាហរណ៍ស្រាប់ រូបនេះជាឧទាហរណ៍ស្រាប់ ។ នេះនៅហ្នឹងសាលា លើផ្លូវលេខ៩៥ លោកព្រះរាជអាជ្ញា លោកមើលនៅលើផ្លូវលេខ៩៥ មុខសាលាហ្នឹងបែរទៅលិចក្បែរផ្ទះខ្ញុំ សាលាដែលខ្ញុំដាក់ "អ៊ី"អក្សរ E នៅក្នុងប្លង់ដែលខ្ញុំជូនទៅចៅក្រមស៊ើបអង្កេត ។ ដូច្នេះខ្ញុំសូមបញ្ជាក់ថា ពិតជាមានតែខ្ញុំម្នាក់ឯងគត់ដែលជាអ្នកអប់រំនយោបាយនៅស-២១ ។ សូមចប់ ។

[១១:១៩:៤៥]

**ស៖** សូមអរគុណ ។ ខ្ញុំនឹងសួរសំណួរបន្តទៅទៀតទាក់ទងទៅនឹងរូបថតនេះ ដែលពេលលោកអង្គុយ ដោយមានក្បាលមីក្រូហ្វូនខាងមុខនេះ ហើយលោកនិយាយថា រូបថតនេះបានថតនៅសាលា

ដែលជាសម្រាប់ការអប់រំដល់មន្ត្រីនៅក្នុងស-២១ តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ការអប់រំរបស់ខ្ញុំភាគច្រើនទៅលើកម្មាភិបាលសួរចម្លើយប្រចាំឆ្នាំ មែនខ្ញុំអប់រំទូទៅ ។

**ស៖** សូមអរគុណ។ ដែលថាលោកឆ្លើយបានខ្លី ដោយយើងអាចចូលទៅប្រធានបទផ្សេងៗទៀតបានឆាប់តាមដែលអាចធ្វើទៅបាន ។ ទាក់ទងទៅនឹងកិច្ចប្រជុំប្រចាំឆ្នាំ តើការប្រជុំប៉ុន្មានដងនៅក្នុងពេលដែលលោកធ្វើជាប្រធាន ស-២១នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អត់មានឯកសារអីនៅហ្នឹងដែរទេ ។ ដូច្នេះ ខ្ញុំសូមឆ្លើយតាមការចងចាំ ខុស ឬត្រូវ អាហ្នឹងយើងនិយាយគ្នាតទៅទៀត ដោយឈរលើឯកសារ ។ ក៏ប៉ុន្តែនិយាយពីការប្រជុំប្រចាំឆ្នាំ អប់រំប្រចាំឆ្នាំ ប្រជុំប្រចាំឆ្នាំ គឺខ្ញុំធ្វើមើល៉ មហាសន្និបាត ឆ្នាំ១៩៧៥ ក៏ខ្ញុំធ្វើ, ១៩៧៦ ក៏ខ្ញុំធ្វើ, ១៩៧៧ មេខ្ញុំ លោកគ្រូសុន សេន គាត់អញ្ជើញមកដឹកនាំការប្រជុំសន្និបាតនេះដោយផ្ទាល់ខ្លួនប្រហែលជានៅក្នុងថ្ងៃ២៤ មេសា ១៩៧៧ ។ ដល់១៩៧៨ ក៏ខ្ញុំធ្វើ ។ ដូច្នេះ សរុបមក ពេលដែល ណាតគាត់ធ្វើប្រធានក៏ដោយ ក៏ខ្ញុំនៅតែកាន់ក្បាលមេក្រូដឹកនាំកិច្ចការនយោបាយ ។

**ស៖** សូមអរគុណ ។ កិច្ចប្រជុំប្រចាំឆ្នាំសម្រាប់បុគ្គលិកទាំងអស់នៅក្នុងស-២១ ថាតើប្រជុំហ្នឹងរយៈពេលប៉ុនណាដែរ មួយថ្ងៃ មួយសប្តាហ៍ ឬក៏ពីរបីម៉ោងនៅក្នុងមួយលើកៗ?

**ឆ៖** ការប្រជុំ បើតាមខ្ញុំចាំដូចជាមួយថ្ងៃ ហើយបើមានរៀនសូត្រផង អាហ្នឹងច្រើន បើមានការរៀនសូត្រផងច្រើន ត្រូវប្រជុំតាមក្រុម ពិភាក្សាឯកសារ ត្រូវត្រួតពិនិត្យប្រវត្តិរូបបដិវត្តន៍ប្រចាំឆ្នាំ ហើយនិងត្រូវត្រួតពិនិត្យជីវទស្សន៍ប្រចាំឆ្នាំ ។ ដូច្នេះ ការប្រជុំបែបនេះយូរ ប្រហែលជាមួយអាទិត្យ ។ នេះខ្ញុំសូមបញ្ជាក់អ៊ីចឹង ។

**ស៖** សូមអរគុណ ។ កិច្ចប្រជុំទាំងអស់នោះ ថាតើប្រជុំនៅពេលណា នៅក្នុងពេលដដែលក្នុងឆ្នាំនីមួយៗ ឬក៏នៅក្នុងឆ្នាំ១៩៧៥ ១៩៧៦ ១៩៧៧ ហ្នឹង គឺថាច្រើននៅពេលណា?

**ឆ៖** លោកប្រធានជាទីគោរព! រឿងប្រជុំប្រហែលជានៅមានឯកសារទេ ច្បាស់លាស់ ប៉ុន្តែឥឡូវខ្ញុំឆ្លើយតាមជាក់ស្តែងទៅចុះ ។ ប្រជុំសន្និបាតនៅពេលកកើតស-២១ គឺក្រោយការរៀនសូត្រវគ្គលើកទីពីរ នៅឆ្នាំ១៩៧៥ហ្នឹង មិនដឹងថ្ងៃណា ខែណាទេ ។ ដូច្នេះ គ្រប់ការប្រជុំសន្និបាតនៅស-២១ គឺក្រោយដែលខ្ញុំបាទទៅរៀននៅសាលានយោបាយរបស់អគ្គសេនាធិការ ។ នេះគឺប្រជុំអ៊ីចឹង ក្រោយពីបានបង្រៀនពីណោះមក មកបង្រៀននៅណេះ ហើយប្រជុំគ្នាបណ្តោយនៅហ្នឹង ។ នេះសូមបញ្ជាក់ជូន

ដូចតទៅប៉ុណ្ណឹង ។

[១១:២៤:៣៦]

**ស៖** លោក កាំង ហ្គេកអ៊ាវ លោកឯកភាពថា នយោបាយនៃការសម្លាប់ក្រៅច្បាប់ ក៏ត្រូវបានផ្សព្វផ្សាយនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំនៃអង្គភាពទាំងស្រុង ទាំងអស់ ហើយនោះហើយ គឺអង្គភាពទាំងអស់នៃស-២១ ដែលលោកនិយាយថាទាំងអស់ហ្នឹង?

**ឆ៖** យើងនិយាយភាសាពីរ ដែលមានន័យប្រហែលគ្នា ។ លោកមានប្រសាសន៍ អំពីថា ការសម្លាប់ក្រៅច្បាប់ ឯចំណែកពេលនោះ យើងខ្ញុំបង្រៀនអំពីការតស៊ូវណ្ណៈ វាមានលក្ខណៈដូចគ្នាហើយប៉ុន្តែគ្រាន់តែប្រើពាក្យខុសគ្នា ។ ពាក្យមួយ គឺពាក្យរបស់បក្សកុម្មុយនីស្ត ពាក្យមួយរបស់ច្បាប់អន្តរជាតិនិយាយអំពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ នេះវាខុសគ្នាអ៊ីចឹង ។ ដូច្នេះ ការអប់រំអំពីមាគ៌ាវណ្ណៈ និងការតស៊ូវណ្ណៈ យើងខ្ញុំអប់រំជាហូរហែឲ្យអ្នកនៅក្រោមឱវាទ ដើម្បីឲ្យខំប្រឹងប្រែង បើមិនបានជាមានមុខ មានមាត់អីហ្នឹងគេ ក៏ហោចណាស់ចៀសវាងអំពីសេចក្តីស្លាប់ ។ ជំនាន់នោះបុគ្គលិកខ្លួនឯងតែភ្លាត់ខុសមាគ៌ាស្លាប់ហើយ ។ ពីកាលមុន ព្រះរាជអាជ្ញាលោក យ៉េត ចរិយា លោកសួរខ្ញុំ ថាលោក គឺខ្ញុំរើសបុគ្គលិកហ្នឹងសំដៅស្អី? ខ្ញុំឆ្លើយជម្រាបលោកព្រះរាជអាជ្ញា លោក យ៉េត ចរិយា ថា រើសវណ្ណភាព រើសក្មេងដែលនៅស្អាតស្អំ ។ ហើយលោក យ៉េត ចរិយា លោកមានប្រសាសន៍សួរខ្ញុំថា លោកមានគិតចំណេះវិជ្ជាទេ កម្រិតវប្បធម៌ ។ ខ្ញុំថាអត់ ។ ដូច្នេះ ខ្ញុំរើសបុគ្គលិកក៏ដើម្បីឲ្យគេស្រង់ខ្ញុំ ខ្ញុំស្រោចស្រង់ខ្ញុំ ខ្ញុំស្រោចស្រង់គេ ចៀសវាងសេចក្តីស្លាប់ទាំងអស់គ្នា ។ ដូច្នេះ ដើម្បីចៀសវាងសេចក្តីស្លាប់ទាំងអស់គ្នាត្រូវតែខំអប់រំស្អី ដែលជាមាគ៌ាបក្ស ដែលបក្សគេឲ្យតម្លៃ ។ នេះ ដូច្នេះឥឡូវនេះ ជាភាសាបច្ចុប្បន្នភាសាច្បាប់អន្តរជាតិ ស្តីអំពីសិទ្ធិមនុស្ស យើងហៅថា សម្លាប់ក្រៅច្បាប់ ។ ប៉ុន្តែ ជំនាន់នុ៎ង យើងហៅថា មាគ៌ាបក្ស ហ្នឹងគឺសូមជម្រាបឲ្យត្រង់ៗ ខ្ញុំជាអ្នកអប់រំ គ្មានអ្នកណាអប់រំខ្ញុំ ។

**ស៖** អរគុណលោក កាំង ហ្គេកអ៊ាវ លោកបានធ្វើការងារល្អក្នុងការឆ្លើយតបទៅនឹងសំណួរផ្សេងៗរបស់ភាគីទាំងអស់ ។ ហើយឥឡូវហ្នឹងក្នុងការព្យាយាម ដើម្បីសម្រាលបន្ទុកហ្នឹង ខ្ញុំសួរលោកថាសូមឲ្យលោកឆ្លើយតបជាក់លាក់ ដោយខ្លីតាមសំណួរដែលខ្ញុំឆ្លើយ ដើម្បីឲ្យយើងអនុវត្តទៅពីសំណួរមួយទៅសំណួរមួយ ហើយខ្ញុំនឹងសួរខ្លីៗ ។

លោកនិយាយ កិច្ចប្រជុំនោះ គឺថាសម្រាប់អង្គភាពទាំងអស់នៅក្នុងស-២១ ។ តើមានមនុស្សប៉ុន្មានដែលចូលរួមប្រជុំក្នុងការ កិច្ចប្រជុំប្រចាំឆ្នាំហ្នឹង គឺថាមានបួនដង ដែលថាមួយឆ្នាំមានម្តងហ្នឹង?

**ឆ៖** បុគ្គលិកទាំងអស់នៅស-២១ វាច្រើន ។ នៅពេលដែលខ្ញុំប្រជុំប្រចាំឆ្នាំជាសន្និបាតនេះ គឺយកប្រធានផ្នែក ប្រធានពួក ប្រធានក្រុមយកមករៀន ។ ដូច្នេះ ប្រហែលជា៣០នាក់ប៉ុណ្ណឹង ។ នេះម្តងមួយឆ្នាំ គឺប៉ុណ្ណឹង ។

**សៈ** នៅពេលដែលលោកនិយាយ គឺថា មេរបស់ក្រុមនីមួយៗ លោកចង់និយាយថា គឺថាខាងក្រុមការពារ ក្រុមសន្តិសុខ ក្រុមខាងថតរូប ឬក្រុមទាំងអស់ផ្សេងទៀត ឬក៏មានក្រុមណាទៀត? តើអ៊ីចឹងទេ?

**ឆ៖** ក្រុមរាប់ភ្លាមឥឡូវនេះ វាអត់បានទេ ក៏ប៉ុន្តែ ក្រុមដែលលោកព្រះរាជអាជ្ញា មានប្រសាសន៍អំមិញហ្នឹង វាគ្រប់មួយចំនួនហើយ ។ ពួកសួរ វាមានបីពួក ពួកក្តៅ ពួកត្រជាក់ ពួកអង្គាមយកមក មួយក្រុមមួយ ហើយអ្នកសួរពិសេសមិត្ត ប៉ុន ហ្នឹង ចៀសមិនរួចពីមកទេ គ្រប់ពេលវេលា ឯចំណែកខាងពួកកងពិសេស គេមកមួយពួក គ្នាម្នាក់ពីរមក ចំណែកកងការពារ ក៏មកពីរបីនាក់មក ឯពួកខាងព្រៃស ក៏ខ្ញុំហៅឲ្យគេមកមួយចំនួនដែរ ។ ដូច្នេះ វាសរុបមកអ៊ីចឹង នេះរបៀបហ្នឹង ប៉ុន្តែឲ្យជាក់លាក់ ប្រាកដប្រជាខ្ញុំអត់ជាក់លាក់ទេ ភ្លេចអស់ហើយ ។ នេះសូមជម្រាបដោយត្រង់ ។

[១១:២៩:៥៨]

**សៈ** សូមអរគុណ ។ ប៉ុន្តែ ក្នុងន័យថា កិច្ចប្រជុំប្រចាំឆ្នាំដែលខ្ញុំនិយាយនោះ គឺមិនមែនការបណ្តុះបណ្តាលទៅអង្គភាពតូចៗទេ ។ ប៉ុន្តែ និយាយពីកិច្ចប្រជុំប្រចាំឆ្នាំ ដែលលោកនិយាយថា គឺថាប្រើពេលមួយថ្ងៃក្នុងកិច្ចប្រជុំនីមួយៗ តើលោកបញ្ជាក់ថានៅក្នុងកិច្ចបញ្ចប់នៃការប្រជុំហ្នឹង គឺថាក្រុមនីមួយៗគេ មានតំណាង គឺថាមកចូលរួមវគ្គគឺថា រហូតដល់ពេញមួយថ្ងៃ ឬក៏និយាយគឺជាកិច្ចប្រជុំប្រចាំថ្ងៃសម្រាប់ក្រុមនីមួយៗដែលលោកបានប្រជុំផ្សព្វផ្សាយហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបបញ្ជាក់ថា ប្រហែលជារបៀបធ្វើការងាររបស់យើងមិនដូចគ្នា ។ ដូច្នេះ ខ្ញុំពុះពារនិយាយឲ្យបានច្រើនបន្តិច ។ ពួកនីមួយៗ គេប្រជុំពួករបស់គេប្រចាំអាទិត្យ បក្ខជននៅក្នុងស-២១ ប្រជុំជីវភាពដែលគេហៅថា ប្រជុំជីវភាព គឺមានការធ្វើទិតៀន ស្វ័យទិតៀននេះកន្លះខែម្តង ។ សម្ព័ន្ធយុវកក គាត់ធ្វើការទិតៀន និងស្វ័យទិតៀនកន្លះខែម្តង ។ ដោយឡែក រៀនសូត្រប្រចាំឆ្នាំដែលមានមាគ៌ាបក្សច្បាស់លាស់ប្រចាំឆ្នាំនេះ ហៅមកច្រើន ក៏ប៉ុន្តែ ច្រើនថ្ងៃ ។

ឧទាហរណ៍ ដូចជាសន្និបាតថ្ងៃ២៤ មេសា ១៩៧៧ មេខ្ញុំគាត់អញ្ជើញមក ។ គាត់អញ្ជើញមកបានតែមួយព្រឹកទេ ដល់គាត់អញ្ជើញចេញទៅ ឯកសារទាំងប៉ុន្មានយើងចែកជាក្រុមពិភាក្សា ដល់រួច

ហើយយើងខ្ញុំធ្វើប្រវត្តិរូប ឆ្លងប្រវត្តិរូប យើងខ្ញុំធ្វើជីវទស្សន៍ ឆ្លងជីវទស្សន៍ ។ ដូច្នេះ លក្ខណៈរៀនវាប្លែកគ្នាអ៊ីចឹង ។

[១១:៣១:៥៥]

ដោយឡែក ចំពោះកម្មាភិបាលសួរ ពេលដែលខ្ញុំឃើញសភាពការណ៍អី ដែលខាងលើគេដាក់មកត្រូវចាំបាច់ ខ្ញុំហៅតែកម្មាភិបាលសួរមកឧទ្ទេសនាម ។ នេះរឿងមាគ៌នយោបាយ គោលនយោបាយដែលទាក់ទងនឹងការសួរ គឺហៅមកញឹកញាប់ណាស់ ជាពិសេសឆ្នាំ១៩៧៨ ខ្ញុំហៅមកញឹកញាប់ណាស់ រួចហៅមករៀនរបៀបនេះអត់មាននេះទេ រៀនហើយគេទៅផ្ទះ គេទៅធ្វើ ។ នេះរៀនអំពីជាមួយកម្មា-ភិបាលសួរ គឺរៀនហើយគេទៅកន្លែងគេធ្វើការតទៅទៀត ។ នេះខ្ញុំសូមនិយាយឱ្យហូរហែ ឱ្យច្បាស់លាស់បញ្ហានេះ ។ សូមចប់ ។

**ស៖** សូមអរគុណ ។ តើការចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំហ្នឹងជាលក្ខខណ្ឌតម្រូវ ថាត្រូវតែមកប្រជុំទេ?

**ឆ៖** សូមគោរពលោកប្រធាន! អ្នកដែលចូលរួមប្រជុំនេះ គឺជាអ្នកដែលតម្រូវពីស-២១ ទៅហើយជ្រើសរើសដោយគណៈកម្មាធិការស-២១ ។ តម្រូវហើយ ជ្រើសរើសទៀត ។

[១១:៣៣:៣៦]

**ស៖** សហព្រះរាជអាជ្ញាសូមអរគុណ ។ លោកនិយាយពីខាងដើមនោះថា នៅក្នុងការផ្តល់សក្ខីកម្មនៅក្នុងមន្ទីរម-១៣ ហ្នឹង ហើយនឹងក៏ទាក់ទងនិងស-២១ ដែរ ថាមនុស្សម្នាក់ដែលគ្មានទោសត្រូវបាននាំចូលមកដល់អង្គការ ហើយគេបង្គាប់ឱ្យត្រូវតែកម្ទេច ត្រូវតែសម្លាប់ ។ ហើយលោកបន្ថែមទៀតថា ក្នុងនាមជាអ្នកអប់រំគឺថា ធ្វើម៉េចធ្វើឱ្យមានក្លាហាន គេប៊ានសួរ ឱ្យគេប៊ានធ្វើទារុណកម្មដែលទំនងជា-- ធ្វើឱ្យជាមនុស្សស្លូតដែលថាស្លូតត្រង់តាមធម្មជាតិនោះ គឺថាបានប្រែក្លាយមនុស្សទាំងអស់នោះ ជំរុញលើកទឹកចិត្តគេ ធ្វើឱ្យគេប៊ានសួរ ហើយធ្វើឱ្យគេប៊ានធ្វើទារុណកម្ម ហើយធ្វើឱ្យគេប៊ានអនុវត្តនូវគោលនយោបាយកាប់សម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា ។ តើនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ តើលោកបញ្ជាក់ដូចម្តេច? តើលោកលើកទឹកចិត្តអ្នកទាំងអស់នោះធ្វើដូចម្តេច ឱ្យគេអនុវត្តនូវគោលនយោ-បាយកាប់សម្លាប់នោះ?

**ឆ៖** លោកប្រធានជាទីគោរព! សំណួរនេះខ្ញុំឃើញការបកប្រែជាភាសាខ្មែរ បកប្រែថា "អ្នកគ្មានទោសដែលចូលមក ម-១៣ ឬក៏ចូលមក ស-២១ ។ ប្រសិនបើ យើងយកពាក្យមួយម៉ាត់នេះមក

ធ្វើជាលេសប្រកែកគ្នាក៏វាមិនស្រួលប៉ុន្មានដែរ ។ មនុស្សដែលគេចាប់បញ្ជូនមកគឺ ពួកក្រុមបួននាក់នុ៎ង គឺបួនក្រុមនុ៎ងគេសម្រេច ។ ប៉ុន្តែ ខ្ញុំនិយាយបួនក្រុមៗនេះ គឺសម្រាប់ក្រោយថ្ងៃ៣០ មីនាមកទេ ។ មុនថ្ងៃ៣០ មីនា វាមានតែពីរក្រុមទេ ទីមួយគឺ អចិន្ត្រៃយ៍បក្ស ទីពីរ គឺលេខភូមិភាគ ។

ដូច្នេះ មុន ១៧ មេសា ១៩៧៥ ឲ្យតែភូមិភាគគេសម្រេចបញ្ជូនមកដល់ម-១៣ ហើយ គេចាត់ទុកជាខ្មាំងហើយ ។ បើសិនជាប្រៀបធៀបនឹងច្បាប់ជាធរមាន នៅក្នុងប្រទេសផ្សេងៗ អាហ្នឹងយើងហៅថា ចាប់ចងក្រៅប្រព័ន្ធច្បាប់ ក៏ប៉ុន្តែដោយនិយាយថា មនុស្ស--

**សៈ** សូមអត់ទោសលោក កាំង ហ្កេកអ៊ាវ ហើយសូមរំខានបន្តិច ប្រហែលជាយើងយល់ច្រឡំគ្នាហើយ ។ ខ្ញុំសូមអភ័យទោស គឺថាយល់សំណួរខ្ញុំមិនច្បាស់ ខ្ញុំយោងទៅរកគឺបុគ្គលិក គឺថានៅ ម-១៣ ហើយនិងបុគ្គលិកនៅ ស-២១ ហើយថា តើលោកលើកទឹកចិត្តដូចម្តេចឲ្យគេអនុវត្តនយោបាយសម្លាប់? អ៊ីចឹង សូមយោងទៅរកចម្លើយដែលលោកបានឆ្លើយពីមុននោះ ឆ្លើយទៅនឹងសំណួរ ទៅនឹងលោកចៅក្រម ឡាវែន៍ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ នោះ នៅទំព័រ៨៨ ទៅ៩០ លោកបញ្ជាក់ថា ការអប់រំអ្នកសួរ គឺថាជំរុញឲ្យគេមានភាពឃោរឃៅ និងបទឧក្រិដ្ឋ ដូចជានៅម-១៣ និង ស-២១ នោះដែរ ។ ប៉ុន្តែតាមពិតលោកនិយាយថា លោកបានប្តូរស្ថានភាពយុវជនក្មេងៗពីអ្នកស្លូតត្រង់ឲ្យទៅឃោរឃៅ គឺរុញទៅឲ្យគេដាច់ខាត ឲ្យគេប៉ានសួរ ប៉ានធ្វើទារុណកម្ម ហើយធ្វើអ្វីៗតាមបញ្ជា ។ ហើយលោកបាននិយាយថា លោកបានបណ្តុះបណ្តាលមនុស្សទៅតាមនយោបាយដែលឃោរឃៅដើម្បីសម្លាប់មនុស្ស ដើម្បីឃុំឃាំងមនុស្សផ្សេងទៀត ។ ហើយការអប់រំ គឺដើរតួនាទីសំខាន់ដែលធ្វើឲ្យមនុស្សស្លូតត្រង់ទៅជាមនុស្សឃោរឃៅ ហើយលោកនិយាយថា គឺថាអ្នកដែលធ្វើការអប់រំនោះ គឺខ្ញុំ ដើម្បីបំប្លែងគេឲ្យទៅជាមនុស្សដាច់ខាត ឲ្យទៅជាមនុស្សឃោរឃៅ ។ សំណួរដូចខ្ញុំសួរលោកនុ៎ង គឺថានៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំទាំងនោះ តើលោកបាននិយាយពីគោលនយោបាយអំពីការសម្លាប់មនុស្ស កម្ទេចមនុស្សនៅក្នុងកិច្ចប្រជុំនោះ? ថាតើលោកនិយាយដូចម្តេច? ហើយលើកទឹកចិត្តដូចម្តេច ដើម្បីឲ្យគេធ្វើបាន បើសិនជាអ្នកទាំងអស់នុ៎ងមិនចង់ធ្វើនោះ រហូតដល់គេចង់ធ្វើបាននោះ? តើលោកធ្វើដូចម្តេច?

[១១:៣៨:២៧]

**ឆៈ** មូលដ្ឋាន គឺខ្ញុំសូមបញ្ជាក់បន្តទៅទៀត ។ មូលដ្ឋានគឺ “ពាក្យ” ដែលយើងប្រើ បើសិនជាយើងពាក្យរឹងរៀងខ្លួនថា យកមនុស្សស្លូតត្រង់មក អាហ្នឹងវាទាស់គ្នា ។ បើសិនជាមូលដ្ឋានយើងថាមនុស្សដែលគេបញ្ជូនមក ដែលអចិន្ត្រៃយ៍មជ្ឈិម ហើយនិងលេខាភូមិភាគគេបញ្ជូនមកនៅម-១៣ សុទ្ធ

តែខ្មាំង ។ ហើយក្រោយ១៧ មេសា មនុស្សដែលអចិន្ត្រៃយ៍គេបញ្ជូនមក ហើយនិងអាពួកប្អូនទាក់បញ្ជូនមក ម-១៣ ជាខ្មាំង អាហ្នឹងវាស្រួលនិយាយគ្នា ។ ពាក្យដែលខ្ញុំជម្រាបលោកចៅក្រម ឡាវែន៍ គឺយើងខ្ញុំជាអ្នកអប់រំ ។ អប់រំឲ្យដាច់ខាត មានជំហរវណ្ណៈដាច់ខាត ពាក្យហ្នឹងខ្ញុំនិយាយជាហូរហែឲ្យតែមនុស្សដែលគេបញ្ជូនមកស-២១ អ្នកឯងជាអ្នកសួរ ត្រូវតែទុកជាខ្មាំង ។ បើអ្នកឯងមិនទុកជាខ្មាំងទេ អ្នកឯងសួរចម្លើយមិនចេញទេ ។ ហើយខ្ញុំបង្ហាញផ្លូវគ្រោះថ្នាក់ទៀត ដល់កម្មាភិបាលសួររបស់ខ្ញុំម្នាក់ៗ បើអ្នកឯងមិនចាត់ទុកមនុស្សដែលគេបញ្ជូនមកជាខ្មាំងទេ អ្នកឯងសួរចុះសួរឡើងសង្ស័យថា បក្សទៅចាប់មនុស្សស្លូតត្រង់ ។ ដូច្នេះ វាធ្វើឲ្យខ្លួនអ្នកឯងទាស់ជាមួយបក្ស ។ ដូច្នេះ វាធ្វើឲ្យអ្នកឯងកំបុតកនេះរបៀបអប់រំៗហូរហែទូទៅ គឺឲ្យមានជំហរវណ្ណៈដាច់ខាត ខ្មាំងត្រូវតែវ៉ៃ ប៊ានវ៉ៃសួរ បក្សអនុញ្ញាតឲ្យអ្នកឯងវ៉ៃសួរ វ៉ៃទៅ! រួចតែអ្នកឲ្យប៊ានដោះលែង គឺអ្នកឯងខ្មាំងហើយ ។ អានេះយើងអប់រំអ៊ីចឹងការបែងចែងគ្នាឲ្យដាច់ស្រឡះ រវាងបដិវត្តន៍ មិនបដិវត្តន៍ រវាងខ្មាំង និងមិត្ត វានៅត្រង់ហ្នឹង ។

[១១:៤០:២៣]

ដូច្នេះ ភាសាយើងប្រើវា វាមិនដូចគ្នា ។ ដូច្នេះ ការអប់រំវាទៅតាមទស្សនៈមនោគមវិជ្ជារបស់មនុស្សម្នាក់ៗ ។ ខ្ញុំជនកុម្មុយនីស្ត ខ្ញុំអប់រំតាមកុម្មុយនីស្ត ។ នេះសូមជម្រាបឲ្យចំ ឧក្រិដ្ឋគឺវានៅលើទស្សនៈរបស់ផ្តាច់ការវណ្ណៈអធន វាឧក្រិដ្ឋៗ ។ ខ្ញុំជាឧក្រិដ្ឋជនជំនាន់នុ៎ង ។

**ស៖** សូមអរគុណ ។ ដូច្នេះ ជាការត្រឹមត្រូវទេ ដែលខ្ញុំនិយាយថា អ្វីដែលលោកនិយាយថានៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំហ្នឹង គឺវាមានលក្ខណៈជាមនោគមវិជ្ជាជាងទាក់ទងទៅនឹងនយោបាយ មាគ៌ារបស់បក្ស ហើយអង្គប្រជុំជាមួយនិងកងអង្គភាពផ្សេងៗទៀតដែលកើតឡើងជាញឹកញាប់នោះ គឺជាពេល ដែលលោកធ្វើការពន្យល់អំពីការអនុវត្តជាក់ស្តែងនូវគោលនយោបាយរបស់បក្ស គឺគោលនយោបាយសម្លាប់របស់បក្សនោះ ។ តើអ្វីដែលខ្ញុំនិយាយហ្នឹងត្រឹមត្រូវដែរឬទេ?

[១១:៤១:១៧]

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសូមឆ្លើយដូចតទៅ បើនិយាយពីកងអង្គភាពផ្សេង មិនមែនកងអង្គភាពពីណាទេ គឺផ្នែកផ្សេងៗនៅក្នុងស-២១ ហ្នឹងខ្ញុំសូមបញ្ជាក់អ៊ីចឹង ។ ផ្នែកផ្សេងៗរបស់អង្គភាពស-២១ទាំងមូល មិនមែនទៅប្រមូលកងឯណាមកអប់រំរបស់គេទេ ។ គេគឺគេ ខ្ញុំគឺខ្ញុំ ដាច់ដោយឡែកពីគ្នា ។

សរុបមកវិញ កិច្ចការទាំងប៉ុន្មាន ខ្ញុំអប់រំ ខ្ញុំត្រួតពិនិត្យការអនុវត្ត ខ្ញុំតម្រង់ទិសការអប់រំ ខ្ញុំតម្រង់

ទិសការអនុវត្ត ។ នេះខ្ញុំសូមសរុបខ្លីប៉ុណ្ណេះ ហើយប្រហែលជាមិនត្រូវនឹងសំណួរលោកទេដឹង? ព្រោះសំណួរលោក ខ្ញុំភ្លេចវង្វេងៗបន្តិចបាត់ ហើយបើមិនត្រូវទេ សូមមេត្តាសួរម្តងទៀតមកចុះ ។

**ស៖** សូមអរគុណលោក កាំង ហ្កេកអ៊ាវ មុននឹងខ្ញុំបន្តទៅទៀតទាក់ទងទៅនឹងកិច្ចប្រជុំប្រចាំឆ្នាំនេះ ហើយនិងអ្វីដែលលោកបានធ្វើឡើងតាមភាពជាក់ស្តែង គឺលោកបាននិយាយអំពីការប្រជុំទៅតាមផ្នែកផ្សេងៗនៅក្នុងស-២១ នេះ ។ តើលោកអាចពន្យល់បានទេ? តើពេលប្រជុំប្រចាំឆ្នាំចាប់ផ្តើមនុ៎ង? តើលោកគឺជាអ្នកដែលបង្រៀននៅក្នុងអង្គប្រជុំនុ៎ងតែម្នាក់ឯងទេឬ និយាយអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមឆ្លើយដូចតទៅ៖ ក្នុងការបង្រៀនគោលនយោបាយនៅក្នុងមន្ទីរស-២១ ខ្ញុំបានបញ្ជាក់ច្រើនដងហើយ ខ្ញុំសូមបញ្ជាក់ម្តងនេះឲ្យច្បាស់ទៀតថា មានតែខ្ញុំទេដែលបង្រៀនគោលនយោបាយនៅមន្ទីរស-២១ ទាំងមូល ។

[១១:៤៣:១៨]

**ស៖** សូមអរគុណ ។ ដើម្បីធ្វើឲ្យបានច្បាស់នោះ គឺនេះនិយាយអំពីគោលនយោបាយគឺបង្រៀនគោលនយោបាយអំពីការសម្លាប់ ឬក៏ការកម្ទេចនោះ ។ តើត្រឹមត្រូវតែឬទេ?

**ឆ៖** គោលនយោបាយវាមានទាំងអស់ សំខាន់គឺគោលនយោបាយនៃផ្តាច់ការ ឬយុទ្ធវិធីយកឈ្នះខ្មាំងពីដំណាក់មួយទៅដំណាក់មួយដែលបក្សបង្រៀន ។ នេះជាគោលនយោបាយៗ ខ្ញុំមិនដោះទេ ខ្ញុំមិនប្រកែកទេ ក៏ប៉ុន្តែ ភាសាយើងវាប្រើទៅវាមិនដូចគ្នា ដូច្នេះ វាធ្វើឲ្យស្តាប់គ្នាពិបាក ។ យើងខ្ញុំដែលបង្រៀនរាល់ឆ្នាំ បង្រៀនហើយបង្រៀនទៀត ភាសារបស់ ប៉ុល ពត គាត់មានប្រសាសន៍ អ៊ីចេះ! គាត់ថា ដាវដែលមុតគឺ ដាវដែលប្រើ មិនមែនដាវដែលនៅក្នុងស្រោមទេ ។ ដូច្នេះ ដាវ ត្រូវតែកាប់ កាប់ហើយសំលៀង សំលៀងហើយកាប់ ។ ដូច្នេះ មិត្តយើងក្នុងអង្គភាពស-២១ ខ្ញុំរុញគេទៅអនុវត្តភារកិច្ចរបស់បក្សដែលដាក់មក គឺមាគ៌ាតស៊ូវណ្ណៈ ។ មើលទៅ នេះហើយខ្ញុំហៅយកមកបង្រៀនទៀត ដាវហ្នឹងខ្ញុំយកមកសំលៀង សំលៀងហើយខ្ញុំរុញយកទៅកាប់ទៀត ។ នេះការអប់រំវាទៅអ៊ីចឹង ។

ដូច្នេះ បើយើងនិយាយថា វាសម្លាប់អាហ្នឹងវាចូលទៅក្នុងករណីមួយដែលពិបាកយល់គ្នា ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**លោក វីលៀម ស្មីត៖**

**ស៖** សូមអរគុណ ។ តើលោកឯកភាពជាមួយនឹងខ្ញុំទេ បើសិនជាខ្ញុំនិយាយថា នៅក្នុងការអប់រំ

និងការបណ្តុះបណ្តាលនៅស-២១ ទាក់ទងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តនោះ គឺជាចំណុចសំខាន់បំផុត ហើយគឺសំខាន់ណាស់ដែលថា អគារមួយចំនួននោះត្រូវទុកមួយដុំសម្រាប់តែការអប់រំតែប៉ុណ្ណឹងទេ ហើយបើសិនជាខ្ញុំបន្តទៀតនុ៎ងលោកក៏បាននិយាយថា លោកបានទៅយកវិហារកាតូលិកមួយនៅក្បែរស-២១ ហើយសម្រាប់រយៈពេលប្រហែលជាពីរឆ្នាំ គឺមានបានធ្វើជាសាលារៀនមួយ។ បន្ទាប់មក គឺជាសាលាអប់រំនយោបាយសម្រាប់គោលបំណងក្នុងការបណ្តុះបណ្តាលបុគ្គលិករបស់ ស-២១ តើអ្វីដែលខ្ញុំលើកឡើងនេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ គឺខ្ញុំបានយកឈឺច, បាតឺឡេហ៊ឹម ឈ្មោះ ឈឺចបាតឺឡេហ៊ឹម យកមកប្រើជាកន្លែងបណ្តុះបណ្តាលមនោគមវិជ្ជាឲ្យអង្គភាពរបស់ខ្ញុំ ។ បន្ទាប់មក បានៗខ្ញុំមកធ្វើសាលាមួយតូចនៅក្បែរផ្ទះខ្ញុំ នៅផ្លូវលេខ៩៥ ។ វិហារ ឈឺចបាតឺឡេហ៊ឹម ក៏ខ្ញុំធ្វើ អាសាលាដែលខ្ញុំសង់ថ្មីក៏ខ្ញុំធ្វើ ប៉ុន្តែសាលាដែលសង់ថ្មី ខ្ញុំប្រើបានយូរជាងគេ ។ ដូច្នេះ ឈឺច ខ្ញុំប្រើជាសាលាអប់រំ ។

**ស៖** តើហេតុអ្វីបានជាមានការសម្រេចចិត្តក្នុងការកសាងសាលាបណ្តុះបណ្តាលនយោបាយនោះ? ហេតុអ្វីបានជាមិនប្រើផ្ទះដែលមាននៅក្នុងតំបន់អស់នុ៎ងទៅ ដូចដែលលោកប្រើផ្ទះផ្សេងៗសម្រាប់ការធ្វើ ការសួរចម្លើយនោះ?

**ឆ៖** សាលាខ្ញុំវានៅវាបនឹងដីទេ កម្ពស់ប្រហែលជាកន្លះម៉ែត្រពីដី ហើយដាក់មនុស្សបានប្រហែលជាហាហុកសិបនាក់ ។ ឯចំណែកផ្ទះវីឡាដែលនៅក្នុងបរិវេណស-២១ លោកជ្រាបហើយវីឡាមិនអាចដាក់ មនុស្សបានច្រើនទេ ហើយ ឈឺច បាតឺឡេហ៊ឹម នោះវានៅឆ្ងាយពីផ្ទះខ្ញុំ ។ ដូច្នេះ ពិបាកនឹងរឿងទូរស័ព្ទមេមករកខ្ញុំ ដូច្នេះ ខ្ញុំសុខចិត្តធ្វើសាលាមួយអំពីឈើថ្មី នៅក្បែរផ្ទះដើម្បីជិតទូរស័ព្ទពីខ្ញុំទៅមេ មេទៅខ្ញុំ ។

**ស៖** សូមអរគុណ ។ សាលាថ្មីដែលបានធ្វើឡើងនោះ គឺធ្វើឡើងនៅចំទល់មុខផ្ទះរបស់លោកតែម្តងដែលលោកអាចដើរទៅបានមែនទេ?

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសុំឆ្លើយនឹងសំណួរបន្តិចថា សាលាថ្មីនុ៎ងនៅខាងឆ្វេងផ្ទះខ្ញុំខណ្ឌតែមួយរបងទេៗ ។

[១១:៤៨:០៥]

**ស៖** លោកក៏បាននិយាយថា សាលានុ៎ងនៅក្បែរផ្ទះរបស់លោក ពីព្រោះលោកនឹងអាចត្រូវលើកឆ្លើយទូរស័ព្ទជាមួយនឹងនរណាគេម្នាក់ដែលលោកបាននិយាយនោះ គឺឬក៏លោកនិយាយទៅមេរបស់

លោក ដូចជា សុន សេន ជាដើម ។ តើហេតុអ្វីបានជាចំណុចជាការសំខាន់ដែលថា លោកត្រូវនៅក្បែរសាលារៀនបណ្តុះបណ្តាល ហើយនិងក្បែរផ្ទះនោះ ហេតុអ្វីបានជាផ្ទះរបស់លោកត្រូវនៅក្បែរសាលាបណ្តុះបណ្តាលនោះ?

**ឆ៖** ហ្នឹងវាជាទស្សនៈផលប្រយោជន៍ចំពោះមុខទេ វាជាផ្ទះ បើកាលណាមេហៅខ្ញុំ គឺលោកគ្រូ សុន សេន គាត់ហៅខ្ញុំ អ្នកកាន់ទូរស័ព្ទគេរត់ទៅហៅ ខ្ញុំរត់ចោលសាលាមកជួបមេមួយភ្លែតបានតាមចិត្ត ដូច្នេះ វាជាទស្សនៈផលប្រយោជន៍ចំពោះមុខទេ វាអត់មានអីទេ សូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ហើយលោកជាអ្នកសម្រេចនៅក្នុងការកសាងសាលារៀននៅក្បែរផ្ទះ របស់លោក តើមែនទេ?

**ឆ៖** អរគុណ ត្រឹមត្រូវហើយ ។

**ស៖** លោក កាំង ហ្កេកអ៊ាវ លោកដូចជានិយាយថា ការបណ្តុះបណ្តាលនោះដូចជាកើតឡើងជាញឹកញាប់ណាស់ បើមិនដូច្នេះទេ ជាការពិបាកក្នុងការប្រាស្រ័យទាក់ទង ធ្វើការទំនាក់ទំនងជាមួយនឹងលោក សុន សេន បើសិនជាសាលានុំងវានៅឆ្ងាយ ។ តើការបណ្តុះបណ្តាលនៅសាលារៀននោះវាញឹកញាប់របៀបណាទៅ?

**ឆ៖** អរគុណ លោកប្រធានជាទីគោរព! ខ្ញុំសូមឆ្លើយបញ្ជាក់នឹងសំណួរនេះដូចតទៅ៖

ខ្ញុំរឿងវាកន្លងទៅសាមសិបប្លាយឆ្នាំមកហើយ ដូច្នេះ ឯកសារដែលលោកព្រះរាជអាជ្ញាអាចមើលហើយយល់អំពីការបង្រៀនរបស់ខ្ញុំអំពីរបៀបសួរញឹកញាប់ប៉ុនណា គឺនៅក្នុងឯកសារបង ម៉ម ណៃ កំណត់ហេតុបង ម៉ម ណៃ ។ កំណត់ហេតុនេះ មានលេខ 00077611 ទៅដល់ 00078056ជាងបីរយទំព័រ ។ ដូច្នេះ នៅខាងចុងខ្ញុំអប់រំញឹកណាស់ មាននៅក្នុងនុំង ខ្ញុំអប់រំយ៉ាងម៉េច ស្តីយ៉ាងម៉េច បង ម៉ម ណៃ ចារទុកបានជាមូលដ្ឋានខ្លឹមសារដូចខ្ញុំអប់រំ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍ ផ្តាច់ប្រព័ន្ធរូបភាពជាមួយនឹងកុំព្យូទ័ររបស់តំណាងសហព្រះរាជអាជ្ញាវិញ ហើយភ្ជាប់មករូបភាពប្រក្រតីវិញ ។ សូមអញ្ជើញបន្ត លោកតំណាងសហព្រះរាជអាជ្ញា ។

[១១:៥១:០៥]

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** សូមអរគុណ។ លោក កាំង ហ្កេកអ៊ាវ យើង ខ្ញុំមិននិយាយអំពីឯកសារជាក់លាក់ណាមួយ

ទេ ប៉ុន្តែ ខ្ញុំគ្រាន់តែយោងអំពីទៅពាក្យសម្តីរបស់លោកដែលលោកបាននិយាយប្រាប់សហចៅក្រមស៊ើបអង្កេតនៅក្នុងដំណាក់កាលស៊ើបអង្កេត ដែលពួកគាត់បានសួរលោកនូវសំណួរលោកអស់ទាំងនោះ ។

ឥឡូវនេះ ប្រហែលជាយើងត្រូវនិយាយអំពីចំណុចផ្សេងក្រៅអំពីការហ្វឹក ការបណ្តុះបណ្តាលប្រចាំឆ្នាំ ដែលមានការពន្យល់ផ្សព្វផ្សាយអំពីគោលនយោបាយនៃការសម្លាប់មនុស្សនោះ ហើយនឹងយើងនិយាយ អំពីភាពញឹកញាប់អំពីការបណ្តុះបណ្តាលនៅ ស-២១ ។

លោកបានឆ្លើយប្រាប់មកអង្គសវនាការថា តាំងពីដំបូងមក នៅឯវិហាររបស់ បាតឺឡេហ៊ីម នោះសម្រាប់គោលបំណងក្នុងការបណ្តុះបណ្តាលកម្មាភិបាល ហើយនិងយុទ្ធជន ហើយលោកក៏បាននិយាយនៅថ្ងៃនេះផងដែរថា ក្រោយបន្តិចមកលោកបានធ្វើសាលាបណ្តុះបណ្តាលរៀនមួយនៅទល់មុខផ្ទះរបស់លោក ។ នៅពេលដែលលោកនិយាយថា សម្រាប់គោលបំណងនៃការអប់រំដល់កម្មាភិបាល និងយុទ្ធជន តើលោកចង់និយាយសំដៅទៅលើនរណាគេ? តើលោកនិយាយអំពីបុគ្គលិករបស់ស-២១ ឬ? ឬបានន័យថាលោកចាត់ទុកថា ពួកគាត់ហ្នឹងជាយុទ្ធជនដែរនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រឿងនេះវាដូចជាដដែលៗបន្តិចហើយ ។ ក៏ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ ព្រោះខ្លាចយើងស្តាប់គ្នាមិនបាន ។ ការប្រជុំ ការរៀនសូត្រប្រចាំឆ្នាំ ខ្ញុំប្រមូលមកច្រើន ដូច្នេះមានកម្មាភិបាល បក្ខជន មានបក្ខជន មានយុវកក ហើយនិងមហាជនសាមញ្ញក៏មានផងដែរ ឲ្យតែគេកាន់កាប់កិច្ចការផ្នែកណាមួយ នេះប្រចាំឆ្នាំ ។ ដោយឡែក ការអប់រំដែលញឹកញាប់បំផុត គឺខ្ញុំអប់រំពួកសួរចម្លើយ នេះយកតែពួកសួរចម្លើយមកទេ ហើយពួកសួរចម្លើយហ្នឹង ក៏ចោះយកមកមួយចំនួនដែរ មិនទាំងអស់ទេ គេហៅថាវ៉ៃរហ័ស ឈ្នះរហ័ស មានពេលឆក់បង្រៀនមួយម៉ោងពីរចប់ ហើយឲ្យគេទៅប្រតិបត្តិការវិញ ។ ដូច្នេះ ពួកសួរចម្លើយខ្ញុំដាក់អនុវត្តវិធី "វ៉ៃរហ័ស ឈ្នះរហ័ស" ។

**សៈ** សូមអរគុណ ។ អ៊ីចឹង សំណួរបន្ទាប់ទៀតហ្នឹង អាចពាក់ព័ន្ធទៅនឹងផ្នែកបន្តមកទៀតនៃសំណុំរឿង ប៉ុន្តែ ត្រង់ចំណុចនេះ នៅពេលដែលលោកនិយាយថា ការបណ្តុះបណ្តាល់ហ្នឹង គឺ វ៉ៃរហ័សឈ្នះរហ័ស ពីការបណ្តុះបណ្តាលនៅពេលព្រឹក ហើយបន្ទាប់មកយកមកអនុវត្តនៅពេលល្ងាច តើលោក

[១១:៥៤:០៩]

អាចពន្យល់ប្រាប់បានទេ មានន័យថាម៉េចទៅដែលថា "វ៉ៃរហ័ស ឈ្នះរហ័សនៅក្នុងការបណ្តុះបណ្តាលរបស់លោកនោះ តើលោកចង់និយាយសំដៅទៅលើអ្វី នៅពេលដែលលោកបង្រៀន ឬក៏និយាយប្រាប់អ្នកសួរចម្លើយអស់ទាំងនោះ?

**ឌ៖** ខ្ញុំៗប្រើពាក្យពីរម៉ាត់ហើយ ទីមួយដាវកាប់ហើយសំលៀង សំលៀងហើយកាប់ ដាវតែយកទៅកាប់ហើយវារិល ត្រូវតែសំលៀង ដូច្នេះ កម្មាភិបាលសួរចម្លើយរបស់ខ្ញុំ ក្នុងការអនុវត្តភារកិច្ច យើងហៅថា អនុវត្តភារកិច្ចអ៊ីចឹងទៅចុះ វាតែងតែធ្លាក់ទៅក្នុងសភាពមួយដែលគេមានឧបសគ្គ ដែលគេពឹងផ្អែកខាងលើឲ្យផ្តល់កម្លាំងមាគ៌ា កម្លាំងសតិអារម្មណ៍ឲ្យគេតទៅទៀត ។ ដូច្នេះ យើងត្រូវតែហៅគេ យកមករៀន កាលណារៀនហើយ គេបានចំណេះថ្មី ។ ខ្ញុំសូមនិយាយអញ្ចេះ តាមទស្សនវិជ្ជាដែលយើងខ្ញុំប្រើ “ពីប្រតិបត្តិទៅទ្រឹស្តី” កាលណាអ្នកឯងប្រតិបត្តិវាយល់ទ្រឹស្តីកាន់តែជ្រៅ ដល់កាលណាទៅនិយាយទ្រឹស្តីម្តងទៀត អ្នកឯងយល់ដល់ការប្រតិបត្តិកាន់តែជ្រៅ វាទៅជា ស្ពៀរាល់ មួយ វាទៅពីទ្រឹស្តីទៅប្រតិបត្តិ ពីប្រតិបត្តិទៅទ្រឹស្តី ។ ដូច្នេះ យើងខ្ញុំអនុវត្តវិធីហ្នឹងដែរ ដូច្នេះ វ៉ៃរហ័ស ឈ្នះរហ័សក៏មិនត្រូវ យើងយកអាវិធីទស្សនវិជ្ជាមកនិយាយវាដូចជាសមជាង ។ បានន័យថា មានពេលមួយម៉ោង យើងបង្រៀនមួយម៉ោង មានពេលកន្លះម៉ោង យើងបង្រៀនកន្លះម៉ោង ឆក់ឱកាសបានយើងបង្រៀនបង្រៀនក្នុងគោលបំណងអ៊ីចឹង ពីទ្រឹស្តីទៅប្រតិបត្តិ ពីប្រតិបត្តិទៅទ្រឹស្តី ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** ដូច្នេះជាការត្រឹមត្រូវទេ បើសិនជាខ្ញុំនិយាយថានៅស-២១ ជាពិសេសជាមួយនឹងខាងក្រុមសួរចម្លើយ លោកបានធ្វើឲ្យទ្រឹស្តីហ្នឹងក្លាយទៅជាប្រតិបត្តិ ហើយប្រតិបត្តិហ្នឹងក្លាយជាទ្រឹស្តីវិញ ។ ដូច្នេះ គឺលោកផ្តល់ដំបូលន្មានដល់ខាងអ្នកសួរចម្លើយហ្នឹង ដើម្បីឲ្យពួកគេទទួលបាននូវចម្លើយសារភាពពីអ្នកទោស ។

**ឌ៖** ពិតជាត្រូវហើយ សូមអរគុណ ។

**ស៖** សូមអរគុណ ។ លោកបាននិយាយថា ការហ្វឹកហ្វឺនជាច្រើនសម្រាប់អ្នកសួរចម្លើយហ្នឹងត្រូវបានធ្វើឡើងក្នុងក្រុមតូចៗ ឬក៏ដោយការធ្វើការជ្រើសរើសសម្រាប់ម្នាក់ៗ ប៉ុន្តែ ក្នុងពេលនុ៎ងដែរ គឺជាការសំខាន់ណាស់ដែលថា សាលាបណ្តុះបណ្តាលត្រូវបានធ្វើឡើងដែលអាចដាក់មនុស្សបានពីហាសិបទៅហុកសិបនាក់សម្រាប់ការបណ្តុះបណ្តាល ។ ដូច្នេះ ក្រៅពីការប្រជុំប្រចាំឆ្នាំ ដែលកើតឡើងតែម្តងក្នុង មួយឆ្នាំនោះ និងក្រៅពីការបណ្តុះបណ្តាលក្រុមតូចៗដូចនិយាយថា វាយរហ័ស ឈ្នះរហ័សសម្រាប់ពួកអ្នកសួរចម្លើយជាដើមហ្នឹង តើលោកមានការផ្តល់ការបណ្តុះបណ្តាលអ្វីទៀតទេ នៅសាលាថ្មី ដែលត្រូវការឲ្យលោកត្រូវការសាលារៀន ដែលមានទីធ្លាធំ អាចដាក់មនុស្សបានច្រើននោះ?

**ឌ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមឆ្លើយនឹងសំណួរនេះដូចតទៅ ៖

សាលានេះដាក់មនុស្សពេញតែនៅក្នុងការប្រជុំប្រចាំឆ្នាំទេ ។ ជាពិសេសពេលមេអញ្ជើញមកនុ៎ង

ខ្ញុំប្រមូលឲ្យបានច្រើន ជាអតិបរិមា យកទៅស្តាប់គាត់ ទទួលការអប់រំពីគាត់ ។ ក្រៅពីនោះ វ៉ែរហ័ស ឈ្នះរហ័ស តែប្អូនដប់នាក់ ប្អូន-ដប់ប្រាំនាក់ប៉ុណ្ណឹងទេ អាហ្នឹងរហ័ស មួយអាទិត្យម្តង ដប់ថ្ងៃម្តង កន្លះខែម្តង យ៉ាងយូរកន្លះខែម្តង រហ័សមួយម៉ោងម្តង ឬក៏ ហ៊ឺ! មិនដល់ពីរដង់ទេ ជាពិសេសមួយម៉ោងនេះសូមបញ្ជាក់ប៉ុណ្ណោះ ។ សូមចប់។

**ស៖** លោកបានផ្តល់នូវភាពញឹកញាប់នៃការបណ្តុះបណ្តាលសម្រាប់អ្នកសួរចម្លើយនៅសាលាថ្មី ដែលជួនកាលកើតមានឡើងម្តងក្នុងមួយសប្តាហ៍ ឬក៏ម្តងដប់ថ្ងៃ ឬក៏រៀងរាល់ពីរសប្តាហ៍ម្តង ។ អ៊ីចឹងតើខ្ញុំអាចនិយាយបានថា តើថានៅក្នុងកំឡុងពេលនៃប្រតិបត្តិការរបស់ស-២១ ឧទាហរណ៍ ឆ្នាំ១៩៧៦, ១៩៧៧, ១៩៧៨ នៅក្នុងកំឡុងពេលណាមួយហ្នឹង គឺមានការបណ្តុះបណ្តាលដល់អ្នកសួរចម្លើយម្តងជារៀងរាល់សប្តាហ៍នុ៎ង ដែលថាគេមានក្រុម ដែលពួកគេមានគ្នាពីប្រាំទៅដប់នាក់នោះឬ? ពីព្រោះគឺថាពេល ហ្នឹងលោកបានផ្តល់នូវជម្រើសពីរបីដែលលោកបាននិយាយនោះ?

**ឆ៖** សូមបញ្ជាក់ថា ការដែលខ្ញុំបង្រៀនញឹកញាប់ គឺញឹកញាប់មែនទែននៅឆ្នាំ១៩៧៨ៗ ។ ១៩៧៦ មិនដែលបានប្រមូលកម្មាភិបាលសួរចម្លើយមកបង្រៀនទេ ។ ចុង(១៩)៧៧ មានខ្លះ ប៉ុន្តែដែលញឹកញាប់មែនទែន(១៩)៧៨ ការងារកាន់តែមមាញឹក កាន់តែខ្ញុំត្រូវអប់រំអ្នកសួរចម្លើយកាន់តែច្រើនកាន់តែញឹកបន្តិច ។

**ស៖** លោកបាននិយាយថា នៅក្នុងការបណ្តុះបណ្តាលហ្នឹងវាមានភាពញឹកញាប់ខ្លាំងជាមួយអ្នកសួរចម្លើយនៅក្នុងឆ្នាំ១៩៧៧ ខ្ញុំសូមឲ្យលោកបញ្ជាក់ថាតើដោយសារចំនួននៃមនុស្សដែលចូលមកឃុំខ្លួននៅស-២១ នោះកាន់តែច្រើនជាងឆ្នាំ៧៦ និង៧៧ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះវាពឹងផ្អែកទៅលើចំនួនមនុស្សដែលចូលមក ខ្ញុំដូចមិនឃើញទាក់ទងនឹងបញ្ហានេះទេ រឿងដែលខ្ញុំហៅមកប្រជុំញឹកញាប់វាអាស្រ័យនឹងកត្តាពីរ កត្តាទីមួយខ្លួនខ្ញុំកាន់តែយល់ ចំណុចខ្លាំងនិងចំណុចខ្សោយនៃសភាពការណ៍ខ្មាំង តាមការឧទ្ទេសនាមរបស់បក្ស ។ ដូច្នេះ ការអប់រំនេះ វាទៅតាមសំណូមពរដែលបក្សត្រូវការ នេះជាបញ្ហាមួយសំខាន់ ។ វាមិនមែនពឹងអាស្រ័យទៅលើចំនួនអ្នកចូលមកជាអ្នកទោសៗដែលចូលមក យើងហៅអ្នកទោសអ៊ីចឹងទៅចុះដែលចូលមកទេ ។ ទីពីរ វាអាស្រ័យសភាពការណ៍ដែលបក្សត្រូវការមមាញឹក អ្នំាក បងឌុច អាត្រង់នេះ អ្នំាក បងឌុច អាត្រង់ណោះទៀត ។ ដូច្នេះ ដើម្បីជំរុញអាត្រង់ណោះ អាត្រង់ណោះ តាមសំណូមពររបស់បក្ស វាទាល់តែលេខាស-២១ ហៅអ្នកសួរចម្លើយមកអប់រំ ថែបំប៉ន ជំរុញថែមទៀត ។ នេះវា

របៀបហ្នឹង ។ សូមបញ្ចប់ ។

**ស៖** លោកនិយាយថាកាន់តែញឹកញាប់ហ្នឹង ប៉ុន្តែគឺថាលោកនិយាយអំពីការប្រជុំឬក៏ការបណ្តុះបណ្តាលដែលថាកាន់តែញឹកញាប់ក្នុងឆ្នាំដែលមាន?

**ឆ៖** ខ្ញុំមិនសូវបានប្រជុំ មកដល់និយាយទ្រឹស្តី បង្ហាញសភាពការណ៍ដាក់វិធានការ។ ការបង្រៀនអ្នកសួរចម្លើយលើកទ្រឹស្តីដាក់វិធានការ ។

**ស៖** សូមអរគុណលោកប្រធាន ។ ឥឡូវនេះ ម៉ោងដប់ពីលើសប្រាំនាទីហើយ តើលោកប្រធានចង់សម្រាក ឬក៏អនុញ្ញាតឲ្យខ្ញុំបន្ត ?

**ប្រធានអង្គជំនុំ៖**

យើងនឹងសម្រាកមិនបន្តទៀតទេ សូមអញ្ជើញ មុននឹងប្រកាសសម្រាកសូមអញ្ជើញ លោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវីន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំអាចថាអាចនឹងមានអត្ថប្រយោជន៍ ដើម្បីឲ្យយើងយល់ច្បាស់អំពីការពិភាក្សានេះថាតើលោកសហព្រះរាជអាជ្ញាលោកត្រូវការពេលប៉ុនណាទៀតដើម្បីសួរទៅជនជាប់ចោទទាក់ទងនឹងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានោះ ។

**លោក វីលៀម ស្មីត៖**

សំណួររបស់ខ្ញុំ គឺទាក់ទងទៅហ្នឹង អាស្រ័យទៅលើចម្លើយរបស់លោក កាំង ហ្កេកអ៊ាវ ដែលលោកបានធ្វើការបណ្តុះបណ្តាល ឬក៏ការវគ្គសិក្សា ខ្ញុំនឹងសួរបន្ថែមទៀតអំពីកិច្ចប្រជុំរបស់អង្គភាពតូចៗការផ្សព្វផ្សាយគោលនយោបាយ ហើយនិងកិច្ចប្រជុំទិតៀន ស្វ័យទិតៀន ដែលផ្សព្វផ្សាយពីគោលនយោបាយនោះដែរ ហើយដូចព្រឹកនេះ យើងឃើញហើយ ខ្ញុំអាចនឹងត្រូវការពេលមួយម៉ោងទៀត ប្រសិនជាលោកប្រធានអនុញ្ញាតខ្ញុំនឹងអរគុណ ប្រហែលជាមួយម៉ោងទៀត ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងដល់ម៉ោងត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អ៊ីចឹងគឺអង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញបន្តដំណើរការសវនាការតទៅទៀត ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ និងឲ្យនាំគាត់មកកាន់ទីនេះវិញនៅ

វេលាឲ្យបានមុនម៉ោងមួយសាមសិបនាទី ហើយភាគីដែលត្រូវចូលរួមសវនាការក៏ដូច្នោះដែរ សូមអញ្ជើញមកចូលរួមសវនាការនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។

*[សវនាការសម្រាកពីម៉ោង ១២:០៥នាទី ដល់ម៉ោង ១៣:៣៤ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាកាដេញដោលតទៀត ។ ហើយជាកិច្ចបន្តនេះសូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឡើងបន្តធ្វើសំណួរដល់ជនជាប់ចោទ អំពីអង្គហេតុដែលបានកំណត់ក្នុងការធ្វើការសវនាការនៅពេលនេះ ។ សូមអញ្ជើញ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំបានត្រៀមនៅក្នុងពេលសម្រាកនេះ ខ្ញុំសង្ឃឹមថាអាចនឹងបញ្ចប់ទាន់ពេល ។ ខ្ញុំសូមអនុញ្ញាតមើល D69 ជារូបថតរបស់លោក កាំង ហ្គេកអ៊ាវ ដើម្បីបង្ហាញនៅលើអេក្រង់ម្តងទៀត ដើម្បីខ្ញុំអាចនឹងសួរសំណួរ ដោយផ្តោតអារម្មណ៍ទៅតាមអ្វីដែលខ្ញុំឃើញនៅក្នុងរូបថត ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធកុំព្យូទ័រ មកជាមួយនឹងកុំព្យូទ័ររបស់សហព្រះរាជអាជ្ញាតាមការស្នើសុំរបស់សហព្រះរាជអាជ្ញានេះ ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** សូមអរគុណ ។ លោក កាំង ហ្គេកអ៊ាវ ខ្ញុំមានសំណួរបីបួនទៀតទាក់ទងទៅនឹងរូបថតនេះ។ ខ្ញុំមិនច្បាស់ទេលោកបញ្ជាក់ព្រឹកមិញនេះ ថាតើរូបថតនេះ ថតនៅក្នុងកិច្ចប្រជុំប្រចាំនៅក្នុងអង្គភាពស-២១ ឬក៏ថតនៅពេលណា រូបថតនេះ? តើរូបថតនេះត្រូវបានថតឡើងក្នុងពេលកិច្ចប្រជុំប្រចាំឆ្នាំ ឬពេលណាមួយ?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំសូមឆ្លើយដូចតទៅ ។ រឿងវាកន្លងទៅជាងសាមសិបប្លាយឆ្នាំមកហើយ រឿងល្អិតជាក់ស្តែងអ៊ីចឹងពិបាកណាស់ ប៉ុន្តែ ខ្ញុំសូមឆ្លើយតាមការវិភាគ និងតាមការ

សន្និដ្ឋាន ។ បើសិនជាថតនៅពេលដែលខ្ញុំបង្រៀនពួកសួរ ដូចជាមិនបានថតទេ ប្រហែលជាថតនៅក្នុងពេលបង្រៀនប្រចាំឆ្នាំ បានជាមានពេលថត ។ ដូច្នេះ ខ្ញុំសូមអស់ចម្លើយប៉ុណ្ណឹងឯង ។

[១៣:៣៧:១៦]

**ស៖** សូមអរគុណ ។ នៅពេលដែលលោកមិនធ្វើការបណ្តុះបណ្តាលប្រចាំឆ្នាំទេ តើការបណ្តុះបណ្តាលនៅក្នុងឆ្នាំ តើលោកពេលដែលលោកបង្រៀននៅក្នុងវគ្គបណ្តុះបណ្តាលអ្នកសួរ ហើយអ្នកផ្សេងទៀត តើលោកប្រើមីក្រូហ្វូនដែរឬទេ? ឬក៏មិនដែលប្រើមីក្រូហ្វូន?

**ឆ៖** ការរៀបចំសាលាថ្មីរបស់ខ្ញុំ មិត្តហ៊ី គេរៀបចំបានល្អដែរ ។ ដូច្នេះ ខ្ញុំប្រើមីក្រូរហ្វូត គ្នាប្អូនប្រាំនាក់ គ្នាប្អូនដប់នាក់ ខ្ញុំប្រើមេក្រូ ។ អ៊ុបប៉ាល័រ ដាក់ពីលើក្បាលមកនោះ ដាក់ពីលើក្បាលចុះមកក្រោម ។ ដូច្នេះ និយាយទៅវាមិនឮខ្លាំង ខ្ទរ លាន់កុងគ្នាអីទេ ។ ដូច្នេះហើយ តែប្រាំនាក់ខ្ញុំប្រើមីក្រូហ្វូន ។

**ស៖** សូមអរគុណ ។ លោកបាននិយាយអំពីឆ្នាំ១៩៧៨ គឺថា ការបង្រៀននោះ គឺថាញឹកញាប់ណាស់ ដោយសារថាតម្រូវការបក្សនុំង គឺត្រូវការ ។ អ៊ីចឹងហើយគឺថា ត្រូវមានអ្នកសួរចម្លើយពីប្រាំទៅដប់នាក់ត្រូវធ្វើឡើងក្នុងមួយអាទិត្យ ។ អ៊ីចឹងគឺថា អ៊ីចឹងនៅពេលដែលលោកបង្រៀនអ្នកសួរចម្លើយទាំងអស់នោះ លោកប្រើមីក្រូហ្វូទាំងអស់នឹងតាមរបៀបនឹង ដូចដែលក្នុងរូបថតនេះ ឬគឺជាវិធីដែលថាជាផ្លូវការគ្រប់ពេលអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** ឲ្យតើបង្រៀនខ្ញុំប្រើមីក្រូហ្វូនរហូត ។

**ស៖** សូមអរគុណ ចុះរូបថតដែលយើងបានឃើញនេះ នៅក្នុងអេក្រង់គឺថា D68 គឺជារូបភាពគំរូដែលថាលោកតែងតែបង្រៀនអ្នកនៅក្រោមបង្គាប់ តើលោកឯកភាពថាអ៊ីចឹងទេ គ្រប់ពេលទាំងអស់គឺរបៀបហ្នឹង? តើលោកឆ្លើយថា បាទ ឬក៏ទេ?

**ឆ៖** សូមទោស ត្រូវហើយៗ ។

**ស៖** សូមអរគុណ សាលាបណ្តុះបណ្តាលថ្មីនេះ ដែលថាបើដំណើរការ ហើយនៅជិតផ្ទះរបស់លោកនោះ ប្រហែលជារយៈពីរឆ្នាំមុនពេលដែលវៀតណាមចូលមកកាន់កាប់នោះ ។ ថាតើកិច្ចការនោះរវល់យ៉ាងដូចម្តេច? តើបង្រៀនរៀងរាល់ថ្ងៃទេ នៅក្នុងសាលារបស់លោកថ្មីនោះ?

**ឆ៖** ដូចបានខ្ញុំជម្រាបអ៊ីចឹង មិនបានរាល់ថ្ងៃទេ មួយអាទិត្យ ពីរអាទិត្យអីម្តង វាស្រេចនឹងមេគឿន ជួនអីគេគឿន មិត្តឌុច រវល់អានេះ រវល់អានោះ សភាពការណ៍វាអីចេះហើយ យើងត្រូវតែផ្សព្វ

ផ្សាយទៅឲ្យខាងក្រោមយល់មាគ៌ា ដើម្បីនឹងគេដំណើរការទៅទៀត ។ ដូច្នេះ ទៅតាមការចាំបាច់របស់ខាងលើ ។

[១៣:៤១:០៣]

**ស៖** អរគុណ ។ ប្រហែលជា សូមឲ្យជាក់លាក់ជាងនេះបន្តិច នៅពេលដែលលោកនិយាយអំពីពេលដែលរវល់ខ្លាំងក្នុងឆ្នាំ១៩៧៨ ។ តើមួយអាទិត្យប៉ុន្មានដង ដែលថាលោកប្រើសាលាបង្រៀនហ្នឹង ជាពេលវេលាដែលរវល់ជាងបំផុត ក្នុងន័យថា បណ្តុះបណ្តាលនិងវគ្គសិក្សានោះ?

**ឆ៖** ខ្ញុំនិយាយតាមស្មានទេណា៎ ខ្ញុំនិយាយតាមស្មានទេ ហើយឯកសារមានអាចជូនជាព័ត៌មានដល់លោកក៏បានដែរ បើចង់លោកឃើញ ។ ប៉ុន្តែ ខ្ញុំនិយាយតាមស្មានអាមួយអាទិត្យម្តង យ៉ាងឆាប់មួយអាទិត្យម្តងប៉ុណ្ណឹង ប៉ុន្តែយ៉ាងយូរកន្លះខែ មិនដល់មួយខែទេម្តង ។

**ស៖** សូមអរគុណ ។ ក្រៅពីអ្នកសួរចម្លើយដែលទទួលវគ្គបណ្តុះបណ្តាលនោះ តើអង្គភាពណាផ្សេងទៀត ឬក៏ពួកណាផ្សេងទៀត ដែលយកមកបណ្តុះបណ្តាលនៅក្នុងសាលានេះ ជាសាលាបណ្តុះបណ្តាលវគ្គនយោបាយហ្នឹង?

**ឆ៖** លោកប្រធានជាទីគោរព! មួយឆ្នាំម្តងប្រមូលទាំងអស់ ពីខាងព្រៃស ក៏ខ្ញុំប្រមូលយករបស់ខ្ញុំមកដែរ បង្រៀនគេ ។ ពីខាងព្រៃស ក៏ខ្ញុំយកមកដែរ ប៉ុន្តែដែលយកមួយភ្លែតៗ គឺមានតែពួកសួរទេ ពួកការពារអត់ទេ អត់បានឆក់យកមកទេ ។

**ស៖** សូមអរគុណ តើលោកនិយាយថា ក្រៅពីការបណ្តុះបណ្តាល ឬក៏វគ្គប្រជុំប្រចាំនោះ ការបណ្តុះបណ្តាល សាលាបណ្តុះបណ្តាលនេះ គឺប្រើសម្រាប់តែអ្នកសួរចម្លើយទេ នៅស-២១? ជាពិសេសខ្ញុំយោងទៅរកឆ្នាំ១៩៧៨ ដែលជាពេលរវល់ជាងគេ ។ ហើយក្រៅពីវគ្គប្រចាំឆ្នាំ តើអង្គភាពផ្សេងៗទៀតទេ គេប្រើសាលាហ្នឹងទេ ដូចជាខាងឯកសារ ក្រុមខាងសេដ្ឋកិច្ច ឬក្រុមខាងអ្នកយាម គេដែលប្រើអាគារហ្នឹងសម្រាប់ប្រជុំសិក្សាទេ?

**ឆ៖** អត់ទេ អត់មានទេ ។ ពួកអស់នេះមួយឆ្នាំគេមករៀនជាមួយនឹងខ្ញុំម្តង អាហ្នឹងមែន ។ ប៉ុន្តែដល់ក្រោយពីមួយឆ្នាំហើយម្តងមក គឺមានតែពួកសួរចម្លើយទេ ដែលរៀនជាមួយនឹងខ្ញុំញឹកញាប់ ដែលខ្ញុំហៅយកមករៀនញឹកញាប់ ។ ហើយសូមបញ្ជាក់ថា ពួកសួរចម្លើយដែលហៅមករៀនហ្នឹង គឺតាមការចាំបាច់ពីខាងលើ យើងចេះតែធ្វើទៅ ។

**ស៖** ដូច្នេះ តើអ្នកយាមគេទទួលការបណ្តុះបណ្តាលរៀនសូត្រនៅកន្លែងណា? ថាតើការបណ្តុះបណ្តាលពីមាគ៌ានយោបាយដល់ពួកអ្នកយាមនុ៎ងធ្វើនៅកន្លែងណាដែរ?

[១៣:៤៤:២៨]

**ឆ៖** អ្នកយាមក្រៅអំពីទទួលការអប់រំរៀនសូត្រពីខ្ញុំប្រចាំឆ្នាំ គេទទួលការប្រជុំរៀនសូត្រតាមក្រុមរបស់គេ ។ ឯកសារដែលនៅសល់នេះ ខ្ញុំឃើញរបៀបដែលមិត្តហ៊ី គេបង្រៀនគឺ មិនដឹងលេខប៉ុន្មានទេ ចំណងជើងគាត់ដាក់ "សារាចរ" ។ អានុ៎ង មិត្តហ៊ី គេបណ្តុះបណ្តាលអ្នកយាម អ្នកអី តាមឯកសារហ្នឹង សារាចរ ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំ តើការបណ្តុះបណ្តាលអ្នកយាមធ្វើនៅកន្លែងណា? តើគេទទួលការបណ្តុះបណ្តាលនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្មី ឬក៏នៅកន្លែងណាផ្សេងពីហ្នឹង?

**ឆ៖** ខ្ញុំមិនដឹងគេធ្វើនៅទីណាទេ អាហ្នឹង មិត្តហ៊ី គេធ្វើណា តែគេអត់មកបៀតបត់នៅសាលាខ្ញុំទេ មិត្តហ៊ី គេអត់មកបៀតបត់នៅសាលាខ្ញុំទេ ។ មិត្តហ៊ី គេអត់មកបៀតបត់នៅសាលាខ្ញុំទេ មិនដឹងគេធ្វើម្តងប៉ុន្មាននាក់ ខ្ញុំមិនដឹងដែរ ។ ខ្ញុំអត់ដឹងទេ តែឲ្យតែមិត្តហ៊ី បង្រៀន គេអត់បង្រៀនមាគ៌ាបក្សទេ គឺគេបង្រៀនបទបញ្ជាផ្ទៃក្នុង ដែលអ្នកយាមត្រូវអនុវត្ត ។

**ស៖** ប្រសិនបើលោកដឹងថា សាលាថ្មីហ្នឹង គឺអ្នកយាមមិនរៀនកន្លែងហ្នឹងទេ ឬក៏លោកមិនឹងគេរៀននៅកន្លែងណា? ឬក៏លោកមិនដឹង?

**ឆ៖** ទីមួយ កន្លែងខ្ញុំ មិត្តហ៊ី អត់ប្រើទេ ។ ទីពីរ គេប្រជុំគ្នាអាចបែងចែកជាពួកតូចៗ រៀនឯកសារសារាចរប៉ុននុ៎ងឯង គេធ្វើកន្លែងណា បើតាមខ្ញុំស្មានកន្លែងច្រើន តាមក្រុម រៀនសារាចររបស់មិត្តហ៊ី ដែលមិត្តហ៊ី ធ្វើនេះ ។

**ស៖** នៅពេលដែលលោកនិយាយថាលោកគិតថាអ៊ីចឹង តើលោកដឹង ឬក៏លោកគ្រាន់តែសន្និដ្ឋានថាអ៊ីចឹង?

**ឆ៖** អរគុណៗ ។ សំណួរនេះខ្ញុំសូមឆ្លើយថាខ្ញុំសន្និដ្ឋានទេ ព្រោះការរៀនសូត្រវាត្រូវតែមានក៏ប៉ុន្តែគេអត់បានមកអង្គុយនៅកន្លែងខ្ញុំទេ មកប្រើសាលាខ្ញុំទេ សាលាខ្ញុំសម្រាប់តែខ្ញុំ ។

**ស៖** ដូច្នេះ តើត្រូវទេដែលយើងនិយាយថាសាលាបណ្តុះបណ្តាលនោះ គឺនៅជិតផ្ទះរបស់លោក ហើយគឺសាងសង់ឡើងគឺសម្រាប់គោលបំណងការបណ្តុះបណ្តាលអ្នកសួរចម្លើយរបស់លោក គឺមិនប្រើសម្រាប់ការប្រជុំប្រចាំរបស់ស-២១ ទេ? តើត្រូវទេនិយាយអ៊ីចឹង?

[១៣:៤៧:៣០]

**ឆ៖** ត្រូវបានមួយកំណាត់ ។ ប្រជុំប្រចាំរបស់ស-២១ ខ្ញុំដឹកនាំ ដូច្នេះនៅសាលាហ្នឹង ។ ប្រជុំប្រចាំឆ្នាំ ស-២១ នៅ-- ខ្ញុំដឹកនាំ ដូច្នេះវានៅហ្នឹងសាលានុ៎ង ។

**ស៖** ប៉ុន្តែដើម្បីឱ្យច្បាស់ មិនមានអ្នកណាម្នាក់អាចនឹងរៀបចំការបណ្តុះបណ្តាលនៅសាលាហ្នឹងក្រៅពីកិច្ចប្រជុំប្រចាំឆ្នាំទេ? អ៊ីចឹងត្រូវទេ?

**ឆ៖** ត្រូវៗ ។

**ស៖** ហើយក៏ត្រូវទេ បើយើងនិយាយថា លោកមិនដឹងមានកន្លែងណាផ្សេងទៀតដែលគេប្រើសម្រាប់បណ្តុះបណ្តាលអង្គភាពតូចៗ នៅក្នុងស-២១ នោះ?

**ឆ៖** ខ្ញុំមិនដឹងទេ ប៉ុន្តែបើនិយាយពីកន្លែងវាត្រូវតែមានច្រើន ។ សម្រាប់ក្រុមមួយ ពួកមួយរបស់គេ គេរើសកន្លែងឯករាជ្យរៀងខ្លួន ។

**ស៖** ហើយលោកចៅក្រមអាចនឹងបង្គាប់ដករូបភាពចេញពីអេក្រង់បាន លោកប្រធាន ។ ខ្ញុំចង់ឱ្យកាន់តែច្បាស់បន្តិចទៅទៀត ។

**ប្រធានអង្គជំនុំ៖**

ខាងសោតទស្សន៍សូមផ្តាច់ប្រព័ន្ធរូបភាព ហើយធ្វើជាប្រកតីភាពឡើងវិញ ។

**លោក វីលៀម ស្មីត៖**

**ស៖** សូមអរគុណ លោក កាំង ហ្គេកអ៊ាវ ហើយដើម្បីឱ្យលោកច្បាស់ដែរថាការពាក់ព័ន្ធរបស់លោកនៅក្នុងការបណ្តុះបណ្តាល ។ តើលោកបានបណ្តុះបណ្តាល តើលោកខ្លួនឯងជាអ្នកបណ្តុះបណ្តាលអ្នកណាម្នាក់ ឬក្រុមណាផ្សេងនៅខាងក្រៅមជ្ឈមណ្ឌលកន្លែងបណ្តុះបណ្តាលហ្នឹងទេពិសេសនោះ?

**ឆ៖** ខ្ញុំគ្រប់គ្រងទាំងស្រុងតែអង្គភាពស-២១ ទេ ។ ដូច្នេះ មួយឆ្នាំម្តងបុគ្គលិករបស់ខ្ញុំទាំងនៅភ្នំពេញ ទាំងនៅព្រៃសមករៀនជាមួយនឹងខ្ញុំ ឯចំណែកអង្គភាពឯណាឯណីនោះ ខ្ញុំមិនដឹងទេរឿងគេជារឿងគេ ។

**ស៖** ប៉ុន្តែ បើសិនជាលោកត្រូវឆ្លើយរបស់ខ្ញុំដោយផ្ទាល់នោះ តើលោកមានផ្តល់ការហ្វឹកហ្វឺនបណ្តុះបណ្តាលនៅខាងក្រៅនុ៎ងទៀតដែរឬទេ?

**ឆ៖** សាលាខ្ញុំមានតែពីរកន្លែងទេ ។ *ឈើច* បាតីឡេហឹម ហើយនិងសាលាដែលខ្ញុំដាក់អក្ស *អ៊ី (E)* ក្បែរផ្ទះខ្ញុំ ខាងឆ្វេងផ្ទះខ្ញុំ តែពីរហ្នឹង ។ អ៊ូ!សុំទោស មានមួយពេលនោះ ខ្ញុំចូលទៅដល់ព្រៃស ទៅបង្រៀននៅព្រៃស ។

**ស៖** ហេតុអ្វីបានជាលោកសម្រេចចិត្តឲ្យអ្នកសួរចម្លើយមករៀនជាមួយនឹងលោក ជាជាងលោកទៅហ្វឹកហ្វឺននៅកន្លែងដែលគេសួរចម្លើយតែម្តងនោះ? ហើយអ្វីបានជាលោកសម្រេចចិត្តជ្រើសរើសដូច្នេះ?

**ឆ៖** យើងហៅគេមក ម្តងបានបួនប្រាំនាក់ បួនដប់នាក់ ហើយបើខ្ញុំទៅកន្លែងគេ គេរវល់ការងារសួរ យើងទៅធ្វើយ៉ាងម៉េច?

**ស៖** លោកប្រធានសូមទោស ខ្ញុំកំពុងតែពិនិត្យមើលឯកសារមួយភ្លែត ។

លោក កាំង ហ្គេកអ៊ាវ លោកបានធ្វើសេចក្តីសម្អាសជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺលេខ D72 ។

**អ្នកបកប្រែ៖**

សូមឲ្យលោកសហព្រះរាជអាជ្ញា គាត់អានលេខERN វិញឡើងវិញម្តងទៀត ញាប់ពេកស្តាប់អត់ទាន់ទេ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ សូមអានលេខ ERN នូវឯកសារអំមិញឲ្យបានយឺតដើម្បីមានការបកប្រែបាន ។

**លោក វីលៀម ស្មីត៖**

**ស៖** សូមទោសលោកប្រធាន គឺមាន 00204284 ឯកសារនេះគឺមានលេខ D72 ។ នៅក្នុងឯកសារហ្នឹងលោកបានពន្យល់ថា បុគ្គលិករបស់ស-២១ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ៧៨ ថា ស-២១ គឺដើម្បីស្វែងរកខ្មាំងជនជាតិវៀតណាមតាមចម្លើយសារភាព ។ តើលោកមានចាំនូវការប្រជុំជាមួយបុគ្គលិករបស់លោកអំពីចំណុចនេះទេ?

[១៣:៥៣:៣០]

**ឆ៖** លោកប្រធានជាទីគោរព! មុននឹងខ្ញុំឆ្លើយបញ្ហានេះ ខ្ញុំសូមអាន D72 ហ្នឹង ។ ខ្ញុំសូមឲ្យខាងមេធាវីការពារគេប្រគល់ D72 ជាភាសាខ្មែរឲ្យខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត ។ មេធាវីការពារផ្តល់ឯកសារតាមការស្នើសុំរបស់ជនជាប់ចោទ ។

**លោក វីលៀម ស្មីត៖**

លោកប្រធាន! នៅពេលដែលគាត់កំពុងតែរៀបចំពិនិត្យឯកសារហ្នឹងគឺខ្ញុំមានសួរមួយចំនួនទៀត ប្រហែលជាអាចនឹងបញ្ចប់បាននៅក្នុងអំឡុងពេលនេះ ។

**ជនជាប់ចោទ៖**

លោកព្រះរាជអាជ្ញាជាទីគោរព! ត្រង់ឃ្លាណាមួយដែលលោកចង់សួរខ្ញុំ ក្នុង D72 នេះ សូមលោកមេត្តាបញ្ជាក់ម្តងទៀត ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វីលៀម ស្មីត៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ ខ្ញុំអត់មានលេខយោងរបស់ឯកសារនេះជាភាសាខ្មែរទេ ។ ប៉ុន្តែអត្ថបទទាក់ទងទៅនឹងចម្លើយដែលលោកបានផ្តល់ទៅឲ្យសហចៅក្រមស៊ើបអង្កេតនិយាយអំពី នៅក្នុងវគ្គបណ្តុះបណ្តាលស-២១ ហ្នឹង គឺស-២១ ត្រូវបានចាត់តាំងឲ្យរុករក ស្រាវជ្រាវរកភ្នាក់ងារវៀតណាមតាមរយៈចម្លើយសារភាព តែខ្ញុំអត់មានលេខយោងជាភាសាខ្មែរទេនៅពេលនេះ ។

**ឆ៖** លោកនិយាយទំព័រជាភាសាអង់គ្លេសទំព័រ អាទំព័រ មិនមែន*ERN* ទេ ទំព័រធម្មតា ។

**ស៖** គឺលេខ00204284 ។ លោកប្រធាន ប្រសិនយើងអាចបន្តទៅមុខទៀតដើម្បីទុកឱកាសនេះយើងរកលេខទំព័រឲ្យបានត្រឹមត្រូវទាក់ទងនឹងឯកសារនេះ ហើយពេលហ្នឹងខ្ញុំនឹងសួរទៅលើជនជាប់ចោទម្តងទៀត ។

សូមអរគុណលោក កាំង ហ្គេកអ៊ាវ ឥឡូវខ្ញុំនឹងព្យាយាមស្វែងយល់រកលេខយោងសម្រាប់លោក តែក្នុងពេលនេះ យើងបន្តទៅដល់ប្រធានបទមួយទៀត គឺប្រធានបទទាក់ទងទៅនឹងអង្គប្រជុំទិតៀន និងស្វ័យទិតៀន ដែលតម្រូវដោយលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ។ បើជាសេចក្តីសង្ខេប ខ្ញុំចង់និយាយទៅលើសំណួររបស់លោក ហុង គីមសួន ដែលបានសួរពីមុនទាក់ទងទៅនឹងការធ្វើអង្គប្រជុំទិតៀន និងស្វ័យទិតៀននៅមន្ទីរស-២១ ។

នៅក្នុងប្រតិចារឹកទំព័រទី៥ ថ្ងៃទី១៨ ខែមេសា គឺបាននិយាយថា នៅក្នុងប្រជុំនុំងគឺមានលោក

មាន ហ៊ា ហើយនិង ហ៊ុយ ដែលបានជួបពីរអាទិត្យម្ដង ហើយបានធ្វើកិច្ចប្រជុំទិតៀននិងស្វ័យទិតៀន ។ ក៏ប៉ុន្តែលោកក៏បាននិយាយដែលថា ដោយទៅបន្ទុកការងារ និងដោយសារការជឿទុកចិត្តទៅវិញទៅមក គឺរវាង ហ៊ា ហើយនិង ហ៊ុយ ហើយដោយសារលោកស្អប់ការប្រជុំបែបនេះណាស់ លោកមិនបន្តធ្វើកិច្ចប្រជុំបែបហ្នឹងទៀតទេ ។ ក៏ប៉ុន្តែ ជាសំខាន់នោះ គឺលោកនិយាយថា គឺយើងធ្វើតិទៀត និងស្វ័យទិតៀនគ្នាទៅវិញទៅមកទៅតាមករណីនីមួយៗ គឺអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងបីហ្នឹង ធ្វើអ្វីកុំធ្វើកំហុសអ្វីមួយនោះ គឺយើងត្រូវប្រាប់ទៅវិញទៅមក ហើយនេះគឺជាទម្លាប់ដែរអនុវត្តដោយក្រុមរបស់លោកនេះ ។

តើលោកអាចប្រាប់អង្គសវនការបានទេ ថាតើកិច្ចប្រជុំទិតៀន និងស្វ័យទិតៀននេះមានចំនួនប៉ុន្មានដងដែលលោកបានធ្វើជាមួយ ហ៊ា ហើយនិង ហ៊ុយ? ហើយនៅពេលដែលលោកសម្រេចឈប់នោះ តើឈប់នៅពេលណា?

**ឆ៖** ចម្លើយដែលខ្ញុំឆ្លើយទៅលោក គឹមសួន ការបកប្រែយ៉ាងម៉េច ខ្ញុំមិនទាន់ប៉ានថាទេ ។ ក៏ប៉ុន្តែខ្ញុំសូមរំឭក ការអនុវត្តនៅមន្ទីរស-២១របស់ខ្ញុំជូន ។ ខ្ញុំ មិត្តហ៊ា ហើយមិត្ត ហ៊ុយ គេហៅថាគណៈកម្មាធិការស-២១ ។ អាគណៈម្មាធិការមន្ទីរនេះ វាទិតៀនគ្នាជាស៊ីជម្រៅនៅពេលរៀនសូត្រឯណោះ ។ ដែលមេហៅទៅ ហើយខ្ញុំមានពេលទិតៀនគ្នាទៅវិញទៅមក គឺនៅពេលនុំងឯង ។ នេះក្នុងគណៈកម្មាធិការគឺវាតិទៀនគ្នានៅពេលនុំង ហើយដល់យើងមកនៅនេះ បើកសន្និបាត ឬក៏រៀនសូត្រប្រចាំឆ្នាំឲ្យខាងក្រោមគេធ្វើទេ ។ នេះម្យ៉ាង ។ ម្យ៉ាងទៀតបក្ខជនជាទូទៅ គេមានសាខារបស់គេ កន្លះខែគេទៅទិតៀន ស្វ័យទិតៀនគ្នាម្ដង អានេះជាទៀងទាត់ ។ ឯចំណែកយើងខ្ញុំទាំងបីនាក់ ខ្វាត់ខ្វែងរកគ្នាសួរយោបល់គ្នាជាប់ជានិច្ច ។ ក៏ប៉ុន្តែប្រជុំទិតៀន ស្វ័យទិតៀនមិនដែលបានធ្វើ ។

ដូច្នេះ ខ្ញុំសូមរំឭកបញ្ហានេះឡើងវិញ តាមការយើងខ្ញុំអនុវត្តនៅពេលនុំង ។ គណៈកម្មាធិការផ្សេង បក្ខជនទូទៅគេប្រជុំគ្នា កន្លះខែម្ដងផ្សេង ឯកចំណែកគណៈកម្មាធិការរបស់ខ្ញុំ គ្នាបីនាក់នេះទិតៀនគ្នានៅពេលសន្និបាត ។

[១៤:០១:៣៩]

**ស៖** បើសិនជាខ្ញុំយោងទៅលើអ្វីដែលលោកបាននិយាយជាមួយនឹងលោក ហុង គឹមសួន លោកបាននិយាយថា ប្រសិនបើអ្នកណាម្នាក់ក្នុងចំណោមពួករបស់លោកហ្នឹងមានកំហុសនោះ គឺលោកបានប្រាប់គ្នាទៅវិញទៅមក ។ អ៊ីចឹងបានន័យថា ទាល់តែមានកំហុសទើបបានមានការធ្វើទិតៀន និងស្វ័យទិតៀននោះ តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ហ្នឹងភាសាខ្មែរដែលខ្ញុំធ្លាប់ប្រើ ការដែរយូរៗជួបគ្នាគេប្រើពាក្យស្រាល គេមិនតែងប្រើពាក្យទិតៀននិងស្ងួយទិតៀនផនទេ ។ គេប្រើពាក្យជួនមតិ ឬក៏រំឭកគ្នា ។ ជួនមតិគ្នា ឬរំឭកគ្នាអ៊ីចឹងតែប៉ុណ្ណឹងឯង ។ និយាយមួយម៉ាត់មួយកប្រាប់គ្នាទៅ ញឹកណាស់អារឿងនុំង ញឹកណាស់ ។ នេះសូមជម្រាបដោយត្រង់អ៊ីចឹង ។

**ស៖** សូមអរគុណ លោកក៏បាននិយាយថា បើលោកមិនបានធ្វើការប្រជុំជាផ្លូវការជារៀងរាល់ពីរសប្តាហ៍ម្តងនោះទេ ពីព្រោះអីលោកជឿចិត្ត ទុកចិត្តគ្នាទៅវិញទៅមក ។ តើមានដំណើរការយ៉ាងម៉េចទៅដែលធ្វើឲ្យលោក ហ៊ី ហើយនិង ហ៊ុយ ហ្នឹងទុកចិត្តគ្នាទៅវិញទៅមកនោះ? តើហេតុអ្វីដែលបណ្តាលឲ្យលោកមានការទុកចិត្តគ្នាទៅវិញទៅមកនោះ?

**ឆ៖** សូមបញ្ជាក់ថា មូលហេតុមានច្រើន ដល់សួរប្រចុចញ៉ុចអ៊ីចឹង ខ្ញុំសូមឆ្លើយខ្លីៗតាមការដែលនឹងឃើញ ។ សូមជម្រាបលោកព្រះរាជអាជ្ញាថា ខ្ញុំ និងមិត្តហ៊ី ជាប់គុកជាមួយគ្នានៅឆ្នាំ១៩៦៨ នៅព្រៃស ។ កាលណោះមិត្តហ៊ី នៅជាយុវកក ។ ខ្ញុំជាបក្ខជនត្រៀម ហើយយើងរួមគ្នាធ្វើការពីនុំងមកក៏ស្គាល់ចិត្តស្គាល់ថ្លើមគ្នា ។ ចំណែកដល់ក្រោយមកចាប់តាំងពីឆ្នាំ១៩៧៥ យើងខ្ញុំជួបគ្នាឡើងវិញក្នុងគណៈកម្មាធិការស-២១ ហ្នឹង ។ ដូច្នេះ ក្នុងការធ្វើការងារ ខ្ញុំមិនជឿថាអ្នកណាធ្វើការងារចង់ស្លាប់ទេ ។ ដឹងទាំងអស់គ្នាហើយថា បើយើងលួចដោះលែងខ្មាំង គឺយើងស្លាប់ទាំងពីរនាក់ គ្មានអ្នកណារស់ទេ ។ ដូច្នេះហើយ ចេះតែជឿទុកចិត្តគ្នាទៅ ។ ឯចំណែកមិត្តហ៊ុយ ជាមនុស្សថ្មី មិត្តហ៊ុយ, នុន ហ៊ុយ ជាមនុស្សថ្មី ។

ខ្ញុំទើបនឹងជួប ភពប្រសព្វជាមួយ នុន ហ៊ុយ នៅពេលដែលធ្វើស-២១ នេះ ។ ក៏ប៉ុន្តែ នុន ហ៊ុយ នេះគេជិតស្និតជាមួយនឹងមិត្តហ៊ី ក្នុងរយៈកាលធ្វើសង្គ្រាមប្រឆាំងជាមួយ លន់ នល់ គេស្គាល់គ្នា ។

ដូច្នេះ ការដែលជឿទុកចិត្តគ្នាទៅវិញទៅមកតាមរយៈ មិត្តហ៊ី ដែរៗ ។ ដូច្នេះ ធ្វើឲ្យយើងខ្ញុំទាំងអស់គ្នាហ្នឹង ជឿទុកចិត្តគ្នា ។ ដោយឡែក ខ្ញុំសូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាថែមទៀត បង ម៉ម ណៃ គាត់ទៅជាប់គុកជាមួយនឹងខ្ញុំពីហុកសិបប្រាំបីដែរ ។ អ៊ីចឹង បង ម៉ម ណៃ និង មិត្តហ៊ី ក៏ស្គាល់គ្នា ។ ដូច្នេះ វាទាំងអស់គ្នាហ្នឹង វាជឿទុកចិត្តគ្នាអ៊ីចឹង ។

**ស៖** សូមអរគុណ ។ លោកប្រធានសូមដាក់បង្ហាញឯកសារលេខ E3,28 គឺជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលខ្ញុំចង់ដាក់បញ្ចាំង ហើយក្នុងភាសាខ្មែរមានលេខ 00050307 ដែលជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ដែលឯកសារនេះយោងអំពីកាតព្វកិច្ចរបស់សមាជិកបក្សដើម្បីអនុវត្ត

នូវការចូលរួមទិតៀននិងស្វ័យទិតៀនជារៀងថ្ងៃជាមួយនឹងក្រុមរបស់ខ្លួន ។ ហើយខ្ញុំនឹងសូមដកស្រង់បន្តិចថា គោលការណ៍ជាចម្បងនៅក្នុងការសិក្សានយោបាយរបស់នៅក្នុងអំឡុងពេលនៃការកសាងបដិវត្តសង្គមនិយមនោះ គឺគោលការណ៍សង្គមនិយមដែលលក្ខន្តិកៈបានលើកឡើងបាននិយាយថា បក្សកុម្មុយនីស្តកម្ពុជា គឺធ្វើប្រជុំទិតៀននិងស្វ័យទិតៀនជារៀងរាល់ថ្ងៃ នេះជាមធ្យោបាយមួយដើម្បីធ្វើការតស៊ូកសាងសង្គម ឬកសាងបក្សផ្ទៃក្នុង និងដើម្បីលុបបំបាត់នូវកំហុសនិងការភ័ន្តច្រឡំផ្សេងៗទៀតនៅខាងក្នុងជួរបក្ស ។ ហើយដើម្បីជំរុញ និងពន្លាត ពង្រីកនូវគុណភាពរបស់បក្សឲ្យរីកចម្រើនជារៀងរហូត ។

លក្ខន្តិកៈក៏បានបន្តទៀតនូវក្នុងមាត្រាទីពីរដែលបាននិយាយអំពីតួនាទីរបស់សាមជិកបក្ស ហើយបានចែងថា ជាសំខាន់នោះគឺសមាជិករបស់បក្សត្រូវតែព្យាយាមអនុវត្តការប្រជុំទិតៀននិងស្វ័យទិតៀនជារៀងរាល់ថ្ងៃ ។ តើលោកមានបានដឹងអំពីកាតព្វកិច្ចនេះទេនៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា? ហើយតើលោកមានបានដឹងអំពីកាតព្វកិច្ចនេះទេ នៅក្នុងអំឡុងពេលនោះ?

**ឆ៖** លោកប្រធានជាទីគោរព! ដំបូងខ្ញុំសូមអានលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៧៦ ជាភាសាខ្មែរ ។ ពីរ) ភារកិច្ចផ្ទៃក្នុង៖

ក) មានជីវភាពក្នុងអង្គការសាខាបក្សមួយទៀងទាត់មួយខែម្តង ។

សូមជម្រាបថា នៅពេលដែលយើងខ្ញុំនៅជាបក្ខជនធម្មតានៅម-១៣ មិនមែនស្ថិតនៅក្នុងគណៈកម្មាធិការបក្ស ។ មួយខែៗយើងខ្ញុំរត់មកប្រជុំជិះកង់មកច្រើនគីឡូដែរ ពីអមលាំងមកក្រាំងបេងឃុំពាម មិនដឹងជាប៉ុន្មានគីឡូសាមសិបសែសិបអីក៏មិនដឹង ។ ត្រូវតែមក នេះជាទៀតទាត់ ។

[១៤:០៩:១០]

នៅពេលដេលយើងខ្ញុំទាំងពីរនាក់ទាំងបីនាក់នៅក្នុងគណៈកម្មាធិការបក្សលក្ខខណ្ឌការងារដឹកនាំប្រជុំជីវភាពរយាលបន្តិចមែន ។ ដូច្នេះ វាប្រែពីប្រជុំជីវភាពទៀតទាត់ប្រចាំខែ វាមកជាការជួយមតិគ្នាមួយម៉ាត់មួយក នៅពេលណាដែលឃើញបញ្ហាភ្លាមៗ ។ ក៏ប៉ុន្តែមួយឆ្នាំ នៅពេលធ្វើសន្និបាតចៀសពីជួយមតិគ្នាសរុបគ្នាម្តងមិនរួចទេ ត្រូវតែជួយ នេះជារឿងពិត ។

**ស៖** សហព្រះរាជអាជ្ញាលោក កាំង ហ្គេកអ៊ាវ ខ្ញុំសូមឲ្យលោកអានមាត្រាទីពីរចំណុច “ច” នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ។

**ឆ៖** ឥឡូវ ចំណុច “ក” យើងឯកភាពគ្នាហើយត្រូវប្រជុំជីវភាពទៀងទាត់មួយខែម្តង ។

ឥឡូវចំណុច “ច” ខិតខំអនុវត្តទិតៀននិងស្វ័យទិតៀន របបត្រួតពិនិត្យជីវទស្សនបដិវត្តន៍ឲ្យបាន

ត្រឹមត្រូវហ្មត់ចត់និងសកម្ម ដើម្បីកសាងខ្លួននិងផ្ទៃក្នុងបក្សឲ្យបានជាគំរូល្អ ។ សកម្មជាបើជានិច្ចក្នុងកិច្ចការការពារប្រទេសនិងកសាងកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយម ។

លោកប្រធានជាទីគោរព! អង្គសវនាការជាទីគោរព! លក្ខន្តិកៈបក្សជាឯកសារមួយដែលខ្ញុំភ័យណាស់ត្រូវតែមើលញឹកញាប់ជាប់ជាប្រចាំ ។ យកខ្លួនឯងទៅប្រៀបផ្ទឹមនឹងឯកសារជាប់ជានិច្ច ។ មិត្តផ្សេងទៀតនៅក្នុងគណៈកម្មាធិការរបស់យើងខ្ញុំក៏គេគិតអ៊ីចឹង នេះប្រភពដែលយើងខ្ញុំអនុវត្តជាប់លាប់។ នៅក្នុងនេះអត់មានពាក្យថា ប្រចាំថ្ងៃ ឬប្រចាំខែទេ ក៏ប៉ុន្តែ យើងខ្ញុំខំណាស់នូវលក្ខន្តិកៈហ្នឹងខំណាស់ បើមិនខំប្រយ័ត្នតែប្រហែសបន្តិចវាមានគ្រោះថ្នាក់ដល់ខ្លួន ។ ដូច្នេះ ការប្រៀបផ្ទឹមទស្សនៈរបស់ខ្លួនទៅនឹងទស្សនៈដែលមានចែងក្នុងបក្ស វាមានជាប់ជាប្រចាំលក្ខន្តិកៈខ្ញុំអត់ដែលដាច់ទេ បើទង់បក្សបដិវត្តន៍ខ្ញុំដាច់ខ្លះបាន តែលក្ខន្តិកៈខ្ញុំអត់ដែលប៉ានដាច់ទេនៅមានជាប់ជាប្រចាំរបស់ខ្ញុំ ។ នេះសូមបញ្ជាក់ជូនតែប៉ុណ្ណឹង គឺមើល អាន ផ្ទៀងផ្ទាត់ជានិច្ច ជាពិសេសអារម្ភកថាទីមួយ ដំណាក់កាលនិងគោលជំហរនយោបាយជាមូលដ្ឋានរបស់បក្សក្នុងរយៈកាលថ្មីនៃបក្សបដិវត្តន៍សង្គមនិងកសាងសង្គមនិយម ។ កសាងមហាជននោះ ខ្ញុំគិតអាហ្នឹង ។ ជាពិសេស កសាងខ្លួនឯង ខ្ញុំគិតអារម្ភខាងដើមនេះ ខ្លាំងណាស់ ខ្លាំងជាងអាអ្វីទាំងអស់ ព្រោះថានឹងហើយ វាកំណត់ឲ្យយើងរស់នៅបាន វាកំណត់ឲ្យយើងជ្រុះ វាកំណត់ស្លាប់វាកំណត់ឲ្យយើងរស់ ។ ហ្នឹងសូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាប៉ុណ្ណេះ សូមអរគុណ ។

**ស៖** សូមអរគុណ ។ ប្រហែលជានេះ ខ្ញុំអាចផ្អាកត្រឹមណេះសិន ហើយនឹងអាចសួរសំណួរថាតើលោកឯកភាពឬមិនឯកភាពទៅលើចម្លើយលើកមុន ។ តើលោកយល់ស្របជាមួយខ្ញុំទេគោលការណ៍ជាមូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជា លក្ខន្តិកៈនៅក្នុងកថាខណ្ឌទី៧ មាត្រា២(ច) នោះតម្រូវឲ្យសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាឲ្យៗធ្វើកែ កសាងកែលម្អគ្នាទៅវិញទៅមកជារៀងរាល់ថ្ងៃ ។ តើលោកឯកភាពទេចំណុចនេះ?

[១៤:១៣:៣៨]

**ឆ៖** គេបកប្រែ គេដឹង លោកព្រះរាជអាជ្ញា រឿងបកប្រែគេដឹង ខ្ញុំសូមអានហើយឲ្យគេបកប្រែឲ្យស្រួល ។

(ច) ខិតខំអនុវត្តរបបទិតៀននិងស្វ័យទិតៀន របបត្រួតពិនិត្យជីវទស្សនៈបដិវត្តន៍ឲ្យបានត្រឹមត្រូវ ហ្មត់ចត់ ដើម្បីកសាងខ្លួននិងផ្ទៃក្នុងបក្សឲ្យបានគំរូល្អ សកម្មប្រយុទ្ធជាប់ជានិច្ចក្នុងកិច្ចការការពារ

ប្រទេសនិងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ ដូច្នេះ លក្ខន្តិកៈត្រង់ប្រការ (ច) នេះ វាតម្រូវជាកាតព្វកិច្ចឲ្យលក្ខន្តិកៈគ្រប់រូបខំជាប់ជាប្រចាំដល់ពេលណាជួបជុំគ្នារៀនសូត្រ អាហ្នឹងយើងបកស្រាយឲ្យវាភ្លឺស្វាង ឲ្យវាច្បាស់ កុំឲ្យដល់អាពេលប្រជុំរៀនសូត្រយើងអត់បានគិតសោះ ស្រាប់តែកេលេងខ្លាំងៗមក នោះយើងច្រឡោត ។ នេះការអនុវត្តចំណុច (ច) គឺនៅត្រង់ហ្នឹង ។ មិនមែនគេកំណត់ប្រចាំថ្ងៃ មិនមែនគេកំណត់ប្រចាំខែ ក៏ប៉ុន្តែ យើងខ្ញុំភ័យខ្លាចជ្រុះត្រូវតែមើលទស្សនៈ លោកទស្សនៈបដិវត្តន៍ និងជីវទស្សនៈបដិវត្តន៍ជាប់ជាប្រចាំ ដល់ពេលទៅរៀនជាមួយគ្នាយើងលាតត្រដាងឲ្យគេ ដើម្បីឲ្យគេទិតៀន ។

**ស៖** ប៉ុន្តែ ក្នុងករណីក៏ដោយ លោកផ្ទាល់ ហ៊ា ហើយនិង ហ៊ុយ គឺថាតែងតែធ្វើកិច្ចប្រជុំជាទៀងទាត់ ហើយបានឈប់មួយរយៈ ហើយក៏ក្រោយមក គឺគ្រាន់តែរិះគន់គ្នាទៅវិញជាធម្មតាក្នុងការងារ ។ តើមែនឬទេ?

[១៤:១៥:៤០]

**ឆ៖** លោកព្រះរាជអាជ្ញា ប្រចាំឆ្នាំយើងខ្ញុំជួបគ្នាចៀសមិនរួច ត្រូវតែជួបគ្នា ។ ប្រចាំខែ ប្រចាំអាទិត្យ ជួបគ្នាញឹកញាប់តាមការចាំបាច់ ។ សូមបញ្ជាក់ថា ពីស-២១ ភ្នំពេញ ទៅស-២១ ព្រៃស វាមានតេអូមួយសម្រាប់ទាក់ទងគ្នា ។ ចង់ជួបមិត្ត ហ៊ុយ ខ្ញុំហៅមក ឲ្យគេតេអូហៅមក ។

**ស៖** អរគុណ ។ ប្រហែលសំណួរចុងក្រោយមួយទាក់ទងនឹងប្រធានបទនេះ ទាក់ទងទៅនឹងកិច្ចប្រជុំប្រចាំឆ្នាំរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំយោងទៅរកសេចក្តីថ្លែងការណ៍ដែលលោកបានផ្តល់ទៅសហចៅក្រមស៊ើបអង្កេត គឺថា D29 តើត្រូវទេដែលថា លោកបានចូលរួមកិច្ចប្រជុំបួនក្នុងអង្គភាពយោធាជាមួយ សុន សេន តើត្រឹមត្រូវទេ?

**ឆ៖** សូមឲ្យលោកចៅក្រមឲ្យលោកព្រះរាជអាជ្ញាអានឃ្លានុ៎ងពេញលេញ ដើម្បីឲ្យខ្ញុំបានយល់ផង ។

**ស៖** ខ្ញុំនងនិយាយឲ្យខ្លីជាងនេះ ។ លោកបានចូលរួមថា តើបានចូលដែរឬទេ គឺថាកិច្ចប្រជុំអប់រំនយោបាយសម្រាប់យោធាក្រោមការដឹកនាំរបស់ សុន សេន នៅឆ្នាំ១៩៧៥ នៅឆ្នាំ១៩៧៦, ១៩៧៧ និងឆ្នាំ១៩៧៨ តើត្រឹមត្រូវទេ? បាទឬក៏ទេ?

**ឆ៖** អរគុណ ។ ឆ្នាំ១៩៧៥ ឆ្នាំ១៩៧៦ ឆ្នាំ១៩៧៧ យើងខ្ញុំទៅរៀនដោយមានលោកគ្រូ សុន សេន ជាអ្នកឧទ្ទេសនាមឯកសារ នេះមែន ។ ដោយឡែក ឆ្នាំ១៩៧៨ លោកគ្រូ សុន សេន មេខ្ញុំហើយ

និងពួកអង្គភាពយោធាគេទៅសមរភូមិមុខអស់ហើយ នៅភ្នំពេញគ្នាពួកយោធាអីជាធំដុំទេ ។ ពេលនោះ ខ្ញុំទៅរៀនដោយមានលេខាបក្ស ប៉ុល ពត ជាអ្នកឧទ្ទេសនាមឯកសារ។ លេខាបក្ស ប៉ុល ពត មិនដែលចុះមកឧទ្ទេសឲ្យកម្មាភិបាលមធ្យមទេ តែឆ្នាំនេះគាត់តម្រូវឲ្យខ្លួនគាត់ចុះមកឧទ្ទេសនាមឯកសារឲ្យកម្មា-ភិបាលមធ្យម ។ ដូច្នេះ ឆ្នាំ១៩៧៨ ប៉ុល ពត មិនមែន សុន សេន ទេ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង គឺថាយើងច្បាស់ហើយនៅក្នុងឆ្នាំ១៩៧៥ ហើយនិងឆ្នាំ១៩៧៦ ការអប់រំនយោបាយនោះ គឺត្រូវបានធ្វើឡើងនៅជិតស្ដាតអូឡាំពិក ។ តើត្រូវទេ?

**ឆ៖** អរគុណ ។ ការអប់រំនយោបាយនៅឆ្នាំ១៩៧៥ នៅឆ្នាំ១៩៧៦ នៅតារាងបាស់ស្កេតនៃពហុកីឡាដ្ឋានជាតិអូឡាំពិក ដល់ឆ្នាំ១៩៧៧ មនុស្សកាន់តែច្រើនលោកគ្រូ សុន សេន មេខ្ញុំ លែងយកតារាងបាស់ស្កេតហើយ គាត់ក៏យកអាស៊ីទេ រៀងដូចដំបូលទូកហ្នឹង អគារនៅក្បែរនុ៎ង ដែលរៀងដូចដំបូងទូកមកបង្រៀនវិញ ។ នេះតាមពិតគឺមានប្រែបន្តិចកន្លែងហ្នឹង ក៏ប៉ុន្តែ មេនៅដដែលទេ អ្នកឧទ្ទេសនាមឯកសារ គឺ សុន សេន ។

[១៤:២០:០៤]

**ស៖** នៅក្នុងឆ្នាំ១៩៧៨ នៅពេលដែលលោកចូលវគ្គនយោបាយដែល ប៉ុល ពត ជាអ្នកឧទ្ទេសនាមនោះ នៅក្នុងវេទកានោះនៅក្បែរមាត់ទន្លេនៅភ្នំពេញ ឬក៏នៅកន្លែងណា?

**ឆ៖** អរគុណ ។ ទីតាំងច្បាស់កន្លែងនុ៎ង គេហៅថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ហ្នឹងទីតាំងច្បាស់លាស់ ឈ្មោះច្បាស់លាស់របស់វាគឺ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅក្បែរមាត់ទន្លេមែន ។ បើតាមខ្ញុំចាំអាផ្លូវកាត់មុខនោះ គេហៅថា ផ្លូវដុកទ័រហាន់ ។

**ស៖** សូមអរគុណ ហើយលោកបានបញ្ជាក់ប្រាប់សហចៅក្រមស៊ើបអង្កេតថា ថាប៉ុល ពត បានមកខ្លួនឯង ហើយផ្ដល់វគ្គមេរៀននយោបាយទៅដល់ប្រធាននៃក្រុមអង្គភាពតូចៗ រាប់ទាំងស-២១ ហើយនិងឃ្លាំងរដ្ឋ ហើយក្រុមកាត់ដេរ ។ ហើយគាត់ក៏បានផ្ដល់វគ្គបណ្ដុះបណ្ដាលទៅដល់ក្រុមធំគឺថាសង្គមកិច្ច ហើយនិងសុខាភិបាល ហើយលោកបានបញ្ជាក់ថា ហើយគាត់ក៏បាន លោកបានបញ្ជាក់ថា ប៉ុល ពត បានមកជាមួយ នួន ជា, អៀង ធីរិទ្ធ មកជួបជាមួយសាធារណជន ហើយលោកនៅទីនោះ ជាមួយហ៊ីរ ។ តើត្រូវទេកន្លែងនេះ?

**ឆ៖** ព្រះរាជអាជ្ញាជាទីគោរព! អ្នកដែលមកបង្រៀន គឺមានតែ បងប៉ុល ទេ បងនួន ពូនួន គាត់អញ្ជើញមកជាអ្នកអម បងប៉ុល នេះអ្នកបង្រៀនមានតែពីរនាក់ទេ ។ ចំណែក អៀង ធីរិទ្ធ, យន់

យ៉ាត, ជួន ជឿន, ឌី ផុន ហៅ ធុក, ខ្ញុំ, មិត្តហ៊ី, មិត្តហ៊ុយ បីនាក់នេះ ហើយនិងពួកអ្នកកាត់ដេរ ពួកមិត្តរឿង, ឃ្លាំងវ័ត្ន អីសុទ្ធតែជាកូនសិស្ស ។ ហើយសូមបញ្ជាក់ថា អ្នកទៅរៀនទាំងប៉ុន្មានសុទ្ធតែជាបក្ខជនធម្មតា មិនមែនជាសមាជិកមជ្ឈិម ។ ខ្ញុំនិយាយនេះចង់បញ្ជាក់ថា ពេលនុ៎ង ធីរិទ្ធ នេះក៏ដោយ យន់ យ៉ាត នេះក៏ដោយ មិនទាន់ចូលមជ្ឈិមទេ អត់មានអ្នកណាមួយជាសមាជិកមជ្ឈិម ព្រោះមករៀនជាមួយនឹងមនុស្សប៉ុនខ្ញុំនេះ ដែលមិនមែនជាសមាជិកមជ្ឈិម ។

**ស៖** តើកិច្ចប្រជុំនោះប្រើពេលអស់ប៉ុនណាដែរ ដែលប៉ុល ពត មកធ្វើឧទ្ទេសនាមក្នុងឆ្នាំ១៩៧៨ នោះ?

**ឆ៖** លោកព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំមិនចង់ប្រើពាក្យកិច្ចប្រជុំទេ តែកាលណាកិច្ចប្រជុំ គឺយើងខ្ញុំមានមតិទន្ទឹមគ្នាប៉ុន ប៉ុល ពត មកដល់យើងខ្ញុំគិតតែពីឱនក្បាលកត់ ។ ដូច្នេះ ប៉ុល ពត គាត់អ្នកបង្រៀន យើងខ្ញុំជាអ្នកកត់ ធីរិទ្ធ ជាអ្នកកត់ យន់ យ៉ាត ជាអ្នកកត់ ដុកទ័រ ជួន ជឿន ជាអ្នកកត់ ហ៊ី ជាអ្នកកត់ ហ៊ុយ ជាអ្នកកត់ ដូច្នេះ គាត់បង្រៀន អត់មានយើងខ្ញុំធ្វើប្រជុំជាមួយនឹងគាត់ទេ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។ យើងរៀនឯកសារយ៉ាងតិចបីថ្ងៃ ។ ក្រោយមក យើងខ្ញុំទៅប្រជុំគ្នាពិភាក្សាឯកសារប្រហែលជាបីថ្ងៃទៀត បានយើងខ្ញុំទៅប្រជុំគ្នាសរសេរប្រវត្តិរូប យើងខ្ញុំបំបែកគ្នាទៅសរសេរប្រវត្តិរូបបដិវត្តហើយនិងជីវទស្សនៈបដិវត្តន៍ដាច់ដោយឡែក ។ ដល់ចុងបញ្ចប់ យើងខ្ញុំប្រជុំគ្នាម្តងទៀតឆ្លងប្រវត្តិរូប នេះរបៀបរៀនសូត្រ គឺអ៊ីចឹង នេះសូមបញ្ចប់ប៉ុណ្ណឹង ។ ទាំងអស់បូកសរុបទៅ ពេលនុ៎ងប្រហែលជាប្រើពេលដប់ថ្ងៃ។ ដប់ថ្ងៃនេះ បងប៉ុល គាត់អញ្ជើញមកប្រហែលជាបីថ្ងៃ ដល់ចុងបញ្ចប់គាត់អញ្ជើញមកមួយថ្ងៃទៀត បិទវគ្គចប់ ។

[១៤:២៤:១២]

**ស៖** តើកិច្ចប្រជុំប្រចាំឆ្នាំ នៅឆ្នាំ១៩៧៨ហ្នឹង តជាប់ៗគ្នាឬក៏ឈប់មួយចុងសប្តាហ៍ ហើយតវិញនៅសប្តាហ៍ថ្មីមួយទៀត?

**ឆ៖** អរគុណ ។ ជាប់គ្នា ហើយពីបទឧទ្ទេសនាម យើងខ្ញុំបំបែកគ្នាតាមក្រុមពិភាក្សាឯកសារ។

**ស៖** តើលោកផ្ទាល់បានជួប ប៉ុល ពត ដោយផ្ទាល់ទេនៅក្នុងកិច្ចប្រជុំនោះ ហើយបាននិយាយផ្ទាល់ទៅរកគាត់ក្នុងពេលណាមួយទេ?

**ឆ៖** សូមបញ្ជាក់ថា គេមានពិធីការរបស់គេច្បាស់លាស់ ។ នៅក្នុងពេលរៀនក៏ដោយ គេមិនមកនិយាយជាមួយនឹងឯកជនណាម្នាក់ទេ នេះជាពិធីការដែលគេប្រកាន់ ។ សូមបញ្ជាក់ថា រហូតដល់ថ្ងៃ

០៧ មករា ១៩៧៩ ដែលយើងខ្ញុំរត់ចោលភ្នំពេញ ខ្ញុំជួប ប៉ុល ពត តែក្នុងមីទ្ទិងថ្ងៃ១៧ មេសា ថ្ងៃ៣០ កញ្ញា ថ្ងៃ០៦ មករា ១៩៧៨ នេះម្តងទៀត នៅពេលដែល ប៉ុល ពត គាត់ធ្វើបុណ្យអបអរជ័យជម្នះរបស់កងទ័ពខ្មែរទៅលើកងទ័ពយៀកណាមហ្នឹងម្តង ។ ហើយដល់ចុងបញ្ចប់ យើងខ្ញុំមករៀនវគ្គជាមួយនឹងគាត់ម្តងនេះ ទៀតជាពិសេសប្លែក គ្រប់ពេលវេលា យើងខ្ញុំនៅចម្ងាយពី ប៉ុល ពត ប្រហែលជាដប់ម៉ែត្រ អ្ហ៎!មិនដល់ទេ ប្រហែលពីលោកប្រធានមកខ្ញុំ ហើយគេប្រកាន់ពិធីការរបស់គេ គេអត់និយាយចូលអ្នកណាទេ និយាយចូលមួយ មួយទៀតតូចចិត្ត អានេះគេរក្សាពិធីការរបស់គេអ៊ីចឹង ។

**ស៖** គឺថា ការកុំឲ្យមានការច្រណែនដោយអ្នកណាទៀត ដោយសារគាត់ជា ដោយគេស្អប់បក្សកុម្មុយនីស្តកម្ពុជា ឬក៏ក្នុងន័យដូចម្តេច?

**ឆ៖** អរគុណៗៗ ។ ពេលនុ៎ង ក្នុងបក្សរបស់យើងខ្ញុំអ្នកដែលគោរពបក្ស ចង់ហើយ ចង់ជួប ប៉ុល ពត ទទួលការណែនាំពីគាត់ដោយផ្ទាល់ ។ ដូច្នេះ បើគាត់មកជួបខ្ញុំ អ្នកផ្សេងទៀត គេមើលលើ មើលក្រោមហើយ ដោយគាត់ទៅជួប ធីរិទ្ធ ប្អូនថ្លៃគាត់អ្នកដទៃទៀត ក៏គេមើលលើ មើលក្រោមដែរ ដូច្នេះ គាត់មិនជួបនរណាទាំងអស់ ដោយឡែក នេះសូមបញ្ជាក់ប៉ុណ្ណឹង ។

[១៤:២៧:២០]

**ស៖** តើខ្ញុំយល់លោកច្បាស់ទេត្រូវទេ នៅក្នុងឆ្នាំ១៩៧៨ លោកបានទៅកន្លែងហ្នឹង គឺថាប៉ុល ពត វត្តមាន ជួប ប៉ុល ពត ប្រហែលជាបីប្អូនដង តើលោកចាំកាលបរិច្ឆេទជាក់លាក់ ថាតើកាលបរិច្ឆេទជាក់លាក់ទាំងនោះ នៅក្នុង៧៨ ឬក៏ក្នុងឆ្នាំណាដែរ ?

**ឆ៖** ៧៨ និយាយពី ៧៨ ដែលខ្ញុំជួប ប៉ុល ពត ថ្ងៃ០៦ មករា ម្តង ប្រហែលជាមួយព្រឹកទេ ។ ពេលនោះ ប៉ុល ពត គាត់ធ្វើពិធីបុណ្យរំឭកជ័យជំនះរបស់កងទ័ពខ្មែរ ទៅលើកងទ័ពវៀតណាមដែលវ៉ៃចូលទឹកដីខ្មែរ ។ ខ្ញុំមិននិយាយជម្រៅដល់ទៅខ្លឹមសារដែលគាត់ឧទ្ទេសនាមពេលនោះទេ ខ្ញុំរំឭកតែព្រឹត្តិការណ៍ ដល់មកក្រោយមក ខ្ញុំបានទៅរៀនជាមួយនឹងបងប៉ុល ម្តងទៀតនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ខ្ញុំសូមបញ្ជាក់ ថយក្រោយបន្តិចទៅវិញ ពេលដែលបងប៉ុល គាត់ធ្វើបុណ្យរំឭកកងទ័ពរបស់គាត់នោះ នៅថ្ងៃ០៦ មករា នេះ មិនមែននៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតទេ នៅបុរីកីឡា នៅសាលមួយធំនៅបុរីកីឡា។ ដល់ទីពីរ ខ្ញុំមករៀនជាមួយនឹងគាត់ គឺរៀននៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។ ហ្នឹង ដល់ក្រោយមក ខ្ញុំទៅធ្វើបុណ្យបក្សនៅកីឡាដ្ឋានអូឡាំពិក ត្រង់តារាងបាស្កេត គាត់ជាអធិបតីនៃពេលបុណ្យនុ៎ង ។ អ៊ូ! ភ្លេចអង្គាល់ពីថ្ងៃ១៧ មេសា ខ្ញុំជួបគាត់ម្តងទៀត គាត់ធ្វើបុណ្យរំឭកជ័យជម្នះ១៧ មេសា នៅ

កីឡាដ្ឋានជាតិអូឡាំពិកតែម្តង មនុស្សនៅហ្នឹង តារាងបាល់ទាត់នុំងទាំងអស់ ។ ដូច្នេះ មួយឆ្នាំ៧៨ ហ្នឹង ខ្ញុំជួប បងប៉ុល។ ម្តងនៅ ៦មករា ។ ម្តងទៀតនៅ ១៧មេសា ម្តងទៀតពេលដែលខ្ញុំទៅរៀន ហើយម្តងទៀតពេលបុណ្យខួបបក្ស ខ្ញុំឃើញមុខគាត់ប្អូនដងពីចម្ងាយ មិននិយាយជួបទេ និយាយថា ឃើញមុខប្អូនដងពីចម្ងាយ នេះនិយាយឲ្យត្រូវពាក្យ ត្រូវសកម្មភាព ។

**ស៖** ហើយទាំងប៉ុន្មានដង ដែលថាលោកបានជួបហ្នឹង តើមានពេលណាមួយដែលលោកបានជួបនៅស-២១ ទេ ឬក៏តែងតែនៅខាងក្រៅស-២១ នោះ?

**ឆ៖** ដឹកនាំ ថ្នាក់ដឹកនាំ ដែលចូលទៅស-២១ មានតែម្នាក់ទេ គឺមេខ្ញុំ លោកគ្រូ សុន សេន គាត់អញ្ជើញទៅ មើល៎ ដូចបីដង ដឹងប្អូនដងមិនដឹងទេ ភ្លេចហើយ ច្រឡំ ។ ហ្នឹងមានតែមួយហ្នឹងគត់ដែលអញ្ជើញទៅ ។ ឯចំណែក អ្នកផ្សេងទៀតអត់ទេ គ្មានអ្នកណាគេទៅទេ ។

**ស៖** សូមអរគុណ ខ្ញុំមានសំណួរមួយពីរទៀត ។ ខ្ញុំចង់យោងទៅលើការប្រជុំប្រចាំឆ្នាំ ដែលចំណាយពេលរយៈពេលដប់ថ្ងៃ នៅក្នុងឆ្នាំ១៩៧៨នោះ ។ តើរយៈពេលដប់ថ្ងៃហ្នឹង នៅពេលណា នៅដើមឆ្នាំ៧៨ ឬក៏នៅកណ្តាលឆ្នាំ៧៨ ឬក៏នៅចុងឆ្នាំ៧៨? ខ្ញុំមិនចង់ឲ្យលោកធ្វើការទស្សន៍ទាយទេ ប៉ុន្តែ ខ្ញុំចង់ឲ្យគិតរំឭកមើលឡើងវិញ ។

[១៤:៣១:១៨]

**ឆ៖** នៅឆមាសទីពីរ ១៩៧៨ គឺនៅក្រោយដែលគេដេញចាប់បង សោ ភឹម ហើយបង សោ ភឹម ធ្វើអត្តឃាតនោះ ។ ចប់អារឿងហ្នឹងមួយសន្ទុះ ប៉ុល ពត គាត់ហៅខ្ញុំទៅបង្រៀន ទាំងអស់គ្នានោះ ហៅទាំងអស់គ្នាទៅបង្រៀន ។

**ស៖** អញ្ចឹងលោកនិយាយថា នៅឆមាសទី២ គឺលោកនិយាយក្រោយខែកក្កដា ឆ្នាំ៧៨ មែនទេ?

**ឆ៖** ប្រាកដ ។

**ស៖** មុនហ្នឹងក៏លោកបាននិយាយថា មានសមាជិកបក្សខ្លះហ្នឹងនឹងច្រណែន បើសិនជាមានសមាជិកបក្សណាមួយជួបជាមួយប៉ុល ពត នោះ ។ តើលោកគិតថា នឹងជាកិត្តិយសទេ ដែលមានមុខនៅចំពោះវត្តមានរបស់ ប៉ុល ពត នៅក្នុងកិច្ចប្រជុំ ឬក៏នៅក្នុងវគ្គរៀនសូត្រជាមួយគាត់នេះ?

**ឆ៖** សូមជម្រាបដោយស្មោះត្រង់ថា នៅពេលនោះវាមានការប្លែកក្នុងអារម្មណ៍បន្តិចដែរ រៀនជាមួយនឹងបុគ្គលទី៧ បីឆ្នាំហើយ ឥឡូវមករៀនជាមួយនឹងបុគ្គលទី១ ឆ្នាំនេះ ដូច្នេះក្នុងអារម្មណ៍ខ្ញុំពេលនោះពិតជាប្លែក ប៉ុន្តែ ប្លែកយ៉ាងម៉េចលែងនឹកឃើញហើយ ។

**ស៖** តើពេលហ្នឹងគឺថា លោកមានអារម្មណ៍ល្អទេ ដែលមានវត្តមាននៅចំពោះមុខរបស់គាត់នោះ?

**ឆ៖** ប្លែកហ្នឹង គឺប្លែកមករកផ្លូវអារម្មណ៍ល្អហ្នឹងឯង ប្លែក ។

**លោក វីលៀម ស្មីត៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំអត់មានសំណួរបន្តទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ គឺសូមជូនវេទិកាហ្នឹងទៅ មេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយលើកនេះគឺចាប់ផ្តើមពី មេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយមុន បើសិនជាមានសំណួរពាក់ព័ន្ធគឺសូមអញ្ជើញ ។ ហើយមុននឹងសួរសូមអង្គជំនុំជម្រះសួរទៅមេធាវីក្រុមមួយ ថាតើលោកមានផែនការប៉ុនប៉ងក្នុងការប្រើពេលវេលាប៉ុន្មាន ដើម្បីតាំងសំណួរដល់ជនជាប់ចោទ ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលកំពុងតែដេញដោលនេះ?

[១៤:៣៤:២៣]

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន! ដើម្បីឆ្លើយសំណួររបស់លោកជាការពិបាកណាស់ ពីព្រោះគឺអាស្រ័យទៅលើការឆ្លើយរបស់ជនជាប់ចោទទៅលើសំណួរនីមួយៗ ។ ខ្ញុំនឹងព្យាយាមបើសិនជាខ្ញុំអស់ពេលខ្ញុំនឹងកាត់បន្ថយសំណួររបស់ខ្ញុំ គឺថាខ្ញុំព្យាយាមមិនឲ្យនិយាយលើសពីមួយម៉ោងទេ ក្នុងករណីណាក៏ដោយ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ។

[១៤:៣៥:០០]

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ សួស្តីជនជាប់ចោទ! ខ្ញុំចង់ចាប់ផ្តើមទាក់ទងទៅនឹងភស្តុតាង និងសក្ខីកម្មមួយចំនួនដែលអ្នកជំនាញ អេតធេសាន់ បានផ្តល់នូវមុនពេលដែលយើងបានឈប់សម្រាកនោះ។ ហើយសម្រាប់មេធាវី គឺខ្ញុំមានលេខរបស់ប្រតិចារឹកគឺនៅថ្ងៃព្រហស្បតិ៍ ទី២៨ ខែឧសភា ឆ្នាំ២០០៩ និងប្រតិចារឹកព្រាងជាភាសាអង់គ្លេសនុ៎ង គឺមាននៅទំព័រទី១៨ និងទី១៩ នៃប្រតិចារឹកនោះ ហើយលោកអេតធេសាន់ បានផ្តល់សក្ខីកម្មថា បន្ថែមទៅលើការព្រាងនូវចម្លើយសារភាពជនជាប់ចោទត្រូវឲ្យធ្វើ

បញ្ជីរបស់ខ្មាំងនៃរបបនោះ ។

**ស៖** តើលោកឯកភាពនឹងការលើកឡើងនេះដែរឬទេ?

**ឆ៖** អត្ថបទរបស់ អេតធេសាន់ មានចំណុចល្អៗមែនទែនពីចំណុចគឹកថាខណ្ឌ២៤ និងកថាខណ្ឌ៥៦ របស់គាត់ ក្រៅពីនោះល្អម៉ាល្អមៗទេ ។ ដល់ចុងបញ្ចប់គាត់និយាយអំពីតួនាទីរបស់ ស-២១ ដូចជាខ្វះឯកសារសំអាង ខ្ញុំស្តាប់មិនយល់ ។ ដូច្នេះ ខ្ញុំលើកសំណូមពរចំពោះអង្គជំនុំជម្រះថា សុំឲ្យមានការដេញដោលឲ្យប្រាកដប្រជា ដោយឈរលើឯកសារមួយៗច្បាស់លាស់ក្នុងករណីនិយាយអំពីតួនាទីរបស់ស-២១ ។

**ស៖** តើលោកអាចឆ្លើយនឹងសំណួរនេះបានទេ? ទៅតាមអ្វីដែលលោកបាននិយាយ? តើបញ្ជីឈ្មោះខ្មាំងធ្លាប់ត្រូវបានអ្នកទោសនៅស-២១ ធ្វើឡើងដែរឬទេ?

**ឆ៖** បញ្ជីដែលអ្នកទោសឆ្លើយដាក់ គឺអ្នកទោសធ្វើ ។

**ស៖** ហើយលោក អេតធេសាន់ នៅទំព័រ១៨ និង១៩ ដដែលនោះ បាននិយាយឡើងថា លោកគឺជាបុគ្គលតែម្នាក់ដែលសម្រេចថា តើអ្នកជាប់ទោសណាម្នាក់នៅស-២១ ត្រូវធ្វើបញ្ជីឈ្មោះខ្មាំងនោះ ឬក៏មិនធ្វើ? មិនមាននរណាម្នាក់ទៀត នៅក្នុងគណៈអចិន្ត្រៃយ៍បញ្ជាឲ្យលោកបង្គាប់ឲ្យអ្នកទោសធ្វើបញ្ជីនោះទេ? តើលោកឯកភាពនឹងការលើកឡើងនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនឯកភាពទេ ។

**ស៖** បើសិនជាលោកមិនឯកភាពទេ ។ តើនរណាគេបើសិនជាតាមការយល់ដឹងរបស់លោកដែលបញ្ជាឲ្យលោក ឲ្យអ្នកទោសធ្វើបញ្ជីបែបនោះ?

**ឆ៖** របៀបរបបសួរចម្លើយនៅស-២១ ខ្ញុំស្គាល់ច្បាស់ តែកាលណាចាប់បានមនុស្សម្នាក់មកហើយ គេឲ្យឆ្លើយអំពីប្រវត្តិក្បត់ ប្រវត្តិក្បត់ពីមុន ប្រវត្តិក្បត់បច្ចុប្បន្ន ។ ដូច្នេះ ដើម្បីសម្រួលដល់ការអាន អ្នកទោសត្រូវតែដកស្រង់ឈ្មោះដែលខ្លួនឆ្លើយដាក់ ។ នេះវាជាកិច្ចដំណើរការនៃការធ្វើឯកសារ បើនិយាយថា--

[១៤:៤០:00]

**ស៖** តើនរណាគេ ជាអ្នកចេញបញ្ជាឲ្យលោកធ្វើដំណើរការនៃការធ្វើដូច្នេះ?

**ឆ៖** ឯកសារបែបនេះ យើងមើលទាំងអស់គ្នា ឯកសារនៅសល់ទេ ។ យកឯកសារសល់នៅស-២១ ទាំងអស់យកមកមើល តាំងពីខ្ញុំមិនទាន់ចូលមកធ្វើអនុប្រធានស-២១ គេដំណើរការបែបនេះទៅ

ហើយ ។ ហើយបន្តិចទៀត លោកមេធាវីគង់ឃើញឯកសារខ្លះ ដូចជាចម្លើយសារភាពរបស់ ជូឡុង រង្ស៊ី អ៊ីចឹង ណាត គាត់ឱ្យធ្វើមួយបែបផ្សេងទៅ ។ ដូច្នេះ រឿងអស់នេះ វាជាការងារដែលស-២១ ក៏ដូចជាមន្ទីរសន្តិបាលផ្សេងទៀតទូទាំងប្រទេសធ្វើ តាមសំណូមពរទាមទាររបស់អ្នកដឹកនាំ ។

**ស៖** តើលោកឯកសារជាមួយនឹងលោក អេតឆេសាន់ ទេ នៅពេលដែលគាត់និយាយថាបញ្ជីឈ្មោះខ្មាំងបែបហ្នឹង ដែលត្រូវបានធ្វើឡើងដោយអ្នកទោសនោះ នៅស-២១ គឺថាមានបញ្ជីរាប់ពាន់បញ្ជីឯណោះ? តើលោកឯកសារភាពទេ?

**ឆ៖** បញ្ជីដែលអ្នកទោសសរសេរដោយដៃអ្នកទោស មិនមែនត្រឹមតែរាប់ពាន់ទេ ជនជាប់រងគ្រោះដែលទៅជាប់ទោសនៅនោះហើយ ត្រូវគេវាយសួរចម្លើយមួយម៉ឺនជាងណ៎ា ដូច្នេះច្រើន ។

**ស៖** ហើយលោក អេតឆេសាន់ នៅថ្ងៃដដែលនោះ គាត់ក៏បាននិយាយបញ្ជាក់ថា លោកបានចេញបញ្ជាឱ្យបុគ្គលិកស-២១ ចងក្រងនូវបញ្ជីឈ្មោះខ្មាំង។ ដូច្នេះ យើងពេលនេះគឺយើងមិននិយាយអំពីបញ្ជីដែលអ្នកទោសធ្វើទេ គឺជាបញ្ជីដែលចងក្រងធ្វើឡើងដោយបុគ្គលិករបស់ស-២១ ដោយពឹងផ្អែកនៅលើអត្ថន័យនៃចម្លើយសារភាព ។ តើលោកឯកសារទៅលើការលើកឡើងបែបនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនឯកភាពទេ ។ អ្នកសួរអត់ធ្វើបញ្ជីផ្ទាល់ដោយដៃខ្លួនឯងទេ ។

**ស៖** ដូច្នេះ ខ្ញុំយល់ថា អ៊ីចឹងអ្វីដែលលោក អេតឆេសាន់ និយាយគឺថាមានបញ្ជីឈ្មោះអស់ទាំងហ្នឹងរាប់ពាន់ ដែលបុគ្គលិករបស់ស-២១ ធ្វើនោះ តើលោកមិនឯកសារនូវការលើកឡើងនេះទេឬ?

**ឆ៖** អត់ឯកភាពទេ ។

**ស៖** សំណួរចុងក្រោយទាក់ទងនឹងប្រធានបទនេះ ហើយខ្ញុំអរគុណលោកដែលលោកបានឆ្លើយខ្លីៗច្បាស់ៗ។ តើលោកឯកភាពទេថា អ្នកទោសត្រូវបានសួរចម្លើយឱ្យផ្តល់ឈ្មោះរបស់ជនក្បត់ឬក៏ខ្មាំង ហើយសំណួររបស់ខ្ញុំនោះគឺថា បញ្ជីទាំងនោះ គឺបញ្ជីឈ្មោះជនក្បត់ ដែលអ្នកទោសបានធ្វើដោយខ្លួនឯងទៅតាមការយល់ដឹងរបស់លោក ថាតើបញ្ជីទាំងអស់ហ្នឹងត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខនានាផ្សេងទៀតនៅទូទៅប្រទេសកម្ពុជាសម្រាប់ឱ្យពួកគេយកទៅប្រើប្រាស់ដែរឬទេ?

[១៤:៤៤:២៥]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា សេចក្តីសារភាពរបស់ស-២១ វាត្រូវចេញពីខ្ញុំទៅមេខ្ញុំ។ មេខ្ញុំគឺអ្នកណា? មេខ្ញុំគឺ សុន សេន។ មេខ្ញុំ គឺ សុន សេន នេះ កំណត់ដោយសេចក្តីសម្រេចចិត្ត ថ្ងៃ០៩ តុលា ១៩៧៥ ។ ដូច្នេះ ចេញពី សុន សេន បាន សុន សេន គាត់ចារមតិសុំយោបល់បង ប៉ុល ឬក៏យោបល់ ពូនួន ។ ពូនួន

សម្រេច ឬ បងប៉ុល សម្រេច បានៗអ្នកខាងក្រោមគឺ សុន សេន នេះ មានសិទ្ធិយកឯកសារនេះទៅបង្ហាញភូមិភាគផ្សេងទៀត មិនមែនទៅបង្ហាញនគរបាលទេ ទៅបង្ហាញលេខាភូមិភាគផ្សេងទៀត ដូច្នេះឯកសាររបស់ស-២១ មានដំណើររបស់វាច្បាស់លាស់ ពីខ្ញុំទៅមេខ្ញុំ ដែលចាត់តាំងឡើងដោយសេចក្តីសម្រេចចិត្ត ថ្ងៃ០៩តុលា ១៩៧៥ ។ ទៅពីមេខ្ញុំទៅបងប៉ុល ពីលើនោះ យោងតាមសេចក្តីសម្រេចចិត្តថ្ងៃ០៩ តុលា ១៩៧៥ ដដែល ខាងលើសម្រេចហើយបានវាចុះមក សុន សេន វិញចាត់ចែង ។

**ស៖** ទៅតាមការដឹងរបស់លោក ទាក់ទងនឹងបញ្ជីទាំងនេះ គឺបញ្ជីឈ្មោះខ្មាំងដែលអ្នកជាប់ឃុំនៅស-២១ បានសរសេរនោះ តើលោកមានបានដឹងថា បញ្ជីអស់ទាំងហ្នឹង ធ្វើតាមវិធីដែលលោកដែលទើបតែបានរៀបរាប់អម្បាញ់មិញដែរឬទេ? គឺមានន័យថាពីលោក ទៅមេរបស់លោក ហើយទៅ ប៉ុលពត បន្ទាប់មកទៀតបកមក សុន សេន វិញ ហើយបន្ទាប់មកទៀតបានទៅតាមលេខាភូមិភាគនានាតើបញ្ជីឈ្មោះខ្មាំងទាំងហ្នឹង មានដំណើរដូចគ្នានេះដែរឬទេ?

**ឆ៖** លោក វ៉ែនណឹ ជាទីគោរព! វាត្រូវតែដំណើរការទៅតាមហ្នឹង ។ ពីលើកមុន ខ្ញុំបានរាយ-ការណ៍ជូនលោកចៅក្រមរួចហើយ ឯកសារមួយដែលមាននៅក្នុងសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” របស់ ឌី ខាំបូលី ។ នៅក្នុងឯកសាររបស់ អេតឆេសាន់ មានមួយទៀត គឺឯកសារលេខ ERN00017305 ។ សំណុំរឿងនេះ វាចេញពីខ្ញុំនៅថ្ងៃ២១ ខែមិថុនា ឆ្នាំ១៩៧៧ ដល់មេខ្ញុំលោកគ្រូ សុន សេន ស៊ីញ៉េថ្ងៃ២៣ ខែ(សុំទោស) ថ្ងៃ២៣ ខែឧសភា ។ ខ្ញុំស៊ីញ៉េថ្ងៃ២១ ខែឧសភា ១៩៧៧ ។ លោកគ្រូសុន សេន ស៊ីញ៉េថ្ងៃ២៣ ១៩៧៧ ។ លោកគ្រូសុន សេន មេខ្ញុំចារថា “ជូនបង នួនផ្ទាល់ សម្ងាត់” ដល់ចុងបញ្ចប់ ពូនួន គាត់សម្រេច ហើយគាត់អនុវត្តរួចហើយ។ ដកស្រង់ជូនសមមិត្ត ម៉ុក រួចហើយ ថ្ងៃមិនច្បាស់ទេ ក៏ប៉ុន្តែនៅខែឧសភា ១៩៧៧ ដដែល ។

នេះសំណុំរឿងឯកសារស-២១ វាទៅតាមខ្សែចង្វាក់វាច្បាស់លាស់អ៊ីចឹង អត់មានអ្នកណាទៅច្របូកច្របល់ទេ នេះគឺច្បាស់អ៊ីចឹង ។ នេះវានៅជាប់ក្នុងនេះរបស់ អេតឆេសាន់ ហើយ ។ ប៉ុន្តែ អេតឆេសាន់ គាត់យកទៅនិយាយអធិប្បាយម៉េចឆ្គួត រឿងពិតនេះវានៅហ្នឹង ភស្តុតាង ។

[១៤:៤៨:៤៤]

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទ ប្រយ័ត្នប្រយែងពាក្យសម្តីបន្តិចណា មិនអាចនិយាយធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរនូវពាក្យសម្តីផ្សេងៗនៅក្នុងអង្គសវនាការបានទេ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន តើខ្ញុំអាចសួរសំណួរមួយទៀតទេ មុននឹងយើងឈប់សម្រាក?

**ស៖** សូមជឿរបស់ខ្ញុំយល់អ្វីដែលលោកនិយាយ ហើយខ្ញុំក៏យល់ទៅតាមវិធីដែលឯកសារហ្នឹងដំណើរការដែរ ។ សំណួររបស់ខ្ញុំគឺថា តើលោកឯកភាពទេ? ប្រហែលជាប្រាំ-ដប់នាទីមុន លោកបានឯកភាពថាមានឈ្មោះខ្មាំងមួយចំនួន ត្រូវដាក់នៅក្នុងបញ្ជីនៅស-២១ នៅក្នុងអំឡុងពេលដែលអ្នកទោសត្រូវបានសួរចម្លើយនោះ ហើយសំណួរដែលខ្ញុំសួរទៅលោកគឺថា បើតាមការដឹងរបស់លោក តើបញ្ជីឈ្មោះទាំងនោះ បញ្ជីឈ្មោះខ្មាំងទាំងអស់ហ្នឹងត្រូវបានបញ្ជូនតាមវិធីដូចគ្នា ដែលលោកទើបបានរៀបរាប់អម្បាញ់មិញហ្នឹងឬ? ដែលចុងបញ្ចប់នោះ គឺបញ្ជីទាំងអស់ហ្នឹងគឺធ្លាក់ទៅដល់ដៃលេខារបស់ភូមិភាគនានា តើលោកយល់សំណួររបស់ខ្ញុំដែរឬទេ?

**ឆ៖** សូមសួរម្តងទៀតមក សុំទោស ។

**ស៖** សុំអភ័យទោស ដោយសារសំណួររបស់ខ្ញុំលំបាកបន្តិច ។ លោកបានបញ្ជាក់ខាងមុនថាគឺថាបញ្ជីត្រូវបានធ្វើនៅស-២១ ដោយអ្នកទោសគឺបញ្ជីនៃខ្មាំង ឬជនក្បត់ ។ សំណួរខ្ញុំនោះ ខ្ញុំចង់សួរតាមដែលលោកដឹង ប្រហែលជាលោកមិនដឹង។ ប៉ុន្តែ តាមដែលលោកដឹង ថាតើបញ្ជីទាំងអស់ហ្នឹង មិនមែនឯកសារផ្សេង ថាបញ្ជីទាំងនោះត្រូវបានបញ្ជូនចេញពីស-២១ ទៅថ្នាក់លើរបស់លោក ហើយទៅបង ប៉ុល បន្ទាប់មក សុន សេន ហើយលោកសុន សេន បញ្ជូនទៅលេខាភូមិភាគ តើបញ្ជីទាំងអស់ហ្នឹងបញ្ជូនតាមផ្លូវហ្នឹង ឬយ៉ាងដូចម្តេច?

**ឆ៖** អរគុណ ។ សុទ្ធតែតាមផ្លូវហ្នឹង ទៅដល់ត្រឹមលេខាភាគៗ គេចាត់ចែងតទៅទៀត សុទ្ធតែតាមផ្លូវហ្នឹង ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណ ។ សូមលោកប្រធាន តើអនុញ្ញាតឲ្យខ្ញុំបន្ត ឬក៏ដូចម្តេច?

**ប្រធានអង្គជំនុំ៖**

សម្រាកសិនណ៎ា ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងបីនិងដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តនីតិវិធីសវនាការដេញដោលតទៅទៀត ។

*[សវនាការសម្រាកពីម៉ោង ១៤:៥១ នាទីដល់ម៉ោង ១៥:១២ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការដេញដោល ។ សូមអញ្ជើញមេធាវី អាឡាំង វ៉ែនណឺ ដែលមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ បន្តសំណួរពាក់ព័ន្ធទៅនឹងជនជាប់ចោទអំពីអង្គហេតុបានកំណត់ធ្វើការដេញដោលនេះ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកចៅក្រម លោកប្រធាន ។ ខ្ញុំសូមសួរសំណួរពីរ បន្ថែមទៀតទៅលោក ទាក់ទងទៅនឹងបញ្ជីរាយឈ្មោះទាំងអស់នោះ ។ សំណួរទីមួយ លោកបានប្រាប់យើងថា មុនពេលសម្រាកនេះ បញ្ជីខ្លះក្នុងចំណោមបញ្ជីទាំងអស់នោះ ដែលជាបញ្ជីខ្មាំងដែលត្រូវបានរៀបចំឡើងផ្នែក ឬក៏ធ្វើឡើងដោយអ្នកទោសនៅក្នុងស-២១ ។ បញ្ជីខ្លះក្នុងចំណោមបញ្ជីទាំងអស់នោះ គឺថាត្រូវបានបញ្ជូនទៅឲ្យលេខាភូមិភាគ ហើយលោកបានពន្យល់យ៉ាងច្បាស់ ថាតើដំណើរការពីចំណុចទៅមួយចំណុចមួយនៃលំហូរនោះ ។

**ស៖** អ៊ីចឹង សំណួរបន្ទាប់ទៅទៀត តាមដែលលោកដឹង តើលេខាភូមិភាគហ្នឹង គេធ្វើដូចម្តេចចំពោះបញ្ជីរាយឈ្មោះដែលគេឆ្លើយដាក់នោះ ពេលដែលគេទទួលហើយហ្នឹង គេចាត់ការដូចម្តេច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ។ រឿងគេឯភូមិភាគគេ ខ្ញុំក្តាប់មិនបានទេ ក៏ប៉ុន្តែបើនិយាយពីសន្និដ្ឋាន មិនដឹងត្រូវ ឬខុសទេ ។ ឧបមាដូចជា ក្រដាសមិញដែលខ្ញុំលើកឡើងហ្នឹងៗ វាមានជាប់ឈ្មោះមនុស្សដែលនៅក្នុងតំបន់៣៥ គឺកំពត ។ ម្ល៉ោះហើយបានបញ្ជីនេះទៅ មិនដឹងថា តាម៉ុក គាត់ធ្វើម៉េចទេ? ព្រោះ ពូនួន ឲ្យគេបញ្ជូនបញ្ជីនេះទៅ តាម៉ុក ហើយ ។ ដូច្នេះ ស្រេចតែ តាម៉ុក ទេ គេធ្វើម៉េចស្រេចគេ ព្រោះគេស្ថិតនៅក្នុងពពួកបួនក្រុម ដែលមានចែងនៅក្នុងសេចក្តីសម្រេចចិត្តថ្ងៃ៣០ មីនា ១៩៧៦ ស្រាប់ ។ នេះជាសមត្ថកិច្ចរបស់គេ នេះសូមជូនប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ ឥឡូវនេះ សំណួរទីពីររបស់ខ្ញុំហ្នឹង គឺបញ្ជីទីពីរ ដែលទាក់ទងទៅនឹងការយោងរបស់លោក អេតធេសាន់ ដែលថា បញ្ជីដែលរៀបរៀងដោយបុគ្គលិកស-២១ ផ្អែកទៅលើចម្លើយសារភាព ហើយលោកបានប្រាប់មុនសម្រាកថា លោកមិនឯកភាពជាមួយសម្តីរបស់លោក អេតធេសាន់ ទេ ។ បើតាមសម្តីរបស់លោក គឺថាមិនមានបញ្ជីបែបនោះទេ។ ដូច្នេះ ខ្ញុំចង់បង្ហាញជូននូវឯកសារនេះជូនលោក ហើយសូមអរគុណខាងសហព្រះរាជអាជ្ញាដែលលោកបានសុំឲ្យបង្ហាញឯកសារនេះលើអេក្រង់កុំព្យូទ័រ ដែលមានជាខ្មែរជាច្បាប់ដើម ដែលមានលេខ ERN00161834,D31 ឧបសម្ព័ន្ធលេខ៤

D81 ឧបសម្ព័ន្ធ ។ ហើយខ្ញុំអាចជូនជាអង់គ្លេស 00187746 ហើយដែលខ្ញុំដឹងនោះ គឺថាមិនមានការបកប្រែទៅជាភាសាបារាំងទេឯកសារនេះ ។

ដូច្នេះ ខ្ញុំសូមស្នើលោកប្រធាន ដើម្បីៗដាក់បង្ហាញនៅលើអេក្រង់កុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ដើម្បីឲ្យជនជាប់ចោទគាត់អាចឃើញក្នុងភាសាខ្មែរបាន ។

[១៥:១៧:៣០]

**ប្រធានអង្គជំនុំ៖**

បង្គាប់មកអ្នកបច្ចេកទេសសោតទស្សន៍ សូមភ្ជាប់ប្រព័ន្ធរូបភាពទៅកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ហើយខាងជំនួយការសហព្រះរាជអាជ្ញា សូមរៀបចំឯកសារនេះដាក់លើកញ្ចក់ទូរទស្សន៍ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណ ។ ហើយខ្ញុំមានការបកប្រែនូវបញ្ជីនេះ ហើយខ្ញុំប្រសិនជាខ្ញុំយោងទៅខុស ថសុំប្រាប់ខ្ញុំ ខ្ញុំមិនអាចអានច្បាប់ដើមបានទេ ។ ប៉ុន្តែ តាមដែលខ្ញុំយល់ ប្រសិនបើយើងមើលកូឡោនទីមួយដែលចេញមកពី ចាប់ពីខាងឆ្វេងមក ដែលមានកូឡោនមួយដែលមានលេខរៀង ។ កូឡោនទីមួយនោះ គឺបន្ទាប់ពីលេខរៀងមកមានឈ្មោះ ហើយនៅខាងលើ នៅក្នុងប្រអប់នោះ ដែលនិយាយថា មានដាក់ថាឈ្មោះ ដែលឆ្លើយដាក់នៅក្នុងការឆ្លើយ ហើយដូចដែលយើងបានឃើញ គឺថាយើងមានឈ្មោះមនុស្សមួយចំនួនបន្ទាប់មកបើយើងតាមមើលតទៅទៀត ទៅក្នុងកូឡោនផ្សេងទៀតនៅក្នុងខាងស្តាំដៃ គឺថាមានភារកិច្ចនិងទីកន្លែង ។ ហើយនឹងមានប្រអប់តូចៗមួយចំនួន នៅក្នុងនោះក៏មានឈ្មោះ ហើយយើងជឿថា ទាំងអស់នោះគឺជាឈ្មោះរបស់មនុស្សដែលត្រូវបានជាប់ឃុំនៅស-២១ ។ ប្រសិនបើយើងចុះទៅខាងក្រោមយើងនឹងឃើញមានលេខបូកសញ្ញាលេខបូកៗនៅតាមឈ្មោះគ្រង់ជួរនៃឈ្មោះទាំងអស់ហ្នឹង។

**ស៖** អ៊ីចឹងហើយ ខ្ញុំលើកឡើងខុសនោះតាមដែលខ្ញុំយល់នោះ តើនៅក្នុងឯកសារហ្នឹង គឺរកឃើញនៅក្នុងស-២១ ហើយវាទំនងជា គឺជាបញ្ជីនៃឈ្មោះដែលបញ្ជាក់ពីព័ត៌មាន ដែលថា អាចជាការប្រមូលនូវៗព័ត៌មាន ដោយផ្អែកឡើងទៅចម្លើយសារភាពនៅក្នុងស-២១ ។ តើលោកជឿអ៊ីចឹងទេ ឬក៏លោកអាចពន្យល់ពីខ្លឹមសារនៃបញ្ជីនេះបានទេ?

[១៥:២០:១៣]

**ឆ៖** លោកប្រធានជាទីគោរព! ប្រភពដើមនៃការបូកសរុបបញ្ជីនេះ វាចេញពីចម្លើយសារភាពម្នាក់ៗក្នុងចំណោមមនុស្សទាំងប្រាំបី, ប្រាំបួននាក់នេះ ។ ទាំងអស់ប្រាំបួននាក់៖ ១, ២, ៣, ៤, ៥, ៦,

៧, ៨, ៩ ។ នេះគឺជាបញ្ជាពីលើមកឱ្យ ស-២១ ប្រមូលក្នុងចំណោមមនុស្សប្រាំបួននាក់នេះ តើប៉ុន្មាននាក់ឆ្លើយដាក់អ្នកណាខ្លះ? ដូច្នេះ ជាកិច្ចបញ្ជាមក ដូច្នេះ វាមិនមែនជាឯកសារដែលធ្វើឡើងតាមចិត្តរបស់បុគ្គលិកមន្ទីរស-២១ ទេ ។ វាជាឯកសារដែលឈរលើសេចក្តីសារភាពរបស់អ្នកឆ្លើយទាំងប្រាំបួននាក់នេះ ។ ដូច្នេះ ឃើញទេឈ្មោះ វិន មានឆ្លើយជាប់ចម្លើយបួននាក់ ។ ឈ្មោះ ព្រាប ញ៉ាន មានគេឆ្លើយជាប់ចម្លើយបីនាក់ ។ ឈ្មោះ សូ ភៀច មានគេឆ្លើយជាប់ចម្លើយបួននាក់ ។ ទាំងអស់នេះ វាជារឿងដែលគេស្រង់ចេញអំពីបញ្ជីសារភាពរបស់អ្នកទោសប្រាំបួននាក់ហ្នឹង ។ ហើយខ្ញុំរាយការណ៍ទៅជូនមេតាមសំណូមពរ ។

ដូច្នេះ មិនមែនជាបុគ្គលិកមន្ទីរស-២១ ត្រូវប្រឌិតអីណា គឺអត់ទេ វាឈរលើមូលដ្ឋានជាក់ស្តែងរបស់វា វាធ្វើការងារតាមបញ្ជា ។ វាជារឿងធម្មតា ការងារនេះយើងខ្ញុំធ្វើតាមបញ្ជា ដោយមានមូលដ្ឋានច្បាស់លាស់ប្រភពឯកសារដើម ។

**ស៖** ដូច្នេះ តើយើងឯកភាពគ្នាទេថា បញ្ជីនេះត្រូវបានរៀបចំឡើងដោយបុគ្គលិកស-២១ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រូវមានពាក្យមួយម៉ាត់ទៀត ដោយឈរលើឯកសារជាក់ស្តែងនៃចម្លើយសារភាពរបស់អ្នកទោស ។

**ស៖** ខ្ញុំដឹងហើយអ្វីដែលលោកនិយាយ ។ ប៉ុន្តែ ខ្ញុំចង់និយាយថា បញ្ជីដែលមានតារាងដូចដែលយើងបានឃើញនៅលើអេក្រង់នេះ នេះគឺជាបញ្ជីដែលបានធ្វើឡើងដោយបុគ្គលិករបស់លោកនៅស-២១ តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ធ្វើដោយបុគ្គលិករបស់មន្ទីរស-២១ ដោយឈរលើសេចក្តីសារភាពរបស់ខ្មាំង ។ ថែមអាហ្នឹងទៀត ។

**ស៖** ខ្ញុំយល់ដឹងហើយ ហើយលោកបាននិយាយថា គឺនេះគឺជាការអនុវត្តធម្មតា។ ដូច្នេះ ថាតើបញ្ជីបែបហ្នឹង ត្រូវបានធ្វើប៉ុន្មានទៅនៅមន្ទីរស-២១? បើសិនជាលោកអាចចាំបាន ។

**ឆ៖** ដែលខ្ញុំនិយាយថា ការអនុវត្តធម្មតា ព្រោះក្នុងករណីនេះ មេទាមទារឱ្យធ្វើអីចឹង នេះសំដៅទៅការអនុវត្តធម្មតា គឺយើងធ្វើតាមបញ្ជាមេ ។ ហើយប៉ុន្មានអាហ្នឹងយើងប្រមូលទៅ នៅស-២១ នៅសល់ប៉ុន្មាន អាឯកសាររបៀបហ្នឹង យើងប្រមូលយកឱ្យមើលទាំងអស់គ្នា ។ អត់មានអ្នកណាហ៊ានប្រកែកទេ ។ រឿងពិតដែលកើតឡើង គ្មានអ្នកណាហ៊ានប្រកែកទេ ។

[១៥:២៣:៥២]

**ស៖** ប្រសិនបើសិនជាលោកអាចជួយបាន តើលោកអាចនិយាយប្រាប់បានទេ បញ្ជីអស់ទាំងហ្នឹងមានចំនួនប៉ុន្មានទៅ ដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលលោកជាអនុប្រធាន និងជាប្រធាននៅ ស-២១ នោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំចាំមិនច្បាស់ទេ ។ ខ្ញុំចាំមិនច្បាស់ទេ ប្រហែលជាមានប្រមូលម្តង ហើយខ្ញុំរាយការណ៍ជូនមេនៅពេលដែលទាក់ទងនឹងកងពល១៧០ និង២៩០ ហើយដែលមេហៅខ្ញុំទៅចាំស្តាប់សេចក្តីសម្រេច ន្ធាលនឹងសហការគ្នាយកមនុស្សដែលត្រូវចាប់ចូល ស-២១ នៅថ្ងៃ ១៦ កញ្ញា១៩៧៦ ។

ប្រហែលជាមានដល់ពេលនុ៎ងទៀត ។ ដូច្នេះ ប៉ុន្មានខ្ញុំមិនចាំច្បាស់ទេ ហើយសូមបញ្ជាក់ថាឯកសារនេះខ្ញុំក៏ភ្លេចបាត់ទៅហើយ ។ ប៉ុន្តែ ឥឡូវវាមកឃើញមុខ ចុះវាមានអីចម្លែក រឿងមេប្រើឲ្យខ្ញុំធ្វើខ្ញុំត្រូវតែធ្វើ ហើយធ្វើនោះដោយឈរលើមូលដ្ឋានជាក់ស្តែងមានលក្ខណៈជាវិទ្យាសាស្ត្រច្បាស់លាស់របស់ខ្ញុំ។ ខ្ញុំអត់ប្រឌិតទៅឲ្យអ្នកណា បញ្ចូលឈ្មោះអ្នកណាពាសវាលពាសកាលទេ អត់ទេ ។

**ស៖** អ៊ីចឹងទៅតាមការយល់ដឹងរបស់ខ្ញុំ គឺលោកនិយាយថា មានបញ្ជីឈ្មោះដទៃទៀត ប៉ុន្តែលោកមិន ប្រាកដថាតើមានបញ្ជីប៉ុន្មានទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវយ៉ាងហោចណាស់ក៏មាន១៧០ ហើយនិង២៩០ ត្រង់យើងរកឯកសារដើមឃើញឬមិនឃើញមិនដឹងទេ មាន១ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណ ។ ឥឡូវនេះ អាចយកឯកសារហ្នឹងចេញពីអេក្រង់បានហើយ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ផ្តាច់ ផ្នែកខាងរូបភាពជាមួយខាងសហព្រះរាជអាជ្ញា ហើយដាក់រូបភាពប្រក្រតីឡើងវិញ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

**ស៖** នៅថ្ងៃទី២៨ ខែឧសភា គឺ១ថ្ងៃមុននឹងយើងឈប់គឺនៅថ្ងៃព្រហស្បតិ៍ មានការនិយាយអំពីគោលនយោបាយទាក់ទងទៅនឹងការធ្វើទារុណកម្ម ហើយសម្រាប់មេធាវីការពារក្តីអាចរកឃើញនៅក្នុងប្រតិចារឹកព្រាងនៅថ្ងៃទី២៨ ខែឧសភា នៅទំព័រ៦ និងទំព័រ៧។ លោក អេតធេសាន់ បានផ្តល់សក្ខីកម្ម

ថា វិធីជាច្រើនដែលត្រូវបានប្រើសម្រាប់ការធ្វើទារុណកម្មនៅស-២១ គឺវាមានលក្ខណៈពិសេស ហើយមិនត្រូវបានប្រើនៅមន្ទីរសន្តិសុខដទៃៗទៀតទេ នៅទូទាំងប្រទេសកម្ពុជានោះ ។ តើលោកឯកភាពនឹងការលើកឡើងនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនឯកភាព ។

[១៥:២៧:៥១]

**ស៖** តើលោកអាចបញ្ជាក់បន្ថែមទៀតបានទេ ហេតុអ្វីបានជាលោកមិនឯកភាពជាមួយនឹងលោកអេតឆេសាន់ ទៅលើចំណុចនេះ?

**ឆ៖** ទីមួយ ឯកសាររបៀបធ្វើទារុណកម្មនៅស-២១ គាត់យកមកនិយាយអាងលើឯកសារស្អីខ្លះ? បញ្ចេញឯកសារឲ្យច្បាស់មក ដើម្បីទាំងអស់គ្នាវិភាគហើយទទួលស្គាល់ ។ ទីពីរ នៅមន្ទីរសន្តិសុខផ្សេងទៀត គាត់មានឯកសារប៉ុន្មានហើយវិភាគអំពីទារុណកម្មនៅមន្ទីរសន្តិសុខទាំងឡាយនោះ? សូមអញ្ជើញយកមកលាតត្រដាងជូនអង្គជំនុំជម្រះ ដើម្បីសម្រេច ថាតើស-២១ វាណាស់ជាងគេទេ? យើងខ្ញុំមិនទាន់ហ៊ានថាខ្លួនឯងណាស់ជាង ហើយក៏អន់ជាងគេ ឬក៏ប្រហែលគេទេ ។ ឥឡូវ រកឯកសារមកប្រមូលគ្នា ឲ្យច្បាស់ ។

**ស៖** ដើម្បីយល់ពីអ្វីដែលលោកបានគិតនោះ តើលោកគិតថាវិធីនៃការធ្វើទារុណកម្មដូចគ្នាឬ? ខ្ញុំនិយាយឡើងវិញម្តងទៀត ថាតើវិធីធ្វើទារុណកម្មដូចគ្នាត្រូវបានប្រើនៅស-២១ និងនៅតាមមន្ទីរសន្តិ-សុខដទៃៗទៀតនៅទូទាំងប្រទេសកម្ពុជាឬ? តើនេះជាទស្សនៈរបស់លោកឬ?

**ឆ៖** សូមបញ្ជាក់ថា ខ្ញុំហើយនិងមន្ទីរសន្តិបាលផ្សេងទៀតគ្មានការទាក់ទងគ្នាទេ ដូច្នេះគេធ្វើយ៉ាងម៉េច ខ្ញុំមិនដឹង ។ ខ្ញុំធ្វើយ៉ាងម៉េចក៏គេអាចមិនដឹង គេមិនដឹង ។ គេធ្វើបែបគេ ខ្ញុំធ្វើបែបខ្ញុំ ។

ដោយឡែកតែការអនុញ្ញាតរបស់ខ្ញុំឲ្យបុគ្គលិកសួរចម្លើយធ្វើទារុណកម្មមាន រូបភាពធ្វើទារុណ-កម្ម យើងខ្ញុំបាននិយាយរួចហូរហែមកហើយ ណាត គាត់ចូលចិត្តឲ្យគេឆក់នឹងទូរសព្ទ័រវៃ ដល់អ្នកយកទៅអនុវត្តមិនលែងអាទូរស័ព្ទរវៃដែលមានត្រឹមតែប៉ុន្មានវុលហ្នឹង គាត់ទៅលេងអាភ្លើងជញ្ជាំង២២០វុលហ្នឹងរូបភាពមួយ ។ ហើយខ្ញុំមិនទាន់ជឿមែនទែនផង សម្តី អេតឆេសាន់ និយាយថានៅជនបទគេនិយាយថា នៅជនបទគេ ប្រើអគ្គីសនីឆក់ដែរមិនដឹងយ៉ាងម៉េចទេ?

ទីពីរ ច្រកស្បោង ។ វិធីហ្នឹង វ៉ន វេត គាត់ណែនាំតាំងតែពីគាត់នៅគ្រប់គ្រងខ្ញុំ ប៉ុន្តែនៅ ស-២១ ជាពិសេសនៅមន្ទីរ-១៣ ខ្ញុំមិនដែលបានអនុវត្តទេ ។ ប៉ុន្តែ នៅស-២១ ដូចជាអនុវត្ត ឬអត់ ។ ដូច្នេះ ជា

គោលការណ៍យើងខ្ញុំអនុញ្ញាតឲ្យធ្វើទារុណកម្មបួនយ៉ាង ក៏ប៉ុន្តែអ្នកធ្វើគេច្រើនតែលួចធ្វើលើស មានដកក្រចក យើងខ្ញុំអត់អនុញ្ញាតទេ ។ ប៉ុន្តែ ឮល្បីមកក្រោយទៀតថា មានពេលខ្លះយកស៊ីម៉ង់ដ៏ទៅលាបមុខអ្នកត្រូវសួរហ្នឹង ។ អាហ្នឹងក៏ខ្ញុំមិនដឹងថាមានមែន ឬគ្មានទេ ។ រួចដល់រហូតអាស្អីណាដុតដោះ ដុតអីក្អែបខាំងណោះមិនមាន ខ្ញុំមិនជឿថាមាន មិនមានឃើញកន្លែងចិញ្ចឹមក្អែប ឬមិនមានអ្នកណាទៅចិញ្ចឹមក្អែបអីសម្រាប់តែធ្វើអីចឹងទេ ។

ដូច្នេះ ទារុណកម្មប្រភេទនេះខ្ញុំជឿថា ជាទារុណកម្មប្រឌិត ។ រឿង អេតឆេសាន់ ខ្លួនឯងប្រឌិតខ្លួនឯង ឬក៏មានគេប្រឌិតប្រាប់ អេតឆេសាន់ ខ្ញុំមិនជឿ។ នេះនិយាយពីរឿងដែលកើតនៅស-២១ ។ ដូច្នេះ រកឯកសារឲ្យច្បាស់ហើយយើងវិភាគទាំងអស់គ្នាឲ្យច្បាស់ទៅ អំមិញនឹងហើយដែលខ្ញុំនិយាយជម្រាបអង្គជំនុំជម្រះថា រឿងដែល អេតឆេសាន់ និយាយទាំងប៉ុន្មានអំពីតួនាទីរបស់ ស-២១ ទាមទារឲ្យឆ្លងកាត់ការដេញដោលឲ្យបានហ្មត់ចត់ ។ បើមិនឆ្លងកាត់ការដេញដោលឲ្យបានហ្មត់ចត់ទេ ខ្ញុំអត់ទទួលយកទេ ។ ឧក្រិដ្ឋកម្មខ្ញុំអត់គេចទេ ទៅលើអាយុជីវិតមនុស្សមួយម៉ឺនពីរពាន់បីរយប្ដាយនាក់ ខ្ញុំអត់គេចទេទទួលគ្រប់ពេលវេលា ។ ក៏ប៉ុន្តែ រឿងល្អិតត្រូវតែនិយាយឲ្យឃើញ តើរឿងជាក់ស្តែងវាយ៉ាងម៉េច? យើងជជែកគ្នាទាំងអស់គ្នាមក យកបញ្ហាមកដាក់លើតុទាំងអស់គ្នា ហើយជជែកគ្នា យើងមើលទាំងអស់គ្នាដោយរក្សា កុំជជែកយកតែម្ខាងទោលរៀងខ្លួន អត់បានទេ ខ្ញុំក៏មិនព្រមម្ខាងទោលរៀងខ្លួនដែរ ។

[១៥:៣២:៣៧]

**ស៖** សូមអរគុណលោកបានឆ្លើយនឹងសំណួររបស់ខ្ញុំហើយ ។ ឥឡូវនេះ យើងនិយាយពីប្រធានបទមួយទៀត ។ លោក អេតឆេសាន់ ក៏បាននិយាយអំពីចម្លើយសារភាព ហើយនិងវិធីដែលចម្លើយសារភាពហ្នឹង ត្រូវទទួលយកបាន គឺនៅទូទាំងប្រទេសកម្ពុជានៅតាមមន្ទីរសន្តិសុខនានាទាំងឡាយនោះ ហើយគាត់ក៏បាននិយាយនៅថ្ងៃដដែលនោះដែរ គឺថ្ងៃទី២៨ ខែឧសភា គឺនៅលើប្រតិចារឹកព្រាងជាភាសាអង់គ្លេស នៅទំព័រ១៥ ដល់១៧ លោក អេតឆេសាន់ បាននិយាយថា នៅតាមមន្ទីរសន្តិសុខនានានៅទូទាំងប្រទេស គឺមានចម្លើយសារភាពមួយចំនួនដែលទទួលយកបាន ។ ប៉ុន្តែ ចម្លើយសារភាពនោះ គឺថាមិនមានលម្អិត និងច្បាស់លាស់ដូចនៅស-២១ នោះទេ ។ តើលោកឯកភាពទៅនឹងការលើកឡើងនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលឃើញចម្លើយសារភាពណារបស់មន្ទីរសន្តិបាលផ្សេងទៀត ក្រៅអំពីចម្លើយសារភាពរបស់ឈ្មោះ លី ផែល ឲ្យមន្ទីរសន្តិបាលតំបន់២១ ទេ ខ្ញុំឃើញតែមួយហ្នឹង ហើយឲ្យខ្ញុំមាន

មតិយ៉ាងម៉េច ។

[១៥:៣៤:០៧]

**ស៖** តើលោកនៅចាំទេ លោកបាននិយាយអំពីទំហំនៃការងាររបស់លោកទាក់ទងទៅនឹងចម្លើយសារភាព ។ លោកបាននិយាយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដែលមានលេខ ERN ក្នុងភាសាអង់គ្លេស និងបារាំង ។ ភាសាអង់គ្លេស គឺមានលេខ 00153565 រហូតដល់ 00153566។ ហើយជាភាសាអង់គ្លេសមានលេខ 00153442 រហូតដល់ 00153445 ។ ខ្ញុំមិនមានបំណងដាក់បញ្ចាំងឯកសារនេះទេ ក៏ប៉ុន្តែខ្ញុំ ដោយបានអាននូវលេខ ERN ហើយនិងធ្វើសេចក្តីសង្ខេបទៅលើផ្នែកនៃឯកសារ ហើយនឹងប្រតិចារឹកនៅថ្ងៃនោះ គឺដូចសន្មតថាខ្ញុំបានដាក់បង្ហាញឯកសារនោះនៅចំពោះមុខអង្គសវនាការហើយ ។ ពេលនោះ គឺលោកបាននិយាយថា ទៅតាមការប៉ាន់ស្មានរបស់លោកនៅក្នុងអំឡុងពេលដែលលោកបានចំណាយពេលនៅស-២១ គឺលោកប្រហែល ជាបានពិនិត្យមើល ប្រហែលជាចម្លើយសារភាពហ្នឹង ប្រហែលជា ២០ម៉ឺនសន្លឹក នៅក្នុងអំឡុងពេលដែលលោកទទួលបន្ទុកនៅ ស-២១ នោះ ។ តើលោកមានចាំថាលោកបាននិយាយពាក្យនោះទេ?

**ឆ៖** ខ្ញុំចាំៗ អាហ្នឹងជារបៀបគិតលេខទៅតាមម៉ោង ទៅតាមពេលដែលយើងចំណាយ ដោយមិនបានឈរលើឯកសារដែលមាននៅចំពោះមុខយើង ហើយយើងរាប់ទេ ។ នេះជាការគិតលេខ ។ ខ្ញុំនិយាយតាមចម្លើយដែលខ្ញុំនិយាយជាមួយ អាឡិចប៊ើត ។

**ស៖** ហើយអ៊ីចឹងលោកតែងនៅឈរនៅលើការស្មានរបស់លោកដែរឬ ដែរថា ក្នុងអំឡុងពេលដែលលោកបានធ្វើការនៅក្នុងអំឡុងពេលនោះ?

**ឆ៖** ដរាបណាយើងមិនទាន់មានឯកសារជាសេចក្តីសារភាពយកមករាប់ចំពោះមុខទាំងអស់គ្នាទេ ខ្ញុំរក្សាការគិតលេខហ្នឹង ទុកជាការគិតលេខមួយដែលខ្ញុំបានគិតពិចារណា ។

[១៥:៣៦:៤៥]

**ស៖** ហើយបន្ទាប់មកទៀតលោកក៏បាននិយាយដែរ នៅចំពោះមុខចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ ដែលមានលេខ ERN ក្នុងភាសាអង់គ្លេស 00178058 រហូតដល់លេខ 00178070 ហើយភាសាអង់គ្លេសមានលេខ 00195945 រហូតដល់លេខ 00195958 ។ លោកបាននិយាយថា លោកត្រូវបានស្នើឲ្យដកឈ្មោះ លុបឈ្មោះមួយចំនួនចេញពីចម្លើយសារភាព ហើយនិង

បំផ្លាញចម្លើយសារភាពចោលមួយចំនួន ហើយលោកបាននិយាយថា នៅពេលដែលមានបញ្ហាឲ្យលោកលុបឈ្មោះចេញពីចម្លើយសារភាពនោះ គឺលោករក្សាច្បាប់ចម្លងនៃចម្លើយសារភាពដែលមិនបានលុបនោះ ហើយលោកបាននិយាយថា ឈ្មោះត្រូវបានលុបចេញក្រែងលោនៅពេលក្រោយត្រូវសម្រេច ដើម្បីចាប់បុគ្គលដែលមានឈ្មោះនោះ ។ តើលោកមានចាំថា លោកមានបាននិយាយពាក្យសម្ដីហ្នឹងជាមួយនឹងសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** បញ្ហាបើតាមខ្ញុំស្ដាប់សំណួរ យើងត្រូវចែកបញ្ហាជាពីរ ។ បញ្ហាដកឈ្មោះជាបណ្ដោះអាសន្ន ហើយនិងបញ្ហាបំផ្លាញឯកសារ ។ ខ្ញុំដូចមិនដែលបានជម្រាបលោកចៅក្រមស៊ើបអង្កេតថា ខ្ញុំបានឲ្យបំផ្លាញឯកសារទេ ។ អានេះខ្ញុំមិនចាំទេ មិនច្បាស់ទេ ក៏ប៉ុន្តែនិយាយពីរឿងដកឈ្មោះ ការងារនៅ ស-២១ វាមានជាហូរហែ ។ ជាពិសេស នៅពេលដែលចម្លើយរបស់ លី ផែល ហៅ ផែន ជាប់ទាក់ទងនឹងឈ្មោះ បងភឹម ។ ដូច្នេះ ដើម្បីឲ្យអចិន្ត្រៃយ៍បញ្ជូនឯកសារនេះទៅ បងភឹម ចាត់ចែងបានវាទាល់តែជាបណ្ដោះអាសន្នអចិន្ត្រៃយ៍ឲ្យខ្ញុំដកឈ្មោះតានុំងចេញ ។ នេះខ្ញុំមានចារ ជាភស្តុតាងដល់យើងសម័យនេះ ថាបានដកឈ្មោះតាហ្នុងចេញហើយ ។ ដូច្នេះដក ដកជាបណ្ដោះអាសន្ន ។ ឯកសារផ្សេងទៀតដែលមិនត្រូវការផ្ញើទៅបងភឹម អចិន្ត្រៃយ៍ទាមទារឲ្យយើងខ្ញុំសរសេរទាំងអស់។ នេះជាកិច្ចដំណើរការឬក៏គេ ហៅថាមាគ៌ាសកម្មភាពរបស់ ស-២១ គឺវាអ៊ីចឹង ។ នេះសូមបញ្ជាក់ ។

**ស៖** ហើយតទៅទៀត តើមានកើតឡើងទេ កាលណាដកឈ្មោះចេញហើយដូចដែលលោកពន្យល់នេះ បន្ទាប់មកលោករក្សាទុកមួយច្បាប់ទៀតដែលមានជាច្បាប់ដើម ដោយមានឈ្មោះនៅជាមួយផងដើម្បីថា ក្នុងករណីជននោះ នៅទីបំផុតជននោះហ្នឹង ត្រូវចាប់ខ្លួន ។ តើធ្លាប់មានករណីហ្នឹងដែរឬទេ?

[១៥:៤០:00]

**ឆ៖** មិនដឹងជាមានប៉ុន្មាននាក់ទេ មាន ប៉ុន្តែដូចតិចដែរទេ ។ ដូចឈ្មោះ សួស នៅ ហៅ ឈូកមានគេឆ្លើយដាក់ ប៉ុន្តែ ដល់ឯកសារដែលផ្ញើទៅ បងភឹម នោះ គេសម្ងាត់ជាមួយគ្នាទេ មិនដឹងជាស្អីមិនដឹងទេ ខ្ញុំដូចជាមិនបានដកទេ ។ ប៉ុន្តែ ដែលសល់ជាឯកសារសម្រាប់ជាភស្តុតាងដល់យើងបច្ចុប្បន្ននេះ គឺជាឯកសារដែល លី ផែល វាឆ្លើយដាក់បងភឹម ។ ខាងលើឲ្យខ្ញុំដកសិនៗទេណា ។

**ស៖** បើខ្ញុំយល់ច្បាស់ ជាពិសេសក្នុងករណីមួយ មានតែមួយហ្នឹង ឬក៏មានប៉ុន្មានដែរ?

**ឆ៖** រឿង៣០ឆ្នាំទៅហើយ កុំដេញដោល ខ្ញុំនឹកមិនឃើញទេ ឯកសារមាន យកមកមើលមក ។ សូមបញ្ជាក់ប៉ុណ្ណឹងទេ ។

**ស៖** ខ្ញុំគ្រាន់តែព្យាយាមពន្យល់ ហើយខ្ញុំនឹងតទៅមុខទៀត ។ នៅក្នុងថ្ងៃទី២០ ឧសភា ២០០៩ លោក អេតឆេសាន់ ហើយក៏នៅក្នុងប្រតិចារឹកហ្នឹង នៅទំព័រ២៤ គាត់បាននិយាយថា ហើយខ្ញុំដកស្រង់គឺថា “ប៉ុល ពត ខ្លួនអាចជាអ្នកទទួលខុសត្រូវចំពោះ...” ខ្ញុំសូមនិយាយឡើងវិញ គាត់និយាយថា “ប៉ុល ពត ខ្លួនឯងអាចនឹងធ្វើអន្តរាគមន៍ក្នុងការដកឈ្មោះ ដែលគេឆ្លើយដាក់នៅក្នុងចម្លើយសារខ្លះ មួយចំនួន” តើលោកឯកភាពនឹងថ្លែងការណ៍នោះទេ?

**ឆ៖** សូមលោកមេធាវីបញ្ជាក់ច្បាស់មើល៎ ដកឈ្មោះអ្នកណា? ដកឈ្មោះបង ប៉ុល ខ្លួនគាត់ ឬក៏ដកឈ្មោះអ្នកណា?

**ស៖** លោក អេតឆេសាន់ មិនបានបញ្ជាក់លម្អិតទេ ប៉ុន្តែ គាត់គ្រាន់តែនិយាយប៉ុណ្ណឹង ប៉ុល ពត អាចនឹងទទួលខុសត្រូវក្នុងការដកឈ្មោះអ្នកណាម្នាក់ចេញពីចម្លើយសារភាពស-២១ ដោយខ្លួនឯង ។ ខ្ញុំឃើញប្រតិចារឹក ហើយខ្ញុំដកស្រង់ត្រង់ ហើយបើសិនជាប៉ុណ្ណឹងគ្រប់គ្រាន់ តើលោកឯកភាពជាមួយថ្លែងការណ៍ទូទៅ អ៊ីចឹងទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា អ្នកដែលបញ្ជាឲ្យខ្ញុំដក គឺអ្នកដែលចុះមកផ្ទាល់នឹងខ្ញុំ ។ ទីមួយ គឺលោកគ្រូ សុន សេន ហ្នឹងឯង ។ បន្ទាប់មក ពូនួន ។ ក៏ប៉ុន្តែ ឈរលើសេចក្តីសម្រេចចិត្តថ្ងៃ៩ តុលា ឆ្នាំ១៩៧៩ គេសរសេរច្បាស់ណាស់ ផ្នែកទីមួយៗរៀបចំឯកសារសូមសេចក្តីសម្រេចរបស់អចិន្ត្រៃយ៍ ។ ដូច្នេះរឿងអីក៏ដោយ ថ្វីត្បិតតែ បងប៉ុល គាត់បញ្ជាមកឲ្យស-២១ ដោយផ្ទាល់ ក៏ប៉ុន្តែឯកសារហ្នឹង វាទុកជាគោលសម្រាប់ឲ្យយើងប៊ានអះអាងថា ទាល់តែមានការអនុម័តពី ប៉ុល ហើយ បាន សុន សេន បញ្ជាក់ឲ្យខ្ញុំ ឬក៏ពូនួន គាត់បញ្ជាឲ្យខ្ញុំអ៊ីចឹង ។ នេះខ្ញុំឈរលើឯកសារហ្នឹង ដើម្បីឆ្លើយ ។

[១៥:៤៤:១៥]

**ស៖** សូមអរគុណ ដែលលោកបានឆ្លើយសំណួរខ្ញុំ ។ លោក អេតឆេសាន់ នៅថ្ងៃទី២៨ ឧសភា ២០០៩ ថ្ងៃដដែល ហើយអត្ថបទប្រតិចារឹកភាសា ២៨-២៩ គាត់បានបញ្ជាក់ថា លោកធ្វើការជានិច្ចកាល ហើយធ្វើការវិភាគទៅលើចម្លើយសារភាព ហើយដកស្រង់ដែលយកបានពីអ្នកទោសនៅស-២១ ហើយនិយាយថា គឺជាការភ័យខ្លាចរបស់គណៈអចិន្ត្រៃយ៍ ដោយសារថាមាន និងត្រូវធ្វើឲ្យមានការបោសសម្អាតច្រើន ដោយសារតែគណៈអចិន្ត្រៃយ៍នោះ មានការភ័យខ្លាច?

**ឆ៖** ខ្ញុំមិនយល់សេចក្តីសន្និដ្ឋានរបស់ អេតឆេសាន់ ទេ ។ មូលដ្ឋានសន្និដ្ឋានរបស់គាត់យ៉ាងម៉េច ខ្ញុំក៏មិនមានមតិដែរ ។ ទុកបញ្ហានេះ ជូនអង្គជំនុំជម្រះវិនិច្ឆ័យចុះ ចំពោះបញ្ហាសន្និដ្ឋាននេះ ក៏ប៉ុន្តែគ្រប់ចំណាររបស់ខ្ញុំលើសេចក្តីសារភាព ខ្ញុំពុះពារឲ្យមានលក្ខណៈសត្យានុម័តដាច់ខាត ចៀសវាងគ្រោះថ្នាក់ដល់អាយុជីវិតដែរ ។ បើសិនជាយើងសន្និដ្ឋាន យើងចារឲ្យគេឃើញថា យើងមានលម្អៀង ដោយស្អប់អ្នកនេះ ស្រឡាញ់អ្នកនោះ ជីវិតយើងក៏រត់មិនរួចដែរ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។ បញ្ហាពីរ ទីមួយ សេចក្តីសន្និដ្ឋានរបស់ អេតឆេសាន់ ទុកជូនអង្គជំនុំជម្រះវិនិច្ឆ័យចុះ ។ ឯចំណែក រឿងខ្ញុំដែលចារលើឯកសារមួយៗ ឯកសារខ្ញុំចារប៉ុន្មាន យកមកមើលទាំងអស់មក ។ តើខ្ញុំខំមែន ឬមិនមែន ដើម្បីរក្សាភាពសត្យានុម័ត?

**ស៖** សូមអរគុណ ។ លោក អេតឆេសាន់ នៅថ្ងៃទី១៩ ឧសភា ២០០៩ ហើយប្រតិចារឹកសេចក្តីព្រាង ទំព័រ៤៩ ហើយខ្ញុំដកស្រង់និយាយថា “ប៉ុន្តែខ្ញុំ ជឿថា ខ្ញុំអាចនិយាយថា ភស្តុតាងណាមួយគឺថាមិនបង្ហាញជាទំនាក់ទំនងផ្ទាល់ប្រចាំថ្ងៃ ជាមួយជនជាប់ចោទ ហើយនិងនួន ជា ដែលទាក់ទងទៅនឹងបញ្ហាមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ” តើលោកឯកសារភាពនឹងថ្លែងការណ៍នោះឬទេ?

**ឆ៖** សូមទោសណ៎ា ខ្ញុំស្តាប់សេចក្តីអធិប្បាយរបស់លោកមិនបានទេ ។ សូមនិយាយឲ្យស្រួលបន្តិចមក សូមទោស សូមមេត្តានិយាយម្តងទៀត ។

**ស៖** ខ្ញុំសូមអនុញ្ញាតិនិយាយឲ្យងាយស្រួលជាងនេះបន្តិច។ លោក អេតឆេសាន់ បាននិយាយថា តាមដែលលោក ដែលគាត់ដឹងនោះ ទំនាក់ទំនងដែលលោកមានជាមួយ សុន សេន ហើយនឹងនួន ជា ។ គាត់និយាយថា ទំនាក់ទំនងនោះគឺផ្ទាល់ ហើយជាឯកជនប្រចាំថ្ងៃ ។ ទំនាក់ទំនងនោះ គឺថាមិនស្របគ្នា ហើយមិនមានទេរវាងមន្ទីរសន្តិសុខផ្សេងៗទៀត ឬក៏អ្នកផ្សេងទៀតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ លើកលែងតែខ្លួនគាត់ផ្ទាល់មួយ ជាមួយពួកគាត់នោះ តើលោកឯកភាពឬទេ?

[១៥:៤៨:២២]

**ឆ៖** ខ្ញុំគិតថា រឿងមេ ដែលហ្មត់ចត់ នឹងការងារ ដែលប្រឹងប្រែងក្នុងការងារ ហៅអ្នកអនុវត្តទៅតាមដានរាល់ថ្ងៃ ជារឿងរបស់គេ ដែលមានចែងច្បាស់លាស់ក្នុងលក្ខន្តិកៈ ហើយនិងសេចក្តីសម្រេចចិត្តថ្ងៃ៩ តុលា ១៩៧៥ គេត្រូវគេធ្វើ ។ ប៉ុន្តែ ដល់និយាយថា ការទាក់ទងឯកជននោះ អត់មានឯកជនទេ អត់មានទេ គឺជាការងារតាមដាន ការងារដែលខ្ញុំអនុវត្ត ។ ក៏ប៉ុន្តែ សូមយើងទាំងអស់គ្នាមើល តើលេខា

ភូមិភាគរបស់គេផ្សេង គេតាមដានយ៉ាងម៉េច? យើងអត់ទាន់មានឯកសារ ឬក៏មានហើយ តែមិនដល់ដៃខ្ញុំ ។ ដូច្នេះ តើយើងសន្និដ្ឋានផ្លូវណា ក្នុងពេលបច្ចុប្បន្ននេះ ដើម្បីឲ្យវាមានលក្ខណៈវិទ្យាសាស្ត្រខ្លះទៅ ។

**ស៖** ខ្ញុំមានសំណួរបួន ឬប្រាំទៀត ខ្ញុំនឹងបញ្ចប់តែប៉ុណ្ណឹង ។ លោកចៅក្រម ខ្ញុំនឹងសួរសំណួរដោយខ្លីៗទេ ។

ជនជាប់ចោទ លោកបាននិយាយចំពោះមុខសហចៅក្រមស៊ើបអង្កេតថា នៅថ្ងៃទី៥ កញ្ញា ឆ្នាំ ២០០៧ ថានៅទំព័រទីo នៃអត្ថបទអង់គ្លេស ហើយនិងលេខ ERN គឺជាភាសាអង់គ្លេស 1475779 រហូតដល់ 00147585 ហើយនៅក្នុងបារាំង--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យគាត់បញ្ជាក់ប្រាប់លេខERN ជាភាសាបារាំង អ្នកបកប្រែអត់ទាន់ គាត់លឿនពេក ។ សូមទោស ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់លេខ ERN នៅឯកសារដែលលោកបំណងលើកឡើងយកមកពិភាក្សាដេញដោលនេះ ឲ្យបានច្បាស់លាស់ម្តងទៀត ពីព្រោះអ្នកកត់ត្រា អ្នកបកប្រែហ្នឹង បកមិនទាន់ទេ ។

**សួរដោយលោក អាឡាំង វែនណឺ៖**

**ស៖** អរគុណលោកប្រធាន ។ អត្ថបទបារាំងគឺ 00147941 រហូតទៅដល់ 001147947 ។ ហើយលោកបានបញ្ជាក់នៅថ្ងៃនោះថា សុន សេន បានជជែកជាមួយលោក អំពីខ្លឹមសារ អំពីអ្វីដែលនិយាយនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ តើលោកនៅចាំទេ ថាលោកបានបញ្ជាក់បែបនោះទៅសហចៅក្រមស៊ើបអង្កេតឬទេ?

[១៥:៥២:១៨]

**ឆ៖** ខ្ញុំភ្លេចហើយ ប៉ុន្តែបើសិនជាមាននៅក្នុងកំណត់ហេតុស្លរចម្លើយជាភាសាខ្មែរ ខ្ញុំទទួលយកសេចក្តីពិតទាំងអស់ ដែលមានក្នុងកំណត់ហេតុស្លរចម្លើយនៃភាសាខ្មែរ ។

**ស៖** លោកចៅក្រម ហើយជាពិសេស ខ្ញុំសូមអនុញ្ញាតមើលទំព័រ៦ ដែលខ្ញុំជូនលេខ ERN ជាអង់គ្លេស 00147584 សូមអនុញ្ញាត និងដាក់បង្ហាញនៅដេញដោលនៅក្នុងអង្គជំនុំជម្រះ ហើយខ្ញុំនឹងសួរសំណួរថា តើលោកបានដឹងយ៉ាងដូចម្តេចអំពីការងារនេះ ពីព្រោះ១៥ ខែសីហានោះ លោកបានធ្វើជា

មួយ សុន សេន ហើយលោកបាននិយាយថា គាត់បានជជែកជាមួយខ្ញុំ អំពីសេចក្តីថ្លែងការណ៍ ហើយនិងកិច្ចប្រជុំ ឬខ្លឹមសារផ្សេងនៅក្នុងសមាជិកគណៈអចិន្ត្រៃយ៍ ។ អ៊ីចឹង ខ្ញុំនឹងចូលទៅដល់សំណួរចុងក្រោយមួយទៀត សំណួរមួយទៀត ។ តើលោកបានដឹងថា តើមាននយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងអំពីការអត់ឃ្លានទេ ក្នុងពេលដែលលោកជាប្រធានស-២១?

**ឆ៖** លោកប្រធានជាទីគោរព! សំណួរនេះព្រឹកមិញ លោកព្រះរាជអាជ្ញាខ្មែរ លោកសួរខ្ញុំរួចហើយ ខ្ញុំបានជម្រាបលោកច្បាស់លាស់ហើយ ខ្ញុំសូមមិនឆ្លើយទេ ។

**ស៖** សូមអភ័យទោស ប្រសិនបើលោកបានឆ្លើយហើយ ។ អ៊ីចឹង ខ្ញុំសួរសំណួរចុងក្រោយពីរ ឬបីទៀត ។ លោក អេតឆេសាន់ បាននិយាយថា នៅថ្ងៃព្រហស្បតិ៍ ២៨ ឧសភា ហើយនៅក្នុងអត្ថបទប្រតិចារឹកនៅទំព័រ៣៦ ដែលនិយាយថា ប្រហែលមនុស្សភាគច្រើនជាអ្នកទទួលខុសត្រូវមន្ទីរខុសត្រូវទាំងនោះនៅក្នុងឆ្នាំ១៩៧៥ ត្រូវបានសម្រិតសម្រាំង ឬបានសម្អាតនៅខែមករា ឆ្នាំ១៩៧៩ តើលោកឯកភាពទេ?

[១៥:៥៥:១០]

**ឆ៖** ខ្ញុំដូចជាចាំថា ការិយាល័យសហព្រះរាជអាជ្ញាដកស្រង់ឈ្មោះ បុគ្គលិកមន្ទីរ ស-២១ មួយបញ្ជីដោយឡែករួចទៅហើយ ។ ដូច្នេះ ខែណា ឆ្នាំណា ខ្ញុំជឿថា បញ្ជីនេះវាច្បាស់លាស់ ទុកជាគោលហើយ ខ្ញុំទទួលស្គាល់បញ្ជីនុ៎ងបើមានមែន ហើយបើឆ្លងកាត់ចៅក្រមស៊ើបអង្កេតទៀតកាន់តែប្រសើរ ។

**ស៖** បើអ៊ីចឹង តើលោកអាចពន្យល់បានដូចម្តេច? ថាលោកគឺជាមនុស្សម្នាក់ក្នុងចំណោមដ៏មួយចំនួនតូចដែលជាអ្នកទទួលខុសត្រូវមន្ទីរសន្តិសុខដែលបានរៀបចំ ហើយកាន់មុខងាររហូតដល់ចប់សម័យហ្នឹង របបកម្ពុជាប្រជាធិបតេយ្យ ដោយមិនទទួលរងនូវការបោសសម្អាត ឬក៏សម្រិតសម្រាំង តើលោកអាចធ្វើម៉េចបានទើបចៀសរួច?

**ឆ៖** រឿងនេះ គេមិនសម្រិតសម្រាំងខ្ញុំ ជារឿងគេ ។ ក៏ប៉ុន្តែ បើសិនជាខ្ញុំពុះពារពិចារណាបញ្ហានេះ គឺខ្ញុំត្រង់ហ្នឹងគេ គេថាប៉ុន្នានប្រាំបី ខ្ញុំអត់ឡើងទៅដល់ប្រាំបួនទេ ។ គេថា ឲ្យដោះលែងតែពួកហ្វូរ៉ូបីនាក់ ខ្ញុំដោះលែងតែបីនាក់ ។ គេថា ស-២១ គ្មានសិទ្ធិកម្ទេចចាប់ចងនរណាទេ ខ្ញុំមិនហ៊ានសម្រេចកម្ទេចចាប់ចងនរណាទេ ។ ដូច្នេះ ចំណារ ស-២១ ដាច់ខាតកុំលម្អៀងណ៎ា ទាមទារគេចាប់អ្នកនេះ ទាមទារគេចាប់អ្នកនោះ ស-២១ អត់ហ៊ានទេ ព្រោះខ្លួនឯងនៅក្រៅក្របខ័ណ្ឌអាប្អូនក្រុមនុះ ហើយតែយើងលូកដៃចូលក្នុង ខ្លួនឯងតាំងខ្លួនអាប្អូនក្រុមហ្នឹងហើយ គឺកំបុតកហើយ ចៀសមិនរួចទេ ប៉ុន កុយ

ធ្លួន យ៉ាងម៉េចកំបុតក ។ ដូច្នេះ យើងខ្ញុំត្រង់ ពាក្យណាយ៉ាងម៉េចអត់ដែលប៉ាានវៀចទេ នេះច្បាស់ ។

[១៥:៥៧:៤០]

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំមិនមានសំណួរអ្វីថែមទៀតទេ លោកចៅក្រម ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ សូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរ ប្រសិនបើមានសំណួរត្រូវសួរដល់ជនជាប់ចោទ អំពីអង្គហេតុដែលកំពុងតែធ្វើសវនាការនេះ ។ សូមអញ្ជើញ ។

**សួរដោយលោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

**ស៖** សូមអរគុណលោកប្រធាន សូមជម្រាបសួរអង្គសវនាការ ។ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា ខ្ញុំគិតថាខ្ញុំនឹងអាចនឹងបញ្ចប់ថ្ងៃនេះជាមួយហ្នឹងសំណួររបស់ខ្ញុំមួយចំនួនតូច ។ ជាដំបូង ខ្ញុំចង់ត្រឡប់ទៅរកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ដែលលោកបានបញ្ជាក់ថា ផ្អែកទៅលើប្រតិចារឹកនៅក្នុងទំព័រ ៥៨ ជាភាសាអង់គ្លេស ។ គឺថាមាន បន្ទាត់ទី១២-១៣ ហើយបើលោកមិនចាត់ទុកអ្នកទាំងហ្នឹងជាខ្មាំងទេ គេមិននឹងសួរចម្លើយដើម្បីទាញយកសេចក្ដីសារភាពនោះទេ ។

តើនេះជាសេចក្ដីសន្និដ្ឋានផ្ទាល់របស់លោក ដែលលោកបានដកស្រង់ចេញពីបទពិសោធន៍ការងាររបស់លោក?

[១៥:៥៩:៤៨]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ប្រែត្រឡប់ចុះត្រឡប់ឡើងពីខ្មែរទៅអង់គ្លេស ហើយពីអង់គ្លេសមកខ្មែរ ខ្ញុំពិបាកស្ដាប់ ក៏ប៉ុន្តែ បើតាមខ្ញុំស្មាន គឺមេរៀនដែលខ្ញុំបង្រៀនកម្មាភិបាលសួរចម្លើយរបស់ខ្ញុំថា មនុស្សដែលគេចាប់មកហើយត្រូវតែចាត់ទុកជាខ្មាំង ។ បើអ្នកឯងមិនចាត់ទុកជាខ្មាំងទេ អ្នកឯងសួរចម្លើយមិនចេញទេ ។ នេះមេរៀនដែលខ្ញុំបង្រៀន ហើយខ្ញុំនិយាយសាចុះសាឡើងនៅស-២១ តែពាក្យមួយម៉ាត់ហ្នឹង ។ ដើម្បីឲ្យវាច្បាស់លាស់ បើតាមខ្ញុំគិតប្រហែលជាសំដៅបញ្ហានេះ បើសំដៅបញ្ហានេះមែន នេះជាមេរៀនដែលខ្ញុំបង្រៀនកម្មាភិបាលសួរចម្លើយស-២១ ជាហូរហែ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** តើលោកបានដឹងថា លោកមិនអាចថា នឹងទទួលចម្លើយពីអ្នកសួរចម្លើយបានទេ បើសិនជាមិនចាត់ទុកពួកគេថាជាខ្មាំង នេះគឺទៅតាមបទពិសោធន៍របស់លោកដែលមាននៅម-១៣ ហើយ

បន្ទាប់មកនៅស-២១ នោះឬ? តើនេះគឺជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកឬ?

**ឆ៖** ត្រឹមត្រូវ ។

**ស៖** សូមអរគុណ ។ តើលោកមានបានអង្កេតមើលនូវភាពអល់អែក ឬក៏ស្ទាក់ស្ទើរក្នុងការធ្វើទារុណកម្ម ឬសម្លាប់អ្នកទោស ឬក៏មានភាពអល់អែកណាមួយ ឬក៏ដូចថាមិនចង់ធ្វើការប្រព្រឹត្តនៅអំពីបែបនេះទេ ដែលបុគ្គលិករបស់លោកអាចនឹងមានអារម្មណ៍បែបនេះ ឬក៏ថាពួកគេអាចនឹងមានអារម្មណ៍បែបនេះនោះ?

**ឆ៖** អានេះវាចូលទៅក្នុងការគ្រប់គ្រងចិត្តសាស្ត្ររបស់បុគ្គលសួរចម្លើយ បុគ្គលិកសួរចម្លើយហើយនិងពួកកងពិសេស ។ អល់អែក ឬមិនអល់អែក ដូចខ្ញុំបានជម្រាបអង្គសវនាការព្រឹកមិញហើយដាវមុតវាទាល់តែប្រើ យើងកាប់ហើយយើងសំលៀង ។ យើងត្រូវសម្រួចគោលជំហរប្រយុទ្ធឱ្យគេជាប់ ។ ដូច្នេះ ខាងកងពិសេស ក៏គេមានមេគេ សម្រួចគោលជំហរប្រយុទ្ធដែរ ។ នេះជាក្រឹត្យក្រមទូទៅនៃការធ្វើការងារ ។ នេះខ្ញុំសូមជម្រាបបញ្ជាក់ប៉ុណ្ណឹង អត់បានសង្កេតថាអ្នកនេះវាកម្រិតតក់ស្លុតប៉ុនណាស្អីប៉ុនណា អត់បានសង្កេតទេ ។

[១៦:០៣:២៣]

**ស៖** តើមានវិធានការអ្វីទេ ដែលលោកបានធ្វើដែលថា អ្នកទោសត្រូវបានចាត់ទុកថាជាខ្មាំងនោះ? តើលោកយល់សំណួររបស់ខ្ញុំដែរឬទេ? ប្រហែលជាមិនយល់ទេឬ?

**ឆ៖** ខ្ញុំអត់យល់ទេ សូមនិយាយម្តងទៀតមកឱ្យស្រួល ។

**ស៖** ខ្ញុំនឹងនិយាយម្តងទៀតឱ្យបានជាក់លាក់ តើលោកប្រើភាសាអ្វីសម្រាប់អ្នកជាប់ទោសដែលត្រូវបានចាត់ទុកថា ជាខ្មាំងនោះ?

**ឆ៖** អ្នកជាប់ទោសនៅស-២១ មានបីសញ្ជាតិ ភាគច្រើនលើសលុបខ្មែរ បុគ្គលិកសួរចម្លើយរបស់ខ្ញុំសុទ្ធតែខ្មែរ មួយចំនួនតូច គឺពួកបស្ចិមប្រទេសបួននាក់នោះ ។

**ស៖** ខ្ញុំសូមទោសដែលខ្ញុំរំខាន ។ អ្វីដែលខ្ញុំនិយាយអំពីភាសាហ្នឹង គឺខ្ញុំមិនចង់និយាយថាភាសាឱ្យចំនោះទេ ។ នៅពេលដែលខ្ញុំនិយាយថា អ្នកទោសដែលត្រូវបានគេចាត់ទុកថាជាខ្មាំងនោះ តើពេលដែលលោកហៅអ្នកទោសនោះ តើហៅប្រើភាសាអីហៅ? ឧទាហរណ៍ តើហៅឈ្មោះចំ ឬក៏ហៅដោយប្រើឈ្មោះត្រកូល ឬឈ្មោះកណ្តាល ឬក៏យ៉ាងម៉េច? តើបុគ្គលិកហៅអ្នកទោសរបៀបណា?

**ឆ៖** ខ្ញុំជម្រាបឲ្យត្រង់ទៅអ្នកទោសនៅម-១៣ អើ!វាឃើញគ្នាព្រឹកល្ងាចអ្ហើយ! អាយុប៉ុនណាក៏អាអ្អែងដែរ អាអ្អែង ។ មកដល់ស-២១ ខ្ញុំទៅសួរចម្លើយតែម្នាក់គត់ គឺ កុយ ធួន សូមបញ្ជាក់ថា កុយ ធួន នេះខ្ញុំធ្លាប់ទៅបម្រើគាត់ពីខែតុលា ១៩៦៧ នៅបឹងធំក្រោយរោងចក្រតម្បាញ កំពង់ចាម ខ្ញុំហៅគាត់បង ដល់គាត់មកជាប់ជាមួយនឹងខ្ញុំ ខ្ញុំហៅគាត់បង ។ ជាស្វ័យប្រវត្តិគាត់មកជាប់ជាមួយខ្ញុំ គាត់ហៅខ្ញុំបងវិញបងទៅបងមករហូត ។ ទីពីរ គឺ វ៉ន វេត ខ្ញុំហៅគាត់បង ។ ឯចំណែក អ្នកទោសផ្សេងទៀតខ្ញុំអត់បានជួបទេ នេះនិយាយឲ្យត្រង់ ក៏ប៉ុន្តែទាល់តែគេរើស្សួរចម្លើយអីអស់ហើយអ៊ីចឹងទៅ ធូរបន្តិចមកខ្ញុំជួបបង ទូច ភឿន គាត់អ្នកកំពង់ធំដូចគ្នា គាត់ចាស់ជាងខ្ញុំ ខ្ញុំហៅគាត់បង អាហ្នឹងមានមែន ។

[១៦:០៦:៥២]

ដូច ចៅ សេង ។ ឯកឧត្តម ចៅ សេង គាត់នៅរស់ គាត់អង្គុយជាមួយបង ម៉ម ណៃ សួរចម្លើយយួន ។ ខ្ញុំទៅលេង ខ្ញុំមិនដឹងហៅម៉េចដែរ ជួនអីខ្ញុំហៅឯកឧត្តមទៅ ឱនលំទោនដាក់គាត់ទៅជួនអីខ្ញុំហៅបងទៅ ។ ឯកឧត្តមព្រោះគាត់ធ្លាប់ធ្វើកុម្ម៉ីចាស់ ខ្ញុំហៅអ៊ីចឹង របៀបហ្នឹង ។ ឯចំណែកក្មេងៗអ្អែងហើយ អាអ្អែងហើយ ច្បាស់ណាស់ ។ អើ! អ្នកនៅរស់នេះម្នាក់ មិនដឹងជាបងខ្ញុំ ឬប្អូនខ្ញុំទេ ប៉ុនអាម៉េង ហើយនេះ ។

**ស៖** តើលោកមានបង្រៀន មានបានបង្រៀនអ្នកសួរចម្លើយដែរឬទេ? តើលោកមានបានពន្យល់ប្រាប់ពួកគេថា ខ្មាំង ត្រូវតែហៅថា អាអ្អែងអ៊ីចឹង តើលោកមានបានពន្យល់ថាជាការងាយស្រួលដើម្បីនឹងធ្វើការធ្វើទារុណកម្មលើពួកគេទេ? បើសិនជាយើងចាត់ទុកពួកអ្នកទោសហ្នឹងថា ពួកអ្អែងនោះ ជាខ្មាំងនោះ?

**ឆ៖** ពាក្យដែលយើងខ្ញុំបង្រៀនពួកអ្នកសួរ វាបង្រៀនហើយ ដដែលៗ ដែលខ្ញុំនិយាយម្តងទៀតទៅចុះ ។ អ្នកណាដែលបក្សចាប់មកហើយត្រូវចាត់ទុកថាជាខ្មាំង បានសួរចម្លើយចេញ ។ ពាក្យ "អ្អែង" ជាពាក្យអាក្រក់ ហើយពាក្យអាក្រក់អ៊ីចឹងមិនចាំបាច់បង្រៀនច្រើនទេ តែមួយម៉ាត់អ្វី! ទៅទាំងអស់ ។

**ស៖** តើលោកមានបានប្រើសត្វ ដើម្បីធ្វើការបន្ទុះបង្អាប់ ឬក៏ធ្វើឲ្យបាត់កិត្តិយសដល់អ្នកទោសដែរឬទេ? ឧទាហរណ៍ ឬ ក៏ប្រើពាក្យដែលសត្វ ដូចជាសត្វ១ដង្កូវ សត្វអីជាដើម ហើយមានបានប្រើអ្នកសួរចម្លើយហ្នឹងឲ្យហៅអ្នកទោសអស់ហ្នឹងដូចជាសត្វធាតុដែរឬទេ?

**ឆ៖** ចៀសមិនរួចទេៗអារឿងទៅអ៊ីចឹងមិនបាច់និយាយច្រើនទេ ទៅហើយ តាមគ្នាហើយ ។ ចៀសមិនរួច ។

**ស៖** អ៊ីចឹងតើខ្ញុំត្រឹមត្រូវទេ បើសិនជាខ្ញុំនិយាយថា ការហៅឈ្មោះអ្នកទោសដូចជាសត្វធាតុហ្នឹង ដែលដូចដែលខ្ញុំទើបតែបានសួរអម្បាញ់មិញហ្នឹង ត្រូវបានយកមកប្រើព្រោះជាការចៀសមិនរួចឬ?

**ឆ៖** ត្រូវហើយៗ ។

[១៦:១០:១៧]

**ស៖** តើលោកមានបានបង្រៀននៅក្នុងវគ្គបណ្ដុះបណ្ដាល វគ្គរៀនសូត្រជាទៀងទាត់ដែលលោកបាននិយាយមុនហ្នឹង តើលោកមានបានបង្រៀន ឬក៏ផ្ដល់ព័ត៌មានដល់អ្នកសួរចម្លើយរបស់លោកអ្នកថា ការប្រើភាសាសត្វធាតុក្នុងការហៅអ្នកទោសបែបហ្នឹងវាជាការងាយស្រួលដើម្បីបំពេញកិច្ចការរបស់គេនោះ? មានន័យថា ដើម្បីងាយស្រួលក្នុងការធ្វើទារុណកម្មពួកគេនោះ?

**ឆ៖** រឿងទារុណកម្មវាផ្សេង រឿងហៅ រឿងនិយាយវាផ្សេង ។ រឿងទារុណកម្ម ជារឿងដែលអ្នកខ្លះគេចេះគិតចេះគូ គេមិនធ្វើ គេមិនងាយធ្វើ ធ្វើតិចណាស់ ។ អ្នកខ្លះគេធ្វើដោយម្ចាស់ការ អ្នកដែលធ្វើតិចណាស់ហ្នឹង ខ្ញុំសូមនិយាយឲ្យវាចំឈ្មោះទៅចុះ អ្នកសួរចម្លើយរបស់ខ្ញុំបង ម៉ម ណៃ ហ្នឹងអត់ងាយទេ ហើយអ្នកដែលគេធ្វើដោយម្ចាស់ការចេះគិតចេះគូថ្លឹងថ្លែង ព្រោះមនុស្សសំខាន់ៗខ្ញុំរុញទៅ គឺមិត្តប៉ុន ក្រៅពីនោះមិនទាន់ម្ចាស់ការទេ។ ដូច មិត្តទុយ អីរកណាស់ រកតែអារឿងវ៉ៃ អារឿងគុណហ្នឹង ។

ដូច្នេះ រឿងទារុណកម្ម យើងអនុញ្ញាត យើងបង្ហាញវិធីខ្លះ យើងបង្រៀនល្បិច កុំពឹងផ្អែកទៅលើទារុណកម្ម យើងមានមែន ។ ក៏ប៉ុន្តែ អារឿងហៅដូចសត្វធាតុអីៗនុំុង វាមិនទាក់ទង មិនរណបសម្រាប់ថា ធ្វើទារុណកម្មសម្រួលចិត្តមនុស្សឲ្យធ្វើទារុណកម្ម គឺអត់ទេ គឺវាទៅតាមគ្នាអ៊ីចឹង ហូរហែ អត់មានអាណាទប់អាណាទេ ទៅទាំងអស់គ្នាហ្នឹង ទាំងខ្ញុំទាំងគេហ្នឹង ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ការហៅអ្នកទោសដោយដូចជាសត្វធាតុនោះ គឺជាវិធីមួយដែលត្រូវបានបណ្ដុះបណ្ដាលដោយលោកនៅក្នុងវគ្គរៀនសូត្រ?

**ឆ៖** សូមមិនឆ្លើយទេ ខ្ញុំនិយាយរួចទៅហើយ ខ្ញុំមិនឆ្លើយច្រំដែលតទៅទៀតទេ សូមទោស ។

**ស៖** តើលោកមានបានបង្រៀន អំពីវិធីមួយទៀត គឺមានន័យថា ការសំពះថ្វាយបង្គំសត្វឆ្កែនោះ ឬក៏ថ្វាយបង្គំទៅលើកៅអី ឬក៏រូបសត្វឆ្កែនោះ តើលោកមានបានបង្រៀនវិធីបែបនេះដែរឬទេ ដើម្បីជា

ការបង្អាប់បង្អោនកិត្តិយសដល់អ្នកជាប់ទោសនោះ?

**ឆ៖** បង្រៀន ខ្ញុំបង្រៀន ។

[១៦:១៤:១៤]

តើអ្វីទៅជាគោលបំណងដែលបង្ខំឲ្យអ្នកទោសថ្វាយបង្គំរូបសត្វឆ្កែជាដើម ឬមួយក៏ធ្វើដូច្នេះដើម្បីជាការបន្តុះបង្អាប់ ឬក៏បង្អាប់បង្អោនដល់កិត្តិយសរបស់អ្នកជាប់ទោស?

**ឆ៖** រឿងនេះ បច្ចុប្បន្ននេះ ចង់វិភាគថាម៉េច វាអត់ខុសទេ ក៏ប៉ុន្តែពេលនោះ ខ្ញុំគិតថា អ៊ើ្ហ មុនដំបូងគេទេ គេធ្វើ ដល់ខ្ញុំឃើញខ្ញុំយល់ស្រប ខ្ញុំដឹងខ្ញុំយល់ស្រប មិនគ្រាន់តែយល់ស្របទេ បង្រៀនឲ្យគេធ្វើទៀត ។ វាជាវិធីមួយសម្រាប់ចៀសវាងការវ៉ៃ ដោយរំពាត់អីៗហ្នឹង វានាំតែនេះទេ ។ ដូច្នេះកាលនោះ គិតប៉ុណ្ណឹង ។ ក៏ប៉ុន្តែឥឡូវ បញ្ហានេះវាជារឿងមួយដែលត្រូវតែថ្កោលទោស ជាឧក្រិដ្ឋកម្មមួយដែលយើងខ្ញុំពិតជាទទួល ។

**ប្រធានអង្គជំនុំ៖**

សូមមេធាវីតម្រង់ន័យសំណួរ ។ ទីមួយ ពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅក្នុងស-២១ ។ បញ្ហាទីពីរ គឺពិចារណាមុននឹងសួរ ចៀសវាងនូវសំណួរពាក់ព័ន្ធនឹងអង្គហេតុនៃដំណើរការប្រតិបត្តិការមន្ទីរស-២១ ។

**សួរដោយលោកស្រី ស៊ីលឃី ស្នូតហ្សិនស្គី៖**

សូមអរគុណលោកប្រធាន ។

**ស៖** ការពន្យល់ដោយខ្លីរបស់ខ្ញុំនោះ គឺថានេះគឺជាការអនុវត្តនូវគោលនយោបាយចំពោះខ្មាំងហើយនេះ គឺជាចំណុចសំខាន់នូវអ្វីដែលយើងកំពុងតែពិភាក្សាគ្នានៅថ្ងៃនេះ ។ លោកបាននិយាយថា អ្នកទោសត្រូវបានហៅថា អានេះ ឬក៏អានោះ ឬក៏អ៊ែ្ហង ។ តើមានន័យដូចម្តេចទៅ ក្នុងការហៅដូច្នេះ? ហើយថាតើលោកបង្រៀនឲ្យគេហៅអ្នកទោសជាស្ត្រីនោះថាដូចម្តេចទៅ?

**ឆ៖** បើតាមខ្ញុំចាំ នៅម-១៣ ហៅឈ្មោះផង មីនេះ មីនោះ អ៊ែ្ហង អត់ហ៊ាំងឯងទេ អ៊ែ្ហង អញ ក៏ប៉ុន្តែ ដល់ស-២១ ខ្ញុំមិនដែលបានទាក់ទងជាមួយអ្នកទោសស្រីណាទេ ហើយមិនដែលបានឮកូនចៅខ្ញុំគេហៅអ្នកស្រីណាម្នាក់យ៉ាងម៉េចទេ ។

**ស៖** សំណួរបន្ទាប់របស់ខ្ញុំ តើលោកអាចបញ្ជាក់ប្រាប់បានទេថា ខ្មាំង និងការប្រើពាក្យអស់ទាំងហ្នឹង ឬក៏ការហៅប្រៀបធៀបពួកគេដូចជាសត្វធាតុនោះ គឺមិនត្រូវចាត់ទុកថា ពួកគេហ្នឹងលែងជា

មនុស្សទៀតហើយមែនទេ?

[១៦:១៨:៥៥]

**ឆ៖** សូមជម្រាបបញ្ជាក់ថា ពេលនោះ យើងអត់គិតជ្រៅដល់ប៉ុននុ៎ងទេ ។ ការបែងចែកខ្មាំង ហើយនិងមិត្ត ។ មិត្តទៅផ្សេង ខ្មាំងទៅផ្សេង ។ យើងខ្ញុំមិនគិតថា លែងជាមនុស្សទេ ខ្មាំងគឺខ្មាំង យើងគឺយើង នេះទស្សនៈគោលជំហរជំនាន់នុ៎ង ។ ក៏ប៉ុន្តែបើឥឡូវ យើងនិយាយពីឥឡូវ យើងយកច្បាប់របស់មនុស្សជាតិទៅមើលវាខុសហើយ វាជាបទឧក្រិដ្ឋហើយ យើងខ្ញុំអត់ប្រកែកទេ ទទួល ក៏ប៉ុន្តែពេលនុ៎ង ទស្សនៈពេលនុ៎ង គឺវាអ៊ីចុង ។

**ស៖** តើវាជាផ្នែកនៃការសួរចម្លើយឬទេ ដែលថាជន អ្នកទោសត្រូវបានគេសម្រាតខោអាវចេញ ទុកតែខោទ្រនាប់ តើហ្នឹងជាផ្នែកនៃបែបបទនៃការសួរចម្លើយឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ទេបញ្ហាហ្នឹង ។ ខ្ញុំមិនច្បាស់ទេ ព្រោះខ្ញុំមិនជាប់សោះការងារសួរចម្លើយលើកលែងតែម្នាក់គត់ គឺ កុយ ធួន ខ្ញុំទៅសួរគាត់ប៉ុននុ៎ង ហើយខ្ញុំចៀសៗជាអតិបរមានៅជាមួយនឹងគាត់យូរ ។ តែកាលណានៅជាមួយនឹងគាត់យូរ គាត់ក៏អ្នកជើងឆើតដែរតើ ជាអ្នកវិភាគនយោបាយដែរតើ គង់លេចចំណុចខ្សោយអីដល់គាត់ ។ ដូច្នេះ ខ្ញុំតែទៅនៅជាមួយនឹងគាត់ឆាប់ណាស់ ខ្ញុំមិននៅយូរទេ ហើយវាអាងនឹងគេដែរ ខ្ញុំមានមនុស្សប្រើ ។ ខ្ញុំចេញមកកងពិសេសពីរនៅហ្នឹង សម្រាប់ទប់ទល់គាត់មិនមកឱ្យ ធ្វើអត្តឃាត ។ ដូច្នេះ សរុបមកខ្ញុំក្តាប់មិនបាន ក៏ប៉ុន្តែ ប្រហែលជាអាចមានលទ្ធភាពទាំងអស់ ឬក៏ជំនាន់ខ្លះ ឬក៏យ៉ាងម៉េច ខ្ញុំមិនដឹង ។ ប៉ុន្តែ ខ្ញុំមិនបដិសេធទេណា ឧក្រិដ្ឋកម្មអស់ៗអ៊ីចឹង ពិតជាមានចំនួនណាខ្លះ ឬក៏ចំនួនទាំងអស់ ប៉ុន្តែ ថាឱ្យណែនាំទៅត្រូវធ្វើអ៊ីចេះៗ គឺអត់ទេ ។ ខ្ញុំសូមនិយាយឱ្យហួសសំណួរបន្តិចទៅចុះ ពីរឿងឆក់ខ្សែភ្លើង ចាប់ចងខ្សែភ្លើងម្ខាងនៅនឹងអាគូលុញទុញ (ពងស្វាស) របស់គ្នាប្រុស អ្នកទោសប្រុស ។ ចាប់ចងខ្សែភ្លើងម្ខាងនៅនឹងមេជើង មិត្តប៉ុន តែម្តង ដល់ចុចចុះ ចុចឡើងវាងាប់ អាគូលុញតុញ គ្នាហ្នឹងបាត់ទៅ ។ ខ្ញុំអត់ដឹង ដល់ពេលរត់ទៅជាមួយគ្នានោះ មិត្តប៉ុន ថ្ងៃមួយនោះគាត់ និយាយលេងជាមួយខ្ញុំ អ្ហឺ!បង អាឆក់ខ្សែភ្លើងអាគូលុញទុញនុ៎ង ងាប់អាគូលុញទុញរបស់គេណា ។ ខ្ញុំថា មិត្តឯងចង់ឆក់នរណា ហើយប្រាប់ខ្ញុំថា ឆក់អាប៉ាវ ប៊ុនស៊ីង ខ្ញុំអ្ហួចប់ ហើយទៅបន្ទោសម៉េច រឿងវាហួសទៅហើយ ។ ប៉ុន្តែ បើសិនជាខ្ញុំដឹងយ៉ាងច្រើនគ្រាន់តែប្រាប់ ប៉ុន ឯងថា មិត្តឯងឈប់ទៅយកទោសម៉េច មិត្តប៉ុន ។ បើយកទោសមិត្ត ប៉ុន ទៅបាននរណាសួរទៀត ។

ដូច្នេះ រឿងវាទារុណកម្ម ហើយនិងរឿង ប្រធានមន្ទីរស-២១ វាអ៊ីចឹង វាមានរឿងខ្លះ មិនដឹង

រឿងខ្លះដឹង រឿងខ្លះដឹងហើយក៏មិនហ៊ានមាត់ សុខចិត្តគ្រាន់តែកែទៅ អាហ្នឹងវាអ៊ីចឹង ។ នេះសូមបញ្ជាក់ឲ្យច្បាស់ទៅ អារឿងសម្រាតហ្នឹង ខ្ញុំអត់បានបញ្ជាទេ ក៏ប៉ុន្តែ ប្រហែលជាអាចមានសម្រាតមែន ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានសំណួរត្រូវសួរច្រើនទៀតទេ? ហើយត្រូវចំណាយពេលប៉ុន្មានទៀតក្នុងការសួរនេះ?

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

លោកប្រធានខ្ញុំអាចនឹងបញ្ចប់បានក្នុងពេលបន្តិចទៀតនេះ ហើយនៅទីបញ្ចប់ ។

**ស៖** តើលោកអាចអានចម្លើយសារភាពដែលថា អ្នកទោសបាននិយាយថាៗ ខ្ញុំមិនមែនជាមនុស្សជាតិទៀតទេ ហើយខ្ញុំជាសត្វ? តើលោកធ្លាប់បានអានជួប ចម្លើយសារភាពដែលមានខ្លឹមសារបែបនោះដែរឬទេ?

**ឆ៖** ចម្លើយសារភាពច្រើនណាស់ បើសិនជាខ្ញុំបានអានប៉ះលើចម្លើយរបៀបនេះ ក៏មិនបានជាយកចិត្តទុកដាក់អីទេ ជំនាន់នុងណាៗ អារម្មណ៍ជំនាន់នុងៗគិតថា ម៉េចខ្សែខ្លាំង ម៉េចអីៗ អាហ្នឹងគឺគិតមែន ។ ក៏ប៉ុន្តែ ដល់ទៅ គិតដល់ទៅមនុស្សធម៌ សីលធម៌អី ចាប់អារម្មណ៍នឹងអ៊ីចឹង ជំនាន់នុងអត់ទេ ។ ក៏ប៉ុន្តែឥឡូវនេះ រឿងវាប៉ុណ្ណេះទៅហើយ យើងត្រូវតែទទួលស្គាល់ថា អាហ្នឹងវាខុសនឹងច្បាប់មនុស្សជាតិ យើងទទួលឧក្រិដ្ឋកម្មនេះដោយភ្ញាក់រឭក អានេះវាមានមែន ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

សូមអរគុណ ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ លោកប្រធាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

នៅក្នុងដំណើរការសវនាការនៅសម្រាប់ថ្ងៃនេះ ក៏ដល់ទីបញ្ចប់ហើយ គឺដល់ម៉ោងកំណត់លើសប្រាំពីរមីនុតហើយដែរ ។ អ៊ីចឹង អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែក ទី៩ ខែមិថុនា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនឹងឲ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ។ ហើយជម្រាបដល់ភាគីទាំងអស់ដែលត្រូវ ចូលរួមក្នុងដំណើរសវនាការ គឺសូមអញ្ជើញឲ្យបានទាន់ម៉ោងកំណត់ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:២៦ នាទី]*